# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ការវាយតម្លៃពាក់កណ្ដាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤ - ២០១៨

## ២. ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧



ខែ ធ្នូ ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ
# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# ២០១៤ - ២០១៨

## ២. ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧



ខែ ធ្នូ ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........................................ ១

អក្សរកាត់ និងពាក្យកាត់ ........................................ ៣

សន្ទានុក្រម ........................................ ៦

សេចក្តីសង្ខេបអំពីកត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ........................................ ១០

១. សេចក្តីផ្តើម ........................................ ១១

២. ការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........................................ ១៣

២.១ ក្របខ័ណ្ឌ PESTLE ........................................ ១៤

២.២ ក្របខ័ណ្ឌសន្តិសុខស្បៀង ........................................ ១៤

២.៣ ក្របខ័ណ្ឌទស្សនទានស្តីពីបញ្ហាអាហារូបត្ថម្ភ ........................................ ១៥

២.៤ របៀបវារៈ ការអភិវឌ្ឍដោយចីរភាព ឆ្នាំ ២០៣០ ........................................ ១៨

៣. ការវិភាគស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (PESTLE) ... ២០

៣.១ និន្នាការនយោបាយ និងច្បាប់ ........................................ ២០

៣.២ និន្នាការសេដ្ឋកិច្ច ........................................ ២៦

៣.៣ និន្នាការសង្គម-ប្រជាសាស្ត្រ ........................................ ២៩

៣.៤ និន្នាការបច្ចេកវិទ្យា ........................................ ៣៥

៣.៥ និន្នាការបរិស្ថាន ........................................ ៣៦

៤. ការវិភាគលើស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........................................ ៣៧

៤.១ និន្នាការនៃភាពមានស្បៀង ........................................ ៣៧

៤.២ និន្នាការនៃការទទួលបានស្បៀង ........................................ ៤១

៤.៣ និន្នាការនៃការបឺតស្រូបស្បៀង ........................................ ៤៥

៤.៤ និន្នាការនៃស្ថិរភាពស្បៀងអាហារ ........................................ ៥១

៥. ដំណើរឆ្ពោះទៅសម្រេចរបៀបវារៈឆ្នាំ ២០៣០ ........................................ ៥៤

មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ ........................................ ៥៤

អន្តរាគមន៍អាហារូបត្ថម្ភ ជាចលករពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ........ ៥៧

បញ្ជីឯកសារយោង ........................................ ៥៩

# សេចក្ដីថ្លែងអំណរគុណ

ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និងជាប្រធានក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសេចក្ដីសោមនស្សរីករាយសូមប្រកាសផ្សព្វផ្សាយលទ្ធផលរកឃើញនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិ លើ យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០១៤-២០១៨។ ឯកឧត្តមសូមថ្លែងអំណរគុណ ចំពោះការរួមចំណែកដ៏មានសារៈសំខាន់ និងការចូលរួមដ៏សកម្ម ពីមន្ត្រីក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ តំណាងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ស្ដីពី ការវាយតម្លៃពាក់កណ្ដាលអាណត្តិលើ យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនេះ។ បន្ថែមលើសពីនេះ ឯកឧត្តម **យឹម ឆៃលី** សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ដែលបានជួយគ្រប់បែបយ៉ាងដល់ការវាយតម្លៃនេះ ដោយមានការចូលរួមពីសហភាពអឺរ៉ុប ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ទីភ្នាក់ងារសហប្រជាជាតិនានា ដូចជា អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) អង្គការស្បៀងអាហារពិភពលោក (WFP) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ព្រមទាំងសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ ដែលដឹកនាំដោយ អង្គការហេលិន ខេល័រ អន្តរជាតិ (Helen Keller International)។ ឯកឧត្តមក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះធនាគារពិភពលោក ដែលបានជួយធ្វើការពិនិត្យល្អិតល្អន់លើការងារនេះ។

ការងាររបស់គណៈកម្មាធិការផ្ដល់ប្រឹក្សា ដែលត្រូវបានបង្កើតឡើងជាផ្លូវការ សម្រាប់ការវាយតម្លៃពាក់កណ្ដាលអាណត្តិលើការអនុវត្តយុទ្ធសាស្ត្រនេះ ហើយដែលមានឯកឧត្តម **ឌី ច័ន្ទផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធាន និងសមាជិកជាតំណាងមកពីក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងការតម្រង់ទិសដល់ដំណើរការក៏ដូចជាការបញ្ជាក់ផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យឡើងវិញនេះផងដែរ។ ឯកឧត្តមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោកស្រី **Veena Reddy** នាយកបេសកកម្មស្ដីទីរបស់ USAID ដែលបានចូលរួមសហការប្រកបដោយការប្ដេជ្ញាចិត្តខ្ពស់។ សមាជិកដែលមាននៅក្នុងក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានចូលរួមនៅក្នុងការវាយតម្លៃពាក់កណ្ដាលអណត្តិនេះ ហើយឯកឧត្តមសូមធ្វើការវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងគាំទ្ររបស់ពួកគេក្នុងការជម្នះបញ្ហាប្រឈម ដែលកំពុងបន្តកើតមានឡើងក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ជាវេទិកាដ៏សំខាន់ សម្រាប់ធ្វើការផ្សព្វផ្សាយវឌ្ឍនភាព ដែលសម្រេចបានជាមួយនឹងការវាយតម្លៃនេះ ហើយក៏ជាវេទិកាសម្រាប់ការពិភាក្សាពីលទ្ធផលនានាផងដែរ។

បន្ទាប់ពីមានការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញយ៉ាងទូលំទូលាយរួចមក ឯកសារចុងក្រោយត្រូវបានប្រកាសផ្សព្វផ្សាយដោយឯកឧត្តម **យឹម ឆៃលី** ក្នុងនាមតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា លោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោក **David Kaatrud** ប្រធានការិយាល័យតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការស្បៀងអាហារពិភពលោក នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៨។ ឯកសារផ្សេងគ្នាចំនួនបីត្រូវបានរៀបចំឡើងសម្រាប់ការវាយតម្លៃពាក់កណ្ដាលអណត្តិនេះ ដោយបានបញ្ចូលគំនិតយោបល់ជាធាតុចូលពីប្រភពផ្សេងៗ

ហើយពង្រាងឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យពិភាក្សាយ៉ាងទូលំទូលាយ។ ឯកសារទាំងបីនេះត្រូវបានរៀបចំឡើង ផ្អែកទៅតាមឯកសារយោងជាច្រើន និងការវិភាគមួយចំនួនដែលកំពុងបន្តធ្វើ។ ឯកសារបីសំខាន់ៗនៃការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ រួមមាន៖

១. វឌ្ឍនភាពដែលសម្រេចបានត្រឹមឆ្នាំ ២០១៦

២. ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧

៣. ទិសដៅជាយុទ្ធសាស្ត្រ ឆ្ពោះទៅឆ្នាំ ២០៣០

ខណៈពេលដែលឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយជាមួយគ្នា ឯកសារទាំងនេះជាឯកសារដោយឡែកៗពីគ្នា ដោយហេតុថា ឯកសារនីមួយៗ គឺជាការវិភាគដោយឡែកៗពីគ្នា។ ដូចដែលបង្ហាញនៅក្នុងឯកសារទាំងនេះ ការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ បានផ្តល់នូវរបកគំហើញសំខាន់ៗជាច្រើន ព្រមទាំងផ្តល់នូវការណែនាំអំពីជំហានបន្ទាប់ផងដែរ។ ការវាយតម្លៃនេះក៏ជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ ២០១៩-២០២៣ និងជាមូលដ្ឋានជួយជំរុញកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភផងដែរ។

ដំណើរការពិគ្រោះយោបល់ និងការពិភាក្សានេះ ក៏ជាច្រកសំខាន់សម្រាប់ជួយឱ្យមានការរៀនសូត្រ និងការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ គិតត្រឹមចុងឆ្នាំ២០១៦ មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងការឈានទៅសម្រេចគោលបំណងជាយុទ្ធសាស្ត្រនានា។ ទិសដៅរបស់យើងក្នុងដំណើរឆ្ពោះទៅមុខ ត្រូវបានដាក់ចេញយ៉ាងជាក់ច្បាស់។ យុទ្ធសាស្ត្រនេះជួយតម្រង់ទិសសកម្មភាពដែលត្រូវអនុវត្តសម្រាប់រយៈពេលនៅសេសសល់ រហូតដល់ចុងឆ្នាំ ២០១៨។ គ្រប់គោលនយោបាយ និងកម្មវិធីតាមវិស័យទាំងអស់ គួរបញ្ចូលទិសដៅទាំងនេះ ហើយគោលនយោបាយ និងកម្មវិធីនីមួយៗសុទ្ធតែរួមចំណែកដល់ការសម្រេចទិសដៅទាំងនេះ ទៅតាមតួនាទី និងការទទួលខុសត្រូវរបស់វិស័យនីមួយៗ។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការពង្រឹងយន្តការសម្របសម្រួលការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ ជាពិសេស សំដៅធានាយ៉ាងណាឱ្យមានការកសាងសមត្ថភាព ពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាព នៅចុងរយៈពេលនៃយុទ្ធសាស្ត្រនេះ។ យើងត្រូវធានាយ៉ាងណាឱ្យគ្រប់ភាគីទាំងអស់ធ្វើការងាររួមគ្នា និងត្រូវបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់ភាពអត់ឃ្លាននៅកម្ពុជាឱ្យបានត្រឹមឆ្នាំ ២០៣០។ យើងទាំងអស់គ្នាអាចបង្ហាញពីគំរូភាពដល់ប្រទេសនានា នៅក្នុងសកលលោកទាំងមូល តាមរយៈការខិតខំធ្វើការងារឆ្ពោះទៅសម្រេចគោលដៅនេះ ពោលគឺការធ្វើការងាររួមគ្នាជាធ្លុងមួយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមតម្រាយផ្លូវនៃយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ដទៃទៀត។

# អក្សរកាត់ និងពាក្យកាត់

## ស្ថាប័នរដ្ឋាភិបាល

| | | |
|---|---|---|
| CARD | Council for Agricultural and Rural Development | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CRDB | Cambodian Rehabilitation and Development Board | គណៈកម្មាធិការស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| IFReDI | Inland Fisheries Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យនេសាទទឹកសាប |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NMCHC | National Maternal and Child Health Center | មជ្ឈមណ្ឌល ជាតិគាំពារ មាតា និងទារក |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

## អង្គការសហប្រជាជាតិ/អង្គការមិនមែនរដ្ឋាភិបាល/ស្ថាប័ននានា

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CFS | Committee on World Food Security | គណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក |
| CSA | Civil Society Alliance | សម្ព័ន្ធសង្គមស៊ីវិល |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |

| | | |
|---|---|---|
| HKI | Helen Keller International | ហេលិន ខេល័រ អន្តរជាតិ |
| HLPE | High-Level Panel of Experts | គណៈកម្មាធិការជំនាញកម្រិតខ្ពស់ |
| IDS | Institute of Development Studies | វិទ្យាស្ថានសិក្សាពីការអភិវឌ្ឍន៍ |
| IFPRI | International Food Policy Research Institute | វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវគោលនយោបាយស្បៀងអាហារ |
| ODI | Overseas Development Institute | វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស |
| SUN | Scaling Up Nutrition | ចលនាបង្កើនអាហារូបត្ថម្ភ |
| SUN-CSN | SUN Civil Society Network | បណ្តាញសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិដើម្បីប្រជាជន |
| UNICEF | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WFP | World Food Programme | កម្មវិធីស្បៀងអាហារពិភពលោក |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

## ពាក្យកាត់ផ្សេងៗ

| | | |
|---|---|---|
| BMI | Body Mass Index | សន្ទស្សន៍ម៉ាសរាងកាយ |
| DM | Disaster Management | ការគ្រប់គ្រងគ្រោះមហន្តរាយ |
| DDS | Dietary Diversity Score | ពិន្ទុរបបអាហារចម្រុះ |
| FSN | Food Security and Nutrition | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| HDI | Human Development Index | សន្ទស្សន៍នៃការអភិវឌ្ឍន៍មនុស្ស |
| LMIC | Lower Middle-Income Country | ប្រទេសចំណូលមធ្យមកម្រិតទាប |
| MTSR | Mid-Term and Strategic Review | ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រ |
| NAP/ZHC | National Action Plan for the Zero Hunger Challenge in Cambodia | ផែនការសកម្មភាពជាតិលុបបំបាត់គ្រោះអត់ឃ្លាននៅកម្ពុជា |
| NCDs | Non-Communicable Diseases | ជំងឺមិនឆ្លង |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

| | | |
|---|---|---|
| NSFSN | National Strategy for Food Security and Nutrition | យុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| NSPPF | National Social Protection Policy Framework | ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| ODA | Official Development Assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| PESTLE | Political, Economic, Social, Technological, Legal and Environmental | ការវិភាគអំពី នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និង បរិស្ថាន |
| SDG | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |
| WASH | Water, Sanitation and Hygiene | ទឹកស្អាត និងអនាម័យ |
| WRA | Women of Reproductive Age | ស្ត្រីវ័យបន្តពូជ |

# សទ្ទានុក្រម

**អសន្តិសុខស្បៀងរ៉ាំរ៉ៃ៖** ការពុំមានលទ្ធភាពបំពេញតម្រូវការអាហារអប្បបរមាក្នុងរយៈពេលវែង ឬជាប់ជាប្រចាំ។

**ភាពក្រីក្ររ៉ាំរ៉ៃ៖** ជនក្រីក្ររ៉ាំរ៉ៃ គឺជាជនដែលការប្រើប្រាស់ជាមធ្យមក្នុងមនុស្សម្នាក់ក្នុងរយៈពេលមួយស្ថិតនៅកម្រិតបន្ទាត់នៃភាពក្រីក្រ ឬទាបជាងបន្ទាត់នៃភាពក្រីក្រ។

**យុទ្ធសាស្ត្រទប់ទល់៖** សកម្មភាពដែលប្រជាពលរដ្ឋត្រូវធ្វើ ដើម្បីទទួលបានអាហារ ចំណូល និង/ឬសេវានានា នៅពេលដែលមធ្យោបាយប្រកបរបរចិញ្ចឹមជីវិតធម្មតារបស់ពួកគេត្រូវបានរំខាន។

**របបអាហារចម្រុះ៖** រង្វាស់គុណភាពនៃអាហារ ពោលគឺគុណភាពដែលផ្អែកទៅតាមចំនួនក្រុមអាហារដែលបរិភោគដោយមនុស្សម្នាក់ ឬគ្រួសារមួយ ក្នុងរយៈពេលប្រាំពីរថ្ងៃ ដែលត្រូវបានប្រើប្រាស់ជារយៈពេលគោលសម្រាប់ប្រៀបធៀប។ របបអាហារចម្រុះរបស់គ្រួសារ (HDDS) ឆ្លុះបញ្ចាំងពី "លទ្ធភាពផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ ក្នុងការទទួលបានអាហារចម្រុះមុខ" នៅពេលណាមួយ។ កំណើនរបបអាហារចម្រុះរបស់គ្រួសារមានទំនាក់ទំនងជាមួយស្ថានភាពសង្គម សេដ្ឋកិច្ច និងសន្តិសុខស្បៀងរបស់គ្រួសារ (ការមានថាមពល)។

**ការទទួលបានស្បៀង៖** លទ្ធភាពរបស់គ្រួសារមួយក្នុងការទទួលបានស្បៀងជាប្រចាំ តាមរយៈមធ្យោបាយមួយ ឬច្រើនបញ្ចូលគ្នា ដូចជា ការផលិតដោយខ្លួនឯង និងការស្តុកទុកស្បៀង ការទិញ ការលក់ដូរ អំណោយ ការខ្ចី និងជំនួយស្បៀង ជាដើម។

**ភាពមានស្បៀង៖** ស្បៀងដែលមានវត្តមានជាក់ស្តែងនៅកន្លែងដែលពាក់ព័ន្ធ តាមរយៈគ្រប់ទម្រង់ទាំងអស់ ដូចជា ការផលិតស្បៀងក្នុងស្រុក ការនាំចូលជាលក្ខណៈពាណិជ្ជកម្ម ស្បៀងបម្រុង និងជំនួយស្បៀង។ ស្បៀងដែលអាចមាន អាចត្រូវបានស្តុកទុក នៅថ្នាក់តំបន់ ថ្នាក់ជាតិ ថ្នាក់ស្រុក ឬថ្នាក់សហគមន៍។

**សន្តិសុខស្បៀង៖** ស្ថានភាពដែលជនគ្រប់រូប នៅគ្រប់ពេល មានលទ្ធភាពផ្នែករូបវន្ត និងសេដ្ឋកិច្ច ដើម្បីទទួលបានស្បៀងគ្រប់គ្រាន់ មានសុវត្ថិភាព ប្រកបដោយសារអាហារូបត្ថម្ភ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តអាហាររបស់ពួកគេ ដើម្បីអាចរស់នៅក្នុងជីវិតដែលសកម្ម និងប្រកបដោយសុខភាពល្អ (កិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារ ឆ្នាំ ១៩៩៦)។

**ការបឺតស្រូបស្បៀង៖** (ក) ការប្រើស្បៀងអាហាររបស់គ្រួសារមួយ ដែលគ្រួសារនោះទទួលបាន (ខ) លទ្ធភាពរបស់បុគ្គលម្នាក់ក្នុងការស្រូបយក និងបម្លែងសារធាតុចិញ្ចឹមទៅជាថាមពល (ពោលគឺប្រសិទ្ធភាពនៃការបម្លែងស្បៀងអាហារ របស់សារពាង្គកាយ)។

**យេនឌ័រ៖** តួនាទី និងការទទួលខុសត្រូវ ដែលកំណត់ដោយសង្គមរបស់ស្ត្រី និងបុរស ដែលសំដៅលើតួនាទី និងការទទួលខុសត្រូវ ដែលពួកគាត់បានរៀន (ដូច្នេះ ពួកគាត់ក៏អាចផ្លាស់ប្តូរនូវអ្វីដែលពួកគាត់បានរៀននេះដែរ) និងការរំពឹងទុករបស់ស្ត្រី និងបុរស ដែលជារឿយៗ ត្រូវបានគេពិពណ៌នាដោយប្រើប្រាស់ពាក្យថា ភាពជាបុរស និងភាពជាស្ត្រី។

**មុខរបរចិញ្ចឹមជីវិត៖** សមត្ថភាពទ្រព្យសម្បត្តិ (ទ្រព្យសម្បត្តិជាសម្ភារ និងឋានៈក្នុងសង្គម) និងសកម្មភាពនានាដែលចាំបាច់ត្រូវមាន ដើម្បីប្រើជាមធ្យោបាយសម្រាប់រស់រាន និងមានសុខុមាលភាព។

**បញ្ហាអាហារូបត្ថម្ភ៖** សំដៅលើបញ្ហាកង្វះអាហារូបត្ថម្ភផង និងបញ្ហាលើសអាហារូបត្ថម្ភផង។ បញ្ហាខ្វះអាហារូបត្ថម្ភ និងការលើសទម្ងន់ អាចកើតមានក្នុងពេលជាមួយគ្នា ដែលគេហៅថា "បន្ទុកទ្វេ" នៃបញ្ហាអាហារូបត្ថម្ភ។ បញ្ហាខ្វះមីក្រូសារជាតិចិញ្ចឹម សំដៅលើកង្វះវីតាមីន និងសារធាតុរ៉ែ (ឧទាហរណ៍ សារធាតុអ៊ីយ៉ូដ ជាដើម)។

**ភាពក្រីក្រពហុសមាសភាគ៖** វាយតម្លៃលើលក្ខណៈ និងភាពធ្ងន់ធ្ងរនៃភាពក្រីក្រ តាមរយៈការកំណត់រកបញ្ហាចម្រុះដែលកើតមានឡើង (ពាក់ព័ន្ធនឹងសុខភាព ការអប់រំ និងជីវភាពរស់នៅ) និងវិសាលភាពនៃបញ្ហាទាំងនេះនៅកម្រិតបុគ្គលម្នាក់ៗ។ ការវាយតម្លៃប្រភេទនេះប្រើប្រាស់ទិន្នន័យលម្អិត ដែលបានពីការអង្កេតគ្រួសារ និងអាចយកមកធ្វើការបូកសរុប ដើម្បីបង្កើតជារង្វាស់ភាពក្រីក្រនៅថ្នាក់ជាតិ ស្របទៅតាម

និយមន័យស្តង់ដាររបស់ UNDP ដែលពិនិត្យលើសូចនាករសុខភាព (អាហារូបត្ថម្ភ និងមរណភាពកុមារ) ការអប់រំ (ការចូលរៀនរបស់កុមារ និងចំនួនឆ្នាំសិក្សា) និងជីវភាពរស់នៅ (វង្វាស់ទ្រព្យសម្បត្តិនៅក្នុងគ្រួសារមួយ ការរស់នៅក្នុងផ្ទះ ដែលមានកម្រាលត្រឹមត្រូវ ការទទួលបានទឹក អគ្គិសនី បង្គន់ និងឥន្ទនៈសម្រាប់ចម្អិនអាហារ)។

**អន្តរាគមន៍ដែលយកចិត្តទុកដាក់ចំពោះបញ្ហាអាហារូបត្ថម្ភ៖** អន្តរាគមន៍ទាំងឡាយ ដែលគោលបំណងចម្បងមិនចាំបាច់ផ្តោតលើអាហារូបត្ថម្ភនោះឡើយ ប៉ុន្តែជាអន្តរាគមន៍ ដែលមានសក្តានុពលលើកកម្ពស់សន្តិសុខអាហារូបត្ថម្ភរបស់ក្រុមគោលដៅ។ អន្តរាគមន៍បែបនេះច្រើនបញ្ចូលសកម្មភាព ដែលមានឥទ្ធិពលលើអាហារូបត្ថម្ភ តាមរយៈការផ្តោតការយកចិត្តទុកដាក់លើមូលហេតុដែលជាឫសគល់ នាំឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ ដូចជា កសិកម្ម និងសន្តិសុខស្បៀង ការទទួលបានសេវាថែទាំសុខភាព និងការអប់រំ ទឹកស្អាត និងអនាម័យជាដើម។

**អន្តរាគមន៍ផ្តោតលើអាហារូបត្ថម្ភ៖** អន្តរាគមន៍ទាំងឡាយ ដែលមានគោលបំណងចម្បងដោះស្រាយបញ្ហាអាហារូបត្ថម្ភ និងផ្តោតគោលដៅលើមូលហេតុដែលនាំឱ្យមានបញ្ហារូបត្ថម្ភ ដែលប៉ះពាល់ដល់ការអភិវឌ្ឍទារកក្នុងផ្ទៃ និងការអភិវឌ្ឍរបស់កុមារ ក៏ដូចជាសុខភាពមាតា បញ្ហាដែលពាក់ព័ន្ធជាមួយនឹងការបឺតស្រូបស្បៀងអាហារ និងសារធាតុចិញ្ចឹមឱ្យបានគ្រប់គ្រាន់ ការផ្តល់អាហារ របៀបថែទាំ និងចិញ្ចឹមបីបាច់កូន និងផលប៉ះពាល់នៃជំងឺឆ្លងមួយចំនួន។ ឧទាហរណ៍នៃអន្តរាគមន៍ ដែលផ្តោតលើអាហារូបត្ថម្ភរួមមាន ការផ្តល់អាហារបន្ថែម ការផ្តល់អាហារបន្ថែមពីលើរបបអាហារធម្មតា ការជំរុញលើកទឹកចិត្តឱ្យបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារចម្រុះ និងការបន្ថែមមីក្រូសារជាតិ ឬការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារសម្រាប់កុមារ ការព្យាបាលបញ្ហាអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ ការបង្ការ និងការគ្រប់គ្រងជំងឺ និងអាហារូបត្ថម្ភក្នុងស្ថានភាពអាសន្ន។

**បញ្ហាលើសអាហារូបត្ថម្ភ៖** មនុស្សអាចមានបញ្ហាអាហារូបត្ថម្ភផងដែរ ប្រសិនបើពួកគេស្រូបយកកាឡូរីច្រើនពេក។

**ចំនួនប្រជាពលរដ្ឋក្រីក្រ៖** ភាគរយនៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ គណនាដោយប្រើប្រាស់ស្ថិតិចំណាយរបស់ជាតិ។

**ភាពធន់ទ្រាំ៖** លទ្ធភាពធូរស្រាលឡើងវិញ បន្ទាប់ពីរងផលប៉ះពាល់ដោយសារវិបត្តិអ្វីមួយ។

**ហានិភ័យអសន្តិសុខស្បៀង៖** លទ្ធភាពដែលបញ្ហាអសន្តិសុខស្បៀងអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ/គ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស និងស្ថានភាពងាយរងគ្រោះនានា។

**វិបត្តិ៖** ព្រឹត្តិការណ៍ដែលបង្កផលប៉ះពាល់ជាអវិជ្ជមានមកលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ វិបត្តិអាចជាវិបត្តិធម្មជាតិ ឬវិបត្តិដែលបង្កឡើងដោយសកម្មភាពរបស់មនុស្ស។

**បញ្ហាក្រិសក្រិន៖** កម្ពស់ទាបពេក ធៀបនឹងអាយុរបស់បុគ្គល។

**កង្វះអាហារូបត្ថម្ភ៖** មនុស្សមានបញ្ហាកង្វះអាហារូបត្ថម្ភ ប្រសិនបើរបបអាហាររបស់ពួកគេពុំបានផ្តល់នូវកាឡូរី និងប្រូតេអ៊ីនឱ្យបានគ្រប់គ្រាន់សម្រាប់ការលូតលាស់ និងការបន្តការលូតលាស់ ឬពួកគេពុំអាចបឺតស្រូបស្បៀងអាហារ ដែលពួកគេបរិភោគឱ្យបានពេញលេញ ដោយសារតែពួកគេមានជំងឺ។ បញ្ហានេះអាចស្តែងចេញជាការមានទម្ងន់មិនគ្រប់ បើធៀបនឹងអាយុរបស់បុគ្គល និងអាចជាបញ្ហាក្រិសក្រិន ពោលគឺកម្ពស់ទាបពេក បើធៀបនឹងអាយុរបស់បុគ្គល និងបញ្ហាស្គមស្គាំង ពោលគឺស្គមពេក ដែលអាចនាំឱ្យមានគ្រោះថ្នាក់ បើធៀបជាមួយនឹងកម្ពស់របស់បុគ្គល។

**ភាពងាយរងគ្រោះដោយសារបញ្ហាអសន្តិសុខស្បៀង៖** ស្ថានភាពដែលបង្កើនភាពងាយរងគ្រោះរបស់គ្រួសារមួយចំពោះផលប៉ះពាល់មកលើសន្តិសុខស្បៀង នៅក្នុងករណីដែលមានវិបត្តិអ្វីមួយកើតមានឡើង។ ភាពងាយរងគ្រោះមានទំនាក់ទំនងជាមួយនឹងផលប៉ះពាល់មកលើជីវភាពរស់នៅរបស់គ្រួសារ ដែលបង្កឡើងដោយគ្រោះថ្នាក់អ្វីមួយ និងរបៀបដែលគ្រួសារនោះទប់ទល់ជាមួយនឹងផលប៉ះពាល់នេះ។

**ស្គមស្គាំង៖** រូបរាងស្គមពេក ធៀបនឹងកម្ពស់បុគ្គល ដែលនាំឱ្យបុគ្គលនោះអាចនឹងមានគ្រោះថ្នាក់។

សេចក្តីសង្ខេប

# សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា

### យុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨

"ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជា មានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សំគាល់ ក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្រប និងតម្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្ត ក្នុងការទទួលទានអាហារ ព្រមទាំងប្រើប្រាស់ស្បៀង អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ប្រជាពលរដ្ឋ មានសុខភាពល្អ និងមានផលិតភាពខ្ពស់។"

### គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២ (SDG2)

បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រសើរជាងមុន និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព

ដើម្បីសម្រេចគោលបំណងសន្តិសុខស្បៀង ចាំបាច់ត្រូវមានការសម្រេចបាននូវសមាសភាគទាំងបួន (ភាពមានស្បៀង ការទទួលបានស្បៀង ការបឺតស្រូបស្បៀង និងសុវត្ថិភាពស្បៀង) ក្នុងពេលជាមួយគ្នា។




## ការវិភាគអំពីក្របខណ្ឌនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន

### និន្នាការនយោបាយ និងច្បាប់ » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី១

**គោលនយោបាយ និង យុទ្ធសាស្ត្រសំខាន់ៗ**

- » ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម ២០១៦-២០២៥
- » យុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨
- » ផែនការសកម្មភាពជាតិកាត់បន្ថយភាពអត់ឃ្លាននៅកម្ពុជា ២០១៦-២០២៥
- » ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០
- » យុទ្ធសាស្ត្ររបស់ស្ថាប័នពាក់ព័ន្ធផ្សេងៗ

**សម្ព័ន្ធភាពនៅថ្នាក់តំបន់ និងថ្នាក់សកល**

គោលនយោបាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់អាស៊ាន មានគោលបំណងចម្បង "ដើម្បីធានាឱ្យការផ្គត់ផ្គង់ប្រកបដោយចីរភាពនូវស្បៀងអាហារគ្រប់គ្រាន់ក្នុងតម្លៃសមរម្យ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដែលបំពេញទៅតាមតម្រូវការអាហាររបស់ប្រជាពលរដ្ឋនៅក្នុងអាស៊ាន ដែលមានចំនួនកើនឡើង"

ក្របខ័ណ្ឌ Hyogo ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

កម្ពុជាបានបង្កើនសមត្ថភាពស្ថាប័នក្នុងការ បង្កើនសកម្មភាពអាហារូបត្ថម្ភ បាន ២០% នៅឆ្នាំ ២០១៧ បើធៀបនឹងឆ្នាំ ២០១៥ វាមានកំណើន៥០%។




### និន្នាការសេដ្ឋកិច្ច » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី២

"ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ ដែលធានាឱ្យមានភាពប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ..."

ភាគរយនៃប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្ររបស់ជាតិបានថយចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកនៅ ១៣,២% ក្នុងឆ្នាំ ២០១៤ (MEF, 2016b)។

ទោះជាយ៉ាងនេះក្តី នៅមានប្រជាពលរដ្ឋដែលបាត់បង់ឱកាសជាច្រើនដែលកំពុងស្ថិតនៅក្រោយការអភិវឌ្ឍ។

ចាំបាច់ត្រូវមានការធានាយ៉ាងណាឱ្យមានការបែងចែកផលដែលបានពីការអភិវឌ្ឍ ឱ្យប្រកបដោយសមធម៌ និងធានាយ៉ាងណាឱ្យមានការចូលរួមពីស្ត្រីជាពិសេស។

### និន្នាការសង្គម-ប្រជាសាស្ត្រ » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៣




ភាគរយនៃចំណាកស្រុកតាមទិសដៅ (WFP, 2017f)

ការកើនឡើងនូវចំនួនប្រជាជនដែលរស់នៅក្នុងទីក្រុងដោយសារការធ្វើចំណាកស្រុកពីតំបន់ជនបទ ក៏មានភាពពាក់ព័ន្ធគួរឱ្យកត់សម្គាល់ផ្នែកគោលនយោបាយផងដែរ។

ស្ត្រីបន្តជួបប្រទះនឹង អសមធម៌ក្នុងការទទួលបានសេវាសង្គម ដោយសារបញ្ហានៃភាពក្រីក្រ ពាក់ព័ន្ធនឹងយេនឌ័រ។

បញ្ហានានាដូចជា ការអប់រំនៅមានកម្រិត កង្វះការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងអំណាចធ្វើសេចក្តីសម្រេចចិត្ត ការជួញដូរមនុស្ស ការធ្វើចំណាកស្រុក អំពើហិង្សាយេនឌ័រ លទ្ធភាពតិចតួចក្នុងការទទួលបានធនធានសម្រាប់ផលិតកម្ម និងការផ្តល់តម្លៃទាបដល់ការរួមចំណែករបស់ស្ត្រី គឺជាកត្តាចម្បង ដែលបង្កផលប៉ះពាល់ដល់សន្តិសុខស្បៀងរបស់ពួកគេ។

### និន្នាការបច្ចេកវិទ្យា » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៤




ទិដ្ឋភាពរួមនៃស្ថានភាពប្រព័ន្ធផ្សព្វផ្សាយក្នុងខេត្តរតនគិរី ព្រៃវែង និងភ្នំពេញ (BBC Media Action, 2014)

នៅកម្ពុជា ការប្រើប្រាស់វិទ្យុ និងទូរទស្សន៍ ដើម្បីទទួលបានព័ត៌មាន មានការថយចុះ ហើយទន្ទឹមគ្នានេះ ការប្រើប្រាស់អ៊ីនធឺណេត និងទូរសព្ទដៃមានការកើនឡើង។

មានឱកាសក្នុងបង្កើតនូវប្រព័ន្ធព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភពីប្រភពដែលអាចជឿទុកចិត្តបាន ដោយសារប្រជាពលរដ្ឋកាន់តែយល់ដឹងច្រើនអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។

### និន្នាការបរិស្ថាន » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៥

ប្រជាពលរដ្ឋក្រីក្រនៅជនបទ ប្រមាណ ៨០% ពឹងអាស្រ័យលើបរិស្ថានធម្មជាតិ និងកសិកម្ម សម្រាប់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ (CIF, 2016)។

គម្របព្រៃឈើបានថយចុះពីប្រមាណ ៦០% ក្នុងឆ្នាំ ២០០៦ មកនៅតិចជាង ៤៧% ក្នុងឆ្នាំ ២០១៤ ហើយព្រៃឈើដែលនៅសេសសល់ត្រូវប្រឈមនឹងការកាប់បំផ្លាញ (MoE, 2016)។

ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ហើយក្នុងពេលជាមួយគ្នា នៅតែអាចធានាបាននូវការអនុវត្តវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនាពេលអនាគត។

ដើម្បីកាត់បន្ថយផលប៉ះពាល់ និងការខាតបង់ដោយគ្រោះមហន្តរាយៈ កែលម្អហេដ្ឋារចនាសម្ព័ន្ធដែលធន់ទ្រាំទៅនឹងទឹកជំនន់ ធានាឱ្យមានស្តង់ដារអប្បបរមាសម្រាប់ការសាងសង់សំណង់នានា និងធានាឱ្យមានការប្រើប្រាស់ផែនការទីក្រុង ដើម្បីបង្កើនភាពធន់ទ្រាំ (FAO, et al., 2016; UNDP, 2014)។

# ការវិភាគអំពីក្របខណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

## និន្នាការអំពីភាពមានស្បៀង » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៦



ផលិតកម្មដំណាំឧស្សាហកម្ម

ទោះបីជាផលិតកម្មស្រូវ/អង្ករមានការកើនឡើងក៏ដោយ ពិពិធកម្មដំណាំដទៃទៀតនៅមានកម្រិតមួយតិចតួចនៅឡើយ

នៅក្នុងនិន្នាការនៃរបបអាហារតាមគ្រួសារ បាយ/អង្ករនៅតែជាអាហារសំខាន់ជាងគេក្នុងរបបអាហារ បើទោះជាចំណីស្បៀងអាហារនៅតាមទីផ្សារមានច្រើនក៏ដោយ។



បញ្ហាកង្វះអាហារូបត្ថម្ភ ២០០៤-២០១៤
(FAO, 2017b; NIS, 2005, 2009b, 2014)

### កសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ

«អាហារដែលមានភាពប្រសើរសម្រាប់អនាគត» ពោលគឺអាហារដែលសំបូរអាហារូបត្ថម្ភ ធន់ទ្រាំនឹងអាកាសធាតុ មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមាននៅក្នុងស្រុក និងការធ្វើកសិកម្មចម្រុះ (ដូចជា ដំណាំចម្រុះ ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រី) អាចបង្កើនពិពិធភាពនៃអាហារបាន (FAO, 2017)។

## និន្នាការអំពីការទទួលបានស្បៀង » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៧

បើទោះបីជាអត្រានៃភាពក្រីក្រមានការថយចុះគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ ប្រជាពលរដ្ឋកម្ពុជាមួយភាគធំ បានងើបចេញផុតពីបន្ទាត់នៃភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ដែលធ្វើឱ្យពួកគាត់ជាច្រើនងាយរងគ្រោះ ប្រសិនបើមានវិបត្តិនានាកើតមានឡើង (World Bank, 2013)។



ចំណែកនៃប្រាក់ចំណូលប្រចាំគ្រួសារទៅតាមចំណែកបញ្ចភាគ (WFP, 2016)

ប្រជាពលរដ្ឋដែលក្រីក្រច្រើនជួបនឹងផលប៉ះពាល់ជាអវិជ្ជមាននៅពេលដែលមានវិបត្តិនានាកើតឡើង ដូចជានៅពេលដែលមានជំងឺឈឺថ្កាត់ ជាដើម។ ក្រៅពីកង្វះប្រាក់ចំណូលដើម្បីបំពេញតម្រូវការរបស់ខ្លួន ពួកគេក៏ពុំមានលទ្ធភាពទទួលបានសេវាថែទាំសុខភាព ឬបន្តឱ្យកូននៅរៀនដែរ (UNDP, 2016)។



ភាគរយនៃប្រជាជនបែងចែកតាមប្រាក់ចំណូលក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ (FAO et al., 2016)

## និន្នាការអំពីការបីតស្រូបស្បៀង » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៨




ទោះបីជាមាននិន្នាការវិជ្ជមានក៏ដោយ បញ្ហាអាហារូបត្ថម្ភបន្តនាំឱ្យមានការខូចខាតចំពោះការអភិវឌ្ឍចំណេះដឹង និងកាយសម្បទារបស់កុមារ ដែលរួមចំណែកធ្វើឱ្យពួកគេមានប្រាក់ឈ្នួលទាប និងបាត់បង់ផលិតភាព នៅពេលពួកគេក្លាយជាមនុស្សពេញវ័យ (NIS et al., 2001, 2006, 2011, 2015)។

កម្ពុជាបានផ្លាស់ប្ដូរទម្លាប់ទៅទទួលទានអាហារស្រាប់ដែលងាយស្រួល ហើយកត្តានេះបង្កឱ្យមាននិន្នាការកំណើននៃភាពធាត់ជ្រុល និងបង្កើនហានិភ័យនៃការកើតមានជំងឺមិនឆ្លង (MoH, 2013)។

គន្លឹះដើម្បីពង្រឹងការវិនិយោគលើធនធានមនុស្សគឺ តាមរយៈការអន្តរាគមន៍អាហារូបត្ថម្ភផង និងការអប់រំផង។




## និន្នាការអំពីស្ថិរភាពស្បៀង » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៩

កម្ពុជាស្ថិតក្នុងលំដាប់ថ្នាក់ទី ៩ ដែលងាយរងគ្រោះទៅនឹងគ្រោះធម្មជាតិ ដោយសារសមត្ថភាពបន្សាំ និងសមត្ថភាពទប់ទល់របស់ប្រជាពលរដ្ឋ ក៏ដូចជាប្រទេសទាំងមូល រួមទាំងវចនាសម្ព័ន្ធ ដើម្បីបង្ការ និងកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយគ្រោះមហន្តរាយ នៅមានកម្រិតនៅឡើយ (Garschagen, et al., 2016)។



ផលប៉ះពាល់នៃបាតុភូត អែលនីញូ ទៅលើហិរញ្ញវត្ថុរបស់គ្រួសារ (FAO et al., 2016)

ដើម្បីគាំទ្រដល់ការកាត់បន្ថយហានិភ័យ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងត្រៀមបង្ការ និងឆ្លើយតបក៏ដូចជាការប្រមូល វិភាគទិន្នន័យ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹង ភាពងាយរងគ្រោះការពិនិត្យតាមដាន និងការផ្ដល់ព័ត៌មានអំពីអាកាសធាតុ និងតម្លៃទំនិញ ធ្វើយ៉ាងណាដើម្បីបង្កើនការយល់ដឹងអំពីវិបត្តិដែលអាចកើតមាន និងផ្ដល់នូវការតម្រង់ទិសដល់អ្នកតាក់តែងគោលនយោបាយ (CARD, 2017b)។

# ការវិភាគអំពីក្របខណ្ឌនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

## ដំណើរឆ្ពោះទៅកាន់របៀបវារៈឆ្នាំ២០៣០ » កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី១០




### មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ

ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តម្រូវឱ្យប្រជាពលរដ្ឋគ្រប់រូប នៃគ្រប់ទីតាំងភូមិសាស្ត្រ លក្ខណៈប្រជាសាស្ត្រ យេនឌ័រ ស្ថានភាពសង្គមសេដ្ឋកិច្ច វប្បធម៌ ឬជាតិពន្ធទទួលបានភាគផលស្មើៗគ្នាពីកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។

"ស្ថានភាពទ្រព្យសម្បត្តិ គឺជាកត្តាសង្គម-សេដ្ឋកិច្ចសំខាន់ជាងគេ ដែលពាក់ព័ន្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភ ហើយស្ថានភាពអាហារូបត្ថម្ភរបស់កុមារមានទំនាក់ទំនងខ្លាំងជាមួយនឹងស្ថានភាពអាហារូបត្ថម្ភរបស់ម្ដាយពួកគេ" (Grefeuille et al., 2016)។

### អាហារូបត្ថម្ភជាចលករពន្លឿនគោលដៅ

ស្ថានភាពអាហារូបត្ថម្ភដ៏ប្រសើរបំផុតមានសារៈសំខាន់ណាស់ ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព... ចាំបាច់ត្រូវមានការប្រើប្រាស់អភិក្រមសន្តិសុខអាហារូបត្ថម្ភពហុវិស័យ ដើម្បីសម្រេចជោគជ័យ (SUN-CSA, 2017)។

# សេចក្តីសង្ខេបអំពី កត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់ពិចារណា

ការវិភាគលើធាតុផ្សំដែលពាក់ព័ន្ធក្នុងបរិបទដែលមានឥទ្ធិពលលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ត្រូវបានធ្វើឡើងដោយប្រើប្រាស់សសរស្តម្ភទាំងប្រាំមួយនៃ ក្របខ័ណ្ឌ PESTLE ពោលគឺ នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន)។ ការវិភាគនេះបានកំណត់នូវកត្តាជាយុទ្ធសាស្ត្រ ដូចខាងក្រោម ដែលត្រូវយកមកធ្វើការ ពិចារណា ដើម្បីផ្តល់ជាព័ត៌មានសម្រាប់រៀបចំសកម្មភាព និងយុទ្ធសាស្ត្រនាពេលអនាគតជុំវិញបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ៖

- **នយោបាយ និងច្បាប់** • ពិចារណាលើក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ ដើម្បីធានាយ៉ាងណាឱ្យរាល់ឯកសារយុទ្ធសាស្ត្រទាំងអស់ ត្រូវបានតម្រឹមឱ្យស្របគ្នា ដោយដាក់ចេញនូវផែនការច្បាស់លាស់សម្រាប់អនុវត្ត និងពង្រឹងការអនុវត្ត ដូចជាការកៀងគរធនធាន ការរៀបចំអភិបាលកិច្ច ព្រមទាំងសមត្ថភាពពិនិត្យតាមដាន និងប្រមូលទិន្នន័យ។ • ចាំបាច់ត្រូវមានការកៀងគរថវិកាឱ្យបានច្រើនជាងមុនពីប្រភពសាធារណៈនិងប្រភពឯកជនព្រមទាំងត្រូវមានការតម្រឹមដំណើរការរៀបចំផែនការ និងថវិកាឱ្យកាន់តែស្របគ្នាតាមរយៈអភិក្រមថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា។ • ប្រើប្រាស់កិច្ចសហប្រតិបត្តិការតាមរយៈក្រុមការងារបច្ចេកទេស និងបណ្តាញពង្រីកអាហារូបត្ថម្ភ ជាមូលដ្ឋានរឹងមាំសម្រាប់ពង្រីកការសម្របសម្រួលឱ្យដល់ថ្នាក់ក្រោមជាតិ ហើយក្នុងពេលជាមួយគ្នាពង្រីកភាពជាដៃគូ ដើម្បីកៀងគរធនធាន និងជំនាញឯកទេសបន្ថែមទៀត។
- **សេដ្ឋកិច្ច** • ផ្តោតការយកចិត្តទុកដាក់លើបញ្ហាអសមធម៌ និងលើកកម្ពស់កំណើនបរិយាប័ន្នក្នុងការឈានទៅសម្រេចចក្ខុវិស័យ នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ដោយមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ។
- **សង្គម-ប្រជាសាស្ត្រ** • វិនិយោគលើការកសាងសមត្ថភាព ដូចជា ការផ្តោតការយកចិត្តទុកដាក់លើក្មេងជំទង់ និងសម្រេចនូវលទ្ធផលផ្នែកអាហារូបត្ថម្ភ។ • កំណើនការធ្វើចំណាកស្រុកដ៏ឆាប់រហ័ស តម្រូវឱ្យមានការពិនិត្យតាមដានលើផលប៉ះពាល់របស់វា។ • ចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់លើបញ្ហាអតុល្យភាពយេនឌ័រ។
- **បច្ចេកវិទ្យា** • ប្រើប្រាស់ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងការមានបច្ចេកវិទ្យា ដើម្បីបង្កើត និងបង្កភាពងាយស្រួលដល់ការទទួលបានព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភពីប្រភពដែលអាចជឿទុកចិត្តបាន។
- **បរិស្ថាន** • អនុវត្តគោលនយោបាយដើម្បីឈានទៅគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ក្រៅពីនេះ មានការវិភាគដោយប្រើប្រាស់សសរស្តម្ភទាំងបួននៃ ក្របខ័ណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពោលគឺ ភាពមានស្បៀងអាហារ ការទទួលបានស្បៀងអាហារ ការបឺតស្រូបស្បៀងអាហារ និងស្ថិរភាពស្បៀងអាហារ។ ការវិភាគនេះរកឃើញនូវកត្តាដែលត្រូវពិចារណាបន្ថែមទៀតដូចខាងក្រោម៖

- **ភាពមានស្បៀង** • ផ្តោតការយកចិត្តទុកដាក់លើគុណភាព ពិពិធភាព ឬភាពចម្រុះ ភាពធន់ទ្រាំ និងការគិតគូរពីអាហារូបត្ថម្ភ ក្នុងការធ្វើកសិកម្ម។
- **ការទទួលបានស្បៀង** • ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងការបន្តកាត់បន្ថយភាពក្រីក្រ បង្កើនការផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់សមធម៌នៃការទទួលបានស្បៀង។ • អនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម ដោយផ្សារភ្ជាប់ទំនាក់ទំនងឱ្យបានជិតស្និទ្ធជាមួយនឹងការងារសន្តិសុខស្បៀង និងអាហារូបបត្ថម្ភ។
- **ការបឺតស្រូបស្បៀង** • ពង្រឹងការឆ្លើយតបពហុវិស័យ ដូចជា ការបង្កើនការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបទជុំវិញបញ្ហាអាហារូបត្ថម្ភ។ • បង្កើនការយកចិត្តទុកដាក់ចំពោះការផ្លាស់ប្តូររបបអាហារ ការកើនឡើងនូវបញ្ហាលើសទម្ងន់ និងផលប៉ះពាល់នៃជំងឺមិនឆ្លង។
- **ស្ថិរភាពស្បៀង** • ការពារផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលសម្រេចបានកន្លងមកពីវិបត្តិធម្មជាតិ និងវិបត្តិសេដ្ឋកិច្ចតាមរយៈការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចគាំពារសង្គម ដែលឆ្លើយតបចំពោះវិបត្តិនានា។

ជាចុងក្រោយ ការឆ្លុះបញ្ចាំងលើក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈឆ្នាំ ២០៣០ បង្ហាញបន្ថែមនូវកត្តាយុទ្ធសាស្ត្រមួយចំនួនទៀត ដែលត្រូវយកមកធ្វើការពិចារណា៖

- **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈឆ្នាំ ២០៣០** • ការមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ អំពាវនាវឱ្យមានការវិភាគស៊ីជម្រៅលើទិន្នន័យសន្តិសុខស្បៀង និងអាហារូបបត្ថម្ភ ដើម្បីកំណត់រកភាពងាយរងគ្រោះរបស់ក្រុមផ្សេងៗគ្នា។ • ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ពិសេសចំពោះការរៀបចំ និងការកំណត់គោលដៅនៃយុទ្ធសាស្ត្រអន្តរាគមន៍ ដោយផ្តោតការយកចិត្តទុកដាក់លើអ្នកដែលស្ថិតនៅក្រោយការអភិវឌ្ឍ។ • ដោយសារតែអាហារូបត្ថម្ភ និងចំណុចដៅដែលត្រូវបានដាក់ចេញនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង១២ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធការវិនិយោគលើអាហារូបត្ថម្ភគឺជាវិស័យស្នូល(ជាជាងជាវិស័យរួមចំណែក)សម្រាប់ក្របខ័ណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់កម្ពុជា ដែលអាចផ្តល់នូវភាគលាភយ៉ាងច្រើន ក្នុងការឈានទៅសម្រេចរបៀបវារៈឆ្នាំ ២០៣០។

# ១. សេចក្តីផ្តើម

សិទ្ធិទទួលបានស្បៀងអាហារ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ត្រូវបានបញ្ចូលទៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ ១៩៦៦ ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ និងទទួលបានការគាំទ្រពីកិច្ចប្រជុំកំពូល និងគំនិតផ្តួចផ្តើម ដែលបន្តរៀបចំដោយអង្គការសហប្រជាជាតិ រួមទាំងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាពិសេសគោលដៅទី២ ដែលមានគោលបំណងលុបបំបាត់ភាពអត់ឃ្លាន (ប្រអប់ទី ១)។

ប្រទេសកម្ពុជាប្តេជ្ញាចិត្តលុបបំបាត់ បញ្ហាអសន្តិសុខស្បៀង និងភាពអត់ឃ្លាន។ កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីលើកកម្ពស់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការប្រើប្រាស់អភិក្រមពហុវិស័យ ដើម្បីឆ្លើយតបចំពោះបញ្ហាអាហារូបត្ថម្ភ និងភាពក្រីក្រ រៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងខិតខំប្រឹងប្រែងបញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងរបៀបវារៈផ្សេងៗ។ ការលើកកម្ពស់សន្តិសុខស្បៀង គឺជាអាទិភាពអភិវឌ្ឍន៍ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពរបស់រដ្ឋាភិបាល ដែលពង្រឹងការចូលរួមរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ អាហារូបត្ថម្ភ និងកិច្ចគាំពារសង្គម និងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ដែលត្រូវបានរៀបចំឡើងសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ និងបានលើកឡើងពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះក្នុងគ្រប់គោលនយោបាយតាមវិស័យទាំងអស់។ ដើម្បីធានាឱ្យមានវេទិកាសម្រាប់អនុវត្តសកម្មភាពពហុវិស័យរួមគ្នាក្នុងគោលបំណងលើកកម្ពស់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រាជរដ្ឋាភិបាលកម្ពុជាបានចាត់តាំងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកកម្ម និងជនបទឱ្យធ្វើការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះឡើង។

> សិទ្ធិទទួលបានស្បៀងអាហារ ទទួលស្គាល់ថា ការបញ្ចប់ភាពអត់ឃ្លាន គឺជាការធានាឱ្យមានការទទួលបានស្បៀងអាហារ ដែលមានអាហារូបត្ថម្ភសម្រាប់ជនដែលងាយរងគ្រោះបំផុត បង្កើនផលិតកម្មកសិកម្មតាមរយៈការធានានូវចីរភាព និងភាពធន់ទ្រាំនៃប្រព័ន្ធស្បៀងអាហារ និងការឆ្លើយតបចំពោះមូលហេតុពាក់ព័ន្ធនឹងសមាសភាគចម្រុះ ដែលនាំឱ្យមានបញ្ហាអាហារូបត្ថម្ភកើតមានឡើង ដូចជា មូលហេតុដែលពាក់ព័ន្ធនឹងសុខភាព និងអនាម័យជាដើម។

ក្នុងឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសចាប់ផ្តើមអនុវត្ត យុទ្ធសាស្ត្រ ជាតិស្តី ពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ជាមួយនឹងគោលដៅ "ត្រឹមឆ្នាំ ២០១៨ ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សម្គាល់ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ មានផលិតភាពខ្ពស់"។ គោលដៅនេះគឺស្របគ្នាជាមួយនឹងនិយមន័យសន្តិសុខស្បៀង ដែលត្រូវបានព្រមព្រៀងគ្នាក្នុងកិច្ចប្រជុំកំពូលពិភពលោកស្តីពីស្បៀងអាហារក្នុងឆ្នាំ ១៩៩៦ ដែលកំណត់ថា សន្តិសុខស្បៀងកើតមាននៅពេលដែលជនគ្រប់រូបនៅគ្រប់ពេលទាំងអស់មានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ច ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានរបស់ពួកគេ ដើម្បីឱ្យជីវិតរបស់ពួកគេសកម្ម និងមានសុខភាពល្អ។ និយមន័យនេះ ត្រូវបានកំណត់ចេញពីសសរស្តម្ភចំនួនបួននៃសន្តិសុខស្បៀង ពោលគឺ (១) ភាពមានស្បៀង (២) ការទទួលបានស្បៀងគ្រប់គ្រាន់ (៣) ការបឺតស្រូបស្បៀងបានត្រឹមត្រូវ ព្រមទាំង (៤) ស្ថិរភាពនៃសសរស្តម្ភ ទាំងបីខាងលើ។

ដើម្បីសម្រេចគោលបំណងសន្តិសុខស្បៀង ចាំបាច់ត្រូវមានការសម្រេចបាននូវសមាសភាគទាំងបួនខាងលើនេះក្នុងពេលស្របគ្នា។ដូច្នេះការវិភាគស្ថានភាពនេះប្រើប្រាស់ទស្សនទានខាងលើជាក្របខ័ណ្ឌគោល ហើយក៏បង្ហាញពីទំនាក់ទំនងជាមួយនឹងក្របខ័ណ្ឌនឹងការវិភាគដែលពាក់ព័ន្ធផ្សេងទៀតផងដែរ។

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភជាយុទ្ធសាស្ត្រអន្តរវិស័យ ដែ លផ្តល់ការគាំទ្រដល់យុទ្ធសាស្ត្រ ដែលមានស្រាប់តាមវិស័យដទៃទៀត និងជាឧបករណ៍ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវការសម្របសម្រួល និងការសហការ ដើម្បីលើកកម្ពស់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះ មានគោលបំណងចំនួនបី ដែលក្រោមគោលបំណងនីមួយៗ មានការដាក់ចេញសកម្មភាពជាអាទិភាពផ្តោតលើសសរស្តម្ភសន្តិសុខស្បៀង ដើម្បីសម្រេចគោលបំណងទាំងបីនេះ៖

១ គោលបំណងទី ១៖ បង្កើនភាពមានស្បៀង និងទទួលបានស្បៀងតាមរយៈផលិតកម្ម កសិកម្ម និងការចិញ្ចឹមសត្វដែលកាន់តែមានភាពចម្រុះ និងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារ ដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។
២ គោលបំណងទី ២៖ ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និងការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍមនុស្ស និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។
៣ គោលបំណងទី ៣៖ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀងសម្រាប់គ្រួសារ ដែលមានបញ្ហាសន្តិសុខស្បៀង។

យុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទទួលបានការគាំទ្រពីផែនទីបង្ហាញផ្លូវ សម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០ និងការប្តេជ្ញាចិត្ត ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ២ស្តីពីការលុបបំបាត់ភាពអត់ឃ្លាន ក្រោមផែនការសកម្មភាពជាតិកាត់បន្ថយភាពអត់ឃ្លាននៅកម្ពុជា ២០១៦-២០២៥។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាតិនេះ ត្រូ វបានធ្វើឡើងតាមរយៈការពិនិត្យឡើងវិញលើសូចនាករ ដែលត្រូវបានដាក់ចេញក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សូចនាករពិនិត្យតាមដានរួមគ្នា នឹងការធ្វើមូលដ្ឋាននីយកម្មចំណុចដៅ និងសូចនាករនានានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដោយសារតែនឹងមានការពិនិត្យឡើងវិញ និងកែសម្រួលយុទ្ធសាស្ត្រសំខាន់ៗជាច្រើន ដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ នេះ មានគោលបំណងឆ្លុះបញ្ចាំងពីសមិទ្ធផលដែលសម្រេចបានកន្លងមក វិភាគលើស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភបច្ចុប្បន្ននៅកម្ពុជា និងជាការត្រៀមរៀបចំយុទ្ធសាស្ត្រដែលនឹងត្រូវដាក់ចេញនាពេលខាងមុខនេះ។ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនេះ មានការប្រមូលព័ត៌មាន តាមរយៈការអង្កេត អំពីសមិទ្ធផលដែលសម្រេចបានកន្លងមកការពិនិត្យលើឯកសារពាក់ព័ន្ធ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ និងការរៀបចំកិច្ចពិគ្រោះយោបល់ជាផ្លូវការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឯកសារបច្ចុប្បន្នភាពស្ថានភាពនេះមានគោលបំណងបង្ហាញពីទិដ្ឋភាពរួមនៃស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភបច្ចុប្បន្ននៅកម្ពុជា ដោយព្យាយាមបង្ហាញពីចំនុចដែលបានផ្លាស់ប្តូរ កត្តាសំខាន់ៗដែលនាំឱ្យមានការផ្លាស់ប្តូរនេះ និងផ្តល់ជាព័ត៌មានសម្រាប់ពិចារណាលើការដាក់ចេញទិសដៅយុទ្ធសាស្ត្រនាពេលអនាគត។

2 ZERO HUNGER

**គោលដៅទី២នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព៖** បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភកាន់តែប្រសើរជាងមុន និងលើកកម្ពស់ការធ្វើកសិកម្មប្រកបដោយចីរភាព។

២.១ ត្រឹមឆ្នាំ ២០៣០ បញ្ចប់ភាពអត់ឃ្លាននិងធានាថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសជនក្រីក្រ និងប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំង កុមារទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ នៅគ្រប់រដូវ

២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃបញ្ហាអាហារូបត្ថម្ភរួមទាំងការសម្រេចបាននៅឆ្នាំ២០២៥នូវចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិសក្រិន និងភាពស្គមស្គាំងរបស់កុមារក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងចាស់ជរា។

២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃផលិតផលកសិកម្ម និងចំណូលរបស់ផលិតករធុនតូច ជាពិសេសស្ត្រី ជនជាតិដើមភាគតិច គ្រួសារកសិករ អ្នកចិញ្ចឹមសត្វ និងអ្នកនេសាទ រួមទាំងតាមរយៈការធានា និងការទទួលបាននូវសមភាពដីធ្លី ធនធាន និងធាតុចូលសម្រាប់ផលិតកម្មដទៃទៀត ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារ និងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។

២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងដែលមានចីរភាព អនុវត្តកសិកម្មដែលធន់ទ្រាំនឹងបម្រែបម្រួលអាសធាតុដែលអាចបង្កើនផលិតភាព និងផលិតកម្មជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី និងពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងគ្រោះមហន្តរាយដទៃទៀត និងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវគុណភាពដី។

២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែន នៃគ្រាប់ពូជ ដំណាំដាំដុះ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃ ដែលពាក់ព័ន្ធ ដូចជា តាមរយៈការគ្រប់គ្រងសមស្របលើការបង្កើតធនាគារគ្រាប់ពូជ និងការធ្វើពិពិធកម្មគ្រាប់ពូជ នៅថ្នាក់ជាតិ តំបន់ និង អន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយ យុត្តិធម៌ និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែន និងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ។

ប្រអប់ទី ១៖ គោលដៅទី២នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ដែលមានគោលបំណងលុបបំបាត់ភាពអត់ឃ្លាន

# ២. ការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ឯកសារស្តីអំពីស្ថានភាពបច្ចុប្បន្ននេះ បង្ហាញពីទិដ្ឋភាពទូទៅនៃ និន្នាការសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាដោយធ្វើការពិចារណាលើក្របខ័ណ្ឌជាច្រើន។ ដោយសារតែបរិបទ និងនិន្នាការសន្តិសុខស្បៀងនិងអាហារូបត្ថម្ភមានលក្ខណៈទូលំទូលាយការវិភាគនេះប្រើប្រាស់ក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (ហៅកាត់ថា PESTLE) ដើម្បីកំណត់ពីទិដ្ឋភាពទូទៅនៃនិន្នាការនៅកម្រិតម៉ាក្រូ ដែលមានឥទ្ធិពលលើបរិបទសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ បន្ទាប់មកការពិចារណាលើនិន្នាការជាក់លាក់ ដែលពាក់ព័ន្ធនឹងស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានធ្វើឡើងដោយប្រើប្រាស់ក្របខ័ណ្ឌសសរស្តម្ភទាំងបួននៃសន្តិសុខស្បៀង ពោលគឺ ភាពមានស្បៀង ការទទួលបានស្បៀង ការបឺតស្រូបស្បៀង និងស្ថិរភាពស្បៀង។ ពាក់ព័ន្ធនឹងការបឺតស្រូបស្បៀង ក៏មានការពិចារណាពីក្របខ័ណ្ឌទស្សនទានស្តីពីបញ្ហាអាហារូបត្ថម្ភរបស់ UNICEF ផងដែរ ដើម្បីផ្តល់ទម្ងន់បន្ថែមលើការវិភាគអាហារូបត្ថម្ភ។ ចុងក្រោយ ការវិភាគនេះត្រូវបានធ្វើឡើងដោយគិតពិចារណាពីរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ដែលបានកំណត់នូវបរិបទសម្រាប់ការរៀបចំឯកសារគោលនយោបាយថ្មីៗ និងសម្រួចការរៀបចំយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនាពេលអនាគត។

## ២.១ ក្របខ័ណ្ឌ PESTLE

ការវិភាគ PESTLE បានបង្ហាញឱ្យឃើញពីស្ថានភាពទូទៅនៃនិន្នាការខាងក្រៅ ក្នុងវិស័យ នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន ដែលមានទំនាក់ទំនងជាមួយនឹងបរិបទសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការវិភាគដោយប្រើប្រាស់ក្របខ័ណ្ឌនេះ គឺជាការវិភាគដែលមានលក្ខណៈអព្យាក្រឹតដោយធ្វើការកត់សម្គាល់ពីនិន្នាការ ដែលកើតមានក្នុងវិស័យទាំងនេះ (តារាងទី ១) ដែលគេអាចយកមកពិនិត្យដើម្បីដឹងពីកាលានុវត្តភាព ឬហានិភ័យ ភាពបន្ទាន់ និងសារៈសំខាន់ សម្រាប់កំណត់ពីរបៀបឆ្លើយតបចំពោះនិន្នាការទាំងនេះ ដូចជា ត្រូវចាប់យកកាលានុវត្តភាពទាំងនេះ ឬកាត់បន្ថយហានិភ័យ ជាដើម។

តារាងទី ១៖ ឧទាហរណ៍ដែលបង្ហាញពីការវិភាគ PESTLE

| | |
|---|---|
| នយោបាយ | កត្តានយោបាយសំខាន់ៗ (ឧទាហរណ៍ ការដាក់ចេញគោលនយោបាយ ការផ្លាស់ប្តូរគោលនយោបាយដោយសារការបោះឆ្នោត។ល។) និន្នាការសំខាន់ៗពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍ និងវិស័យមនុស្សធម៌ (ឧទាហរណ៍ វត្តមាន និងសកម្មភាពរបស់ទីភ្នាក់ងារសហប្រជាជាតិ/អង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិល និន្នាការនៃការផ្តល់ថវិការបស់អ្នកផ្តល់ជំនួយ លក្ខណៈនៃកម្មវិធីដែលត្រូវបានផ្តល់ ការសម្របសម្រួលតាមវិស័យ។ល។) |
| សេដ្ឋកិច្ច | កត្តាម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ (ឧទាហរណ៍ និន្នាការចំណូល និន្នាការការងារ និងមុខរបរ របទាសម្ព័ន្ធសេដ្ឋកិច្ច វិស័យដែលមានកំណើន/ថយចុះ និន្នាការតម្លៃ/អតិផរណា។ល។) |
| សង្គម | កត្តាសង្គម-ប្រជាសាស្ត្រសំខាន់ៗ (ឧទាហរណ៍ របទាសម្ព័ន្ធប្រជាជន របាយប្រជាជនតាមទីតាំងភូមិសាស្ត្រ ការទទួលបានសេវាជាមូលដ្ឋាន សមធម៌ របទាសម្ព័ន្ធនៃវិស័យសាធារណៈ។ល។) |
| បច្ចេកវិទ្យា | កត្តាបច្ចេកវិទ្យាសំខាន់ៗ (ឧទាហរណ៍ ការទទួលបាន និងការប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗ និងព័ត៌មាន ការមានសេវាបច្ចេកវិទ្យា ឧទាហរណ៍ ការប្រកាសអាសន្នដោយប្រើប្រព័ន្ធឌីជីថល ។ល។) |
| ច្បាប់ | កត្តាច្បាប់សំខាន់ៗ (ឧទាហរណ៍ វត្តមាន/ការពង្រឹងការអនុវត្តកិច្ចគាំពារសង្គម ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។ល។) |
| បរិស្ថាន | កត្តាបរិស្ថានសំខាន់ៗ (ឧទាហរណ៍ ការមានធនធានធម្មជាតិ ការគ្រប់គ្រងធនធាន ការរេចរិលបរិស្ថាន គ្រោះមហន្តរាយធម្មជាតិ។ល។) |

## ២.២ ក្របខ័ណ្ឌសន្តិសុខស្បៀង

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះប្រើប្រាស់សសរស្តម្ភទាំងបួននៃសន្តិសុខស្បៀង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក កាលពីឆ្នាំ ១៩៩៦ ដែលកំណត់និយមន័យសន្តិសុខស្បៀងថាជាស្ថានភាព "នៅពេលដែលមនុស្សគ្រប់រូប នៅគ្រប់ពេលវេលាទាំងអស់មានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ ព្រមទាំងចំណង់ចំណូលចិត្ត ក្នុងការទទួលទានអាហាររបស់ពួកគេ ដើម្បីឱ្យជីវិតរបស់ពួកគេមានភាពសកម្ម និងសុខភាពល្អ"។ ស្ថានភាពសន្តិសុខស្បៀងកើតចេញពីការមានស្បៀងគ្រប់គ្រាន់ និងការទទួលបានស្បៀងនៅគ្រប់ពេលវេលា

ទាំងអស់ ព្រមទាំងការបឺតស្រូបស្បៀងឱ្យបាន ត្រឹមត្រូវ (FAO, 2006) (រូបភាពទី ១)។

១ ភាពមានស្បៀង៖ ពិចារណាលើបញ្ហាជុំវិញនិន្នាការផលិតកម្ម និងការនាំចូល-នាំចេញ។

២ ការទទួលបានស្បៀង៖ ពិចារណាលើបញ្ហាជុំវិញបម្រែបម្រួលចំណូល និងបំណុលរបស់គ្រួសារ ដែលអាចមានឥទ្ធិពលលើ ការទទួលបានស្បៀង វិសមភាព និងភាពងាយរងគ្រោះ ដូចជាភាពខុសប្លែកគ្នារវាង ប្រជាជននៅតំបន់ប្រជុំ និងជនបទ ប្រភេទចំណូលរួមទាំងការធ្វើចំណាកស្រុក និងផលប៉ះពាល់នៃគោលនយោបាយមូលដ្ឋាននីយកម្ម។



រូបភាពទី ១៖ សមាសភាគនៃសន្តិសុខស្បៀង (FAO ២០០៦)

៣ ការបឺតស្រូបស្បៀង៖ ពិចារណាលើបញ្ហាជុំវិញទម្លាប់នៃការផ្តល់អាហារ និងទម្លាប់ការថែទាំ ការទទួលបានទឹក និងអនាម័យ និងសេវាថែទាំសុខភាព និងភាពពាក់ព័ន្ធលើអាហារូបត្ថម្ភ។ល។

៤ ស្ថិរភាពស្បៀង៖ ពិចារណាលើបញ្ហានានា ដូចជានិន្នាការតម្លៃ និងវិបត្តិដែលបង្កឡើងដោយគ្រោះមហន្តរាយតាមរដូវ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃការមានស្បៀង ការទទួលបានស្បៀង និងការបឺតស្រូបស្បៀង។

ដើម្បីសម្រេចគោលបំណងសន្តិសុខស្បៀង ចាំបាច់ត្រូវមានការសម្រេចបាននូវសមាសភាគទាំងបួនក្នុងពេលជាមួយគ្នា។

## ២.៣ ក្របខ័ណ្ឌទស្សនទានស្តីពីបញ្ហាអាហារូបត្ថម្ភ

សន្តិសុខអាហារូបត្ថម្ភ មិនមែនត្រឹមតែសំដៅលើសន្តិសុខស្បៀងនោះទេ។ សន្តិសុខអាហារូបត្ថម្ភ គឺជាលទ្ធផលនៃការមានសុខភាពល្អ បរិស្ថានរស់នៅដែលនាំមកនៅសុខភាពល្អ ការថែទាំបានល្អ និងសន្តិសុខស្បៀង។ ដូច្នេះសន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ គឺជាទស្សនទានពីរផ្សេងគ្នា ប៉ុន្តែមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ និងជាចំណែកនៃគ្នាទៅវិញទៅមក។ ការសម្រេចឱ្យបាននូវសន្តិសុខអាហារូបត្ថម្ភ តម្រូវឱ្យមានភាពពេញលេញនៃសមាសភាគស្បៀង សុខភាព និងការថែទាំ ក្នុងពេលទន្ទឹមគ្នា។ ចំណុចនេះត្រូវបានបង្ហាញតាមរយៈក្របខ័ណ្ឌ ទស្សនទានស្តីពីបញ្ហាអាហារូបត្ថម្ភរបស់ UNICEF (រូបភាពទី ២)។



រូបភាពទី២៖ ក្របខ័ណ្ឌទស្សនទានស្តីពីបញ្ហារូបត្ថម្ភរបស់ UNICEF (Bhutta ២០១៣)

បញ្ហាអាហារូបត្ថម្ភ សំដៅលើការកង្វះអាហារូបត្ថម្ភផង និងការលើសអាហារូបត្ថម្ភផង។ មនុស្សមានបញ្ហាអាហារូបត្ថម្ភ ប្រសិនបើរបបអាហាររបស់ពួកគេពុំបានផ្តល់កាឡូរី និងប្រូតេអ៊ីនឱ្យបានគ្រប់គ្រាន់ ដើម្បីជួយដល់ការលូតលាស់ និងការថែទាំសុខភាពរបស់ពួកគេ ឬប្រសិនបើពួកគេពុំអាចបឺតស្រូបអាហារ ដែលពួកគេទទួលទានឱ្យបានពេញលេញ ដោយសារតែពួកគេមានជំងឺ (កង្វះអាហារូបត្ថម្ភ)។ ពួកគេក៏អាចមានបញ្ហាអាហារូបត្ថម្ភផងដែរ ប្រសិនបើពួកគេបរិភោគកាឡូរីច្រើនពេក (លើសអាហារូបត្ថម្ភ)។ បញ្ហាកង្វះអាហារូបត្ថម្ភ និងការលើសទម្ងន់គឺជា "បន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភ"។

បញ្ហាកង្វះអាហារូបត្ថម្ភ បង្កឡើងដោយកត្តាជាច្រើន ដែលកើតចេញពីការរួមផ្សំគ្នានៃមូលហេតុផ្ទាល់ មូលហេតុប្រយោល និងមូលហេតុជាមូលដ្ឋាន។ មូលហេតុផ្ទាល់ ដូចជា ការបឺតស្រូបយកអាហារពុំបានគ្រប់គ្រាន់ ឬជំងឺ ទទួលរងឥទ្ធិពលដោយសារកត្តាប្រយោលជាច្រើន ដូចជា អសន្តិសុខស្បៀងរបស់គ្រួសារ និងពង្រឹងបន្ថែម ដោយសារមូលហេតុជាមូលដ្ឋាន ដែលបង្កឱ្យមានបញ្ហាអាហារូបត្ថម្ភមិនបានល្អ ដូចជា រចនាសម្ព័ន្ធសង្គម និងដំណើរសង្គម ដែលអាចនាំឱ្យមានភាពក្រីក្រ និងដាក់កំហិត ឬមិនផ្តល់លទ្ធភាពឱ្យប្រជាជនដែលងាយរងគ្រោះអាចទទួលបានធនធានចាំបាច់ ជាដើម។ ផ្នែកសំខាន់ដែលត្រូវផ្តោតការយកចិត្តទុកដាក់ គឺការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅក្នុងរយៈពេល ១.០០០ ថ្ងៃ ដំបូង ចាប់គិតពីពេលមានផ្ទៃពោះរហូតដល់ពេលដែលកុមារអាយុបាន ២ ឆ្នាំ ដោយសារអាហារូបត្ថម្ភខ្សត់ខ្សោយ អាចបង្កឱ្យមានការខូចខាតពេញមួយជីវិត ដែលមិនអាចស្តារឡើងវិញបាន និងដែលនាំឱ្យមានផលវិបាកនៅកម្រិតបុគ្គល សហគមន៍ និងជាតិ។ កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃអាចរួមចំណែកនាំឱ្យមានភាពក្រីក្រ ហើយក្នុងរយៈពេលវែងអាចបង្កើនហានិភ័យនៃការបាត់បង់ជីវិត និងការឈឺថ្កាត់។ ផលវិបាករយៈពេលវែងនៃបញ្ហាក្រិសក្រិនអាចមានផលប៉ះពាល់ជាអវិជ្ជមាននៅពេលពេញវ័យ ទៅលើសុខភាព ការអប់រំ និងសេដ្ឋកិច្ច ជាដើម។ កត្តាទាំងនេះត្រូវបានយកមកធ្វើការពិចារណាក្នុងផ្នែក ៤.៣ ស្តីអំពី "និន្នាការនៃការបឺតស្រូបស្បៀង" ។

គេចាំបាច់ត្រូវបែងចែកឱ្យដាច់រវាង អន្តរាគមន៍ដែលផ្តោតលើអាហារូបត្ថម្ភ និងអន្តរាគមន៍ដែលគិតគូរអំពីអាហារូបត្ថម្ភ ដើម្បីជម្នះបញ្ហាប្រឈមពាក់ព័ន្ធនឹងអាហារូបត្ថម្ភនេះ។ អន្តរាគមន៍ផ្តោតលើអាហារូបត្ថម្ភសំដៅលើអន្តរាគមន៍ទាំងឡាយណាដែលមានគោលបំណងចម្បង ដើម្បីដោះស្រាយមូលហេតុផ្ទាល់ ដែលនាំឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ ដែលប៉ះពាល់ដល់ការអភិវឌ្ឍរបស់ទារកក្នុងផ្ទៃ និងការអភិវឌ្ឍរបស់កុមារ និងសុខភាពមាតា ដូចជា ការបឺតស្រូបស្បៀង និងសារធាតុចិញ្ចឹមគ្រប់គ្រាន់ ទម្លាប់ផ្តល់អាហារផ្តល់ការថែទាំ និងចិញ្ចឹមបីបាច់កូន និងផលប៉ះពាល់នៃជំងឺឆ្លងមួយចំនួន។ ឧទាហរណ៍ដែលបង្ហាញពីអន្តរាគមន៍ផ្តោតលើអាហារូបត្ថម្ភ រួមមាន ការផ្តល់អាហារបន្ថែម ដែលផ្តោតលើក្រុមគោលដៅជាក់លាក់ ការផ្តល់អាហារបន្ថែមពីលើរបបអាហារជាប្រចាំ ការជំរុញឱ្យមានការបំបៅកូនដោយទឹកដោះម្តាយឱ្យបានល្អបំផុត ការធ្វើពិពិធកម្ម និងការបន្ថែមមីក្រូសារជាតិចិញ្ចឹម ឬការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារដែលផ្តល់ឱ្យកុមារ ការព្យាបាលបញ្ហាអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ ការបង្ការជំងឺ និងការគ្រប់គ្រងជំងឺ និងអន្តរាគមន៍អាហារូបត្ថម្ភក្នុងស្ថានភាពបន្ទាន់។ ចំណែកឯអន្តរាគមន៍ដែលគិតគូរពីអាហារូបត្ថម្ភវិញ គឺជាអន្តរាគមន៍ដែលគោលបំណងចម្បងមិនផ្តោតផ្ទាល់លើអាហារូបត្ថម្ភឡើយប៉ុន្តែជាវាមានសក្តានុពលក្នុងការបង្កើនសន្តិសុខស្បៀង របស់ក្រុមគោលដៅ។ លទ្ធផលរកឃើញដែលបង្ហាញក្នុងទស្សនាវដ្តី Lancet ស្តីពីអាហារូបត្ថម្ភមាតា និងកុមារឆ្នាំ ២០១៣ កត់សម្គាល់ពីសារៈសំខាន់នៃកម្មវិធី ដែលគិតគូរពីអាហារូបត្ថម្ភក្នុងវិស័យកសិកម្ម អប់រំ សុខភាពសាធារណៈ សុខមាលភាពសង្គម ក្នុងការឆ្លើយតបចំពោះកត្តាប្រយោលមួយចំនួនដែលនាំឱ្យមានបញ្ហាអាហារូបត្ថម្ភ (រូបភាពទី ៣)។ អន្តរាគមន៍ទាំងពីរប្រភេទនេះមានតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភ។ កត្តាសំខាន់ដែលត្រូវយកមកធ្វើការពិចារណាសម្រាប់យុទ្ធសាស្ត្រនេះគឺតើត្រូវធ្វើយ៉ាងណាដើម្បីបង្កើនអន្តរាគមន៍ផ្តោតលើអាហារូបត្ថម្ភដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ហើយក្នុងពេលជាមួយគ្នា ពង្រីកបន្ថែមទៀតនូវអន្តរាគមន៍ដែលគិតគូរពីអាហារូបត្ថម្ភ។




រូបភាពទី ៣៖ អាហាររូបត្ថម្ភ និងការអភិវឌ្ឍដែលល្អបំផុតរបស់ទារក និងកុមារ (Lancet ២០០៨)

## ការគិតគូរឡើងវិញពីសន្តិសុខស្បៀង និងសន្តិសុខអាហាររូបត្ថម្ភ – អភិក្រមប្រព័ន្ធស្បៀង

ក្របខ័ណ្ឌថ្មីដែលត្រូវបានលើកឡើង ក្នុងរបាយការណ៍ស្តីពីប្រព័ន្ធអាហាររូបត្ថម្ភ និងស្បៀងរៀបចំដោយគណៈកម្មាធិការជំនាញកម្រិតខ្ពស់ (HLPE, 2017) ទទួលបន្ទុកសន្តិសុខស្បៀង និងអាហាររូបត្ថម្ភអាចផ្តល់នូវអភិក្រមដែលកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លុះបញ្ចាំងពីបរិបទដែលកំពុងបន្តវិវត្តន៍នៅកម្ពុជា។ អភិក្រមនេះទទួលស្គាល់ថា ខណៈពេលដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបានស្បៀងឱ្យបានគ្រប់គ្រាន់ សិទ្ធិនេះនឹងមិនអាចសម្រេចបានឡើយ ប្រសិនបើពុំមានប្រព័ន្ធស្បៀងប្រកបដោយនិរន្តរភាព ដែលបង្កភាពងាយស្រួលឱ្យប្រជាពលរដ្ឋមានជម្រើសស្បៀងអាហារដែលនាំមកនូវសុខភាពល្អ និងមានចីរភាព និងធានាឱ្យមនុស្សទាំងអស់គ្នាមានសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ដោយមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ។ ប្រព័ន្ធស្បៀងនាពេលបច្ចុប្បន្ននេះបង្កផលប៉ះពាល់យ៉ាងច្រើនមកលើសុខភាពរបស់មនុស្សនិង បរិស្ថាន ខណៈពេលដែលការសម្រេចចិត្តនិងជម្រើសរបស់មនុស្ស (ជាលក្ខណៈបុគ្គល ឬជាសមូហភាពជុំវិញផលិតកម្ម និងការបរិភោគ ស្បៀងក៏អាចមានឥទ្ធិពលលើប្រព័ន្ធស្បៀង និងបង្កើនលទ្ធភាពរបស់ប្រព័ន្ធស្បៀងក្នុងការផ្តល់នូវរបបអាហារដែលនាំមកនូវសុខភាពល្អប្រកបដោយចីរភាពផងដែរ។

ក្របខ័ណ្ឌដែលត្រូវបានលើកស្នើឡើងដោយគណៈកម្មាធិការជំនាញកម្រិតខ្ពស់(HLPE)នេះមានគោលបំណងបង្ហាញឱ្យឃើញពីរបៀបដែលប្រព័ន្ធស្បៀងមានឥទ្ធិពលលើរបបអាហារ និងស្ថានភាពអាហាររូបត្ថម្ភរបស់មនុស្ស។ក្របខ័ណ្ឌនេះបង្ហាញពីសមាសភាគចំនួនបីនៃប្រព័ន្ធស្បៀងដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកនោះគឺសង្វាក់ផ្គត់ផ្គង់ស្បៀង បរិស្ថានស្បៀង និងឥរិយាបទរបស់អ្នកប្រើប្រាស់ស្បៀង។ក្របខ័ណ្ឌនេះបានរំលេចឱ្យឃើញពីតួនាទីដ៏សំខាន់នៃបរិស្ថានស្បៀង(ពោលគឺបរិបទរូបវន្ត សេដ្ឋកិច្ច នយោបាយ និងសង្គមវប្បធម៌ របស់អ្នកប្រើប្រាស់ម្នាក់ៗ ដែលកំពុងចូលរួមជាមួយ

នឹងប្រព័ន្ធស្បៀង) ក្នុងការបង្កលក្ខណៈងាយស្រួល ឱ្យអ្នកប្រើប្រាស់អាចជ្រើសរើសស្បៀង ដែលនាំមកនូវសុខភាពល្អ ប្រកបដោយចីរភាព។ ស្របគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្របខ័ណ្ឌនេះលើកស្នើនូវអាទិភាពជាក់លាក់ចំនួនពីរ ដើម្បីសម្រេចឱ្យបានស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភៈ (១) បង្កើនលទ្ធភាពរូបវន្ត និងសេដ្ឋកិច្ចក្នុងការទទួលបានរបបអាហារ ដែលនាំមកនូវសុខភាពល្អប្រកបដោយចីរភាព និង (២) ពង្រឹងព័ត៌មាន និងការអប់រំសម្រាប់អ្នកប្រើប្រាស់ស្បៀង ដើម្បីឱ្យពួកគេធ្វើការជ្រើសរើសស្បៀងដែលនាំមកនូវសុខភាពល្អ។




រូបភាពទី៤៖ ក្របខ័ណ្ឌអាហារូបត្ថម្ភ និងប្រព័ន្ធស្បៀងដែលត្រូវបានកែសម្រួល (HLPE២០១៧)

## ២.៤ របៀបវារៈ ការអភិវឌ្ឍដោយចីរភាព ឆ្នាំ ២០៣០

ក្នុងឆ្នាំ ២០១៥ មហាសន្និបាតសហប្រជាជាតិបានអនុម័តសេចក្តីសម្រេច លេខ ៧០/១ ស្តីពី “ធ្វើឱ្យមានការផ្លាស់ប្តូរក្នុងពិភពលោករបស់យើង៖ របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០” ដែលជាសំណុំគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងចំណុចដៅដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានវិសាលភាពធំធេង និងផ្តោតលើតម្រូវការរបស់មនុស្ស ដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងសកលលោកទាំងមូលដើម្បីពង្រីកបន្ថែមសមិទ្ធផលដែលសម្រេចបានក្រោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍និងផ្តោតការយកចិត្តទុកដាក់លើវិស័យទាំងឡាយណា ដែលពុំទាន់បានសម្រេចបានលទ្ធផលនៅឡើយ។ របៀបវារៈឆ្នាំ ២០៣០ ដាក់ចេញនូវចក្ខុវិស័យប្រកបដោយមហិច្ឆតា សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ។ របៀបវារៈនេះទទួលស្គាល់ថា ការលុបបំបាត់ភាពក្រីក្រក្នុងគ្រប់ទម្រង់ និងសមាសភាគទាំងអស់ គឺជាបញ្ហាប្រឈមធំជាងគេ ក្នុងសកលលោក និងជាលក្ខខណ្ឌដែលចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ក្របខ័ណ្ឌនេះក៏បានដាក់ចេញនូវការប្តេជ្ញាចិត្ត ដើម្បីសម្រេច




រូបភាពទី ៥៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (UN, n.d.)

ឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាពក្នុងសមាសភាគទាំងបីគឺសេដ្ឋកិច្ច សង្គម និងបរិស្ថាន តាមបែបផែនដែលមានតុល្យភាព និងប្រទាក់ក្រឡាគ្នា។ ក្របខ័ណ្ឌនេះបានដាក់ចេញនូវគោលបំណងដ៏ធំមួយ ពីពេលបច្ចុប្បន្នរហូតដល់ឆ្នាំ ២០៣០ នោះគឺ "បញ្ចប់ភាពក្រីក្រ និងភាពអត់ឃ្លាននៅគ្រប់ទិសទី ប្រយុទ្ធប្រឆាំងនឹងវិសមភាពក្នុងប្រទេស កសាងសង្គមប្រកបសុខសន្តិភាព យុត្តិធម៌ និងបរិយាបន្ន ការពារសិទ្ធិមនុស្ស និងលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងធានាឱ្យមានការការពារយូរអង្វែងដល់ភពផែនដី និងធនធានធម្មជាតិ"។ ក្របខ័ណ្ឌនេះក៏បានប្តេជ្ញា "បង្កើតនូវលក្ខខណ្ឌដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ន ចែករំលែកវិបុលភាព និងការងារសមរម្យ សម្រាប់ទាំងអស់គ្នា ដោយធ្វើការពិចារណាលើការអភិវឌ្ឍ និងសមត្ថភាព ដែលស្ថិតនៅកម្រិតខុសៗគ្នារបស់ប្រទេសនីមួយៗ" (UN, 2015a)។ គោលដៅនៃរបៀបវារៈឆ្នាំ ២០៣០ ត្រូវបានដាក់ចេញ តាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួន ១៧ (រូបភាពទី ៥) និងចំណុចដៅចំនួន ១៦៩ ដែលបង្ហាញពីវិសាលភាព និងមហិច្ឆតានៃរបៀបវារៈជាសកលថ្មីមួយនេះ។ ខណៈពេលដែលយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានទំនាក់ទំនងជាមួយនឹងគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលុបបំបាត់ភាពអត់ឃ្លានក៏ដោយ ក៏យុទ្ធសាស្ត្រជាតិនេះមានទំនាក់ទំនងយ៉ាងជាក់ច្បាស់ជាមួយនឹងគោលដៅ SDG សំខាន់ៗផ្សេងទៀត ជាពិសេស៖ គោលដៅទី១ ពុំមានភាពក្រីក្រ គោលដៅទី ៣ សុខភាពល្អ និងសុខុមាលភាព គោលទី ៤ ការអប់រំប្រកបដោយគុណភាព គោលដៅទី ៥ សមភាពយេនឌ័រ គោលដៅទី៦ ទឹកស្អាត និងអនាម័យ គោលដៅទី ៨ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច គោលដៅទី ១២ ការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព គោលដៅទី ១៣ សកម្មភាពអាកាសធាតុ គោលដៅទី ១៥ ជីវិត និងដីធ្លី គោលដៅទី ១៦ សន្តិភាព សន្តិសុខ និងស្ថាប័នរឹងមាំ និងគោដៅទី ១៧ ភាពជាដៃគូ។

## មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ

ក្នុងឆ្នាំ២០១៥មហាសន្និបាតអង្គការសហប្រជាជាតិបានសន្យាថាចាំបាច់ត្រូវមានការប្តេជ្ញាចិត្តរួមគ្នា ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងពុំទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍឡើយ។ ដោយទទួលស្គាល់ថា សេចក្តីថ្លៃថ្នូររបស់មនុស្សគឺជាសិទ្ធិជាមូលដ្ឋាន មហាសន្និបាតរបស់អង្គការសហប្រជាជាតិមានបំណងចង់ឃើញឱ្យមានការសម្រេចគោលដៅ និងចំណុចដៅនានាសម្រាប់គ្រប់ប្រជាជាតិទាំងអស់ និងសម្រាប់មនុស្សគ្រប់រូប

មកពីគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម ជាមួយនឹងការខិតខំប្រឹងប្រែងផ្តល់សេវាដល់អ្នកដែលនៅក្រោយគេឱ្យបានមុនគេ (UN, 2015a)។

របាយការណ៍ឆ្នាំ២០១៦ស្តីពីស្ថានភាពសង្គមក្នុងពិភពលោក បានបង្ហាញថា "មនុស្សជាតិបានសម្រេចនូវវឌ្ឍនភាពក្នុងសង្គមដែលមិនធ្លាប់មានក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ភាពក្រីក្របានថយចុះយ៉ាងច្រើននៅទូទាំងសកលលោក ហើយប្រជាពលរដ្ឋកាន់តែមានសុខភាពល្អ ទទួលបានការអប់រំខ្ពស់ជាងមុន និងកាន់តែមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ក្នុងកម្រិតមួយដែលមិនធ្លាប់មានកន្លងមក។ ទោះជាយ៉ាងណាក៏ដោយ វឌ្ឍនភាពទាំងនេះពុំបានសម្រេចឱ្យបានដូចៗគ្នានោះឡើយ។ វិសមភាពផ្នែកសង្គម និងសេដ្ឋកិច្ចនៅបន្តកើតមានឡើង ហើយនៅក្នុងករណីជាច្រើន វិសមភាពនេះកាន់តែកើនឡើងបន្ថែមទៀត។ ស្ទើរតែគ្រប់ទិសទីទាំងអស់ បុគ្គល និងក្រុមមួយចំនួនត្រូវប្រឈមនឹងឧបសគ្គដែលរារាំងពួកគេមិនឱ្យចូលរួមឱ្យបានពេញលេញក្នុងជីវភាពសេដ្ឋកិច្ច ជីវភាពសង្គម និងជីវភាពនយោបាយ។ ជាមួយនឹងបរិការណ៍នេះ បរិយាបន្នភាព និងការចែករំលែកវិបុលភាពបានក្លាយជាបំណងប្រាថ្នាសំខាន់ជាងគេ នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០។ ការផ្តោតសំខាន់នៃរបៀបវារៈឆ្នាំ ២០៣០ លើបរិយាបន្នភាព គូសបញ្ជាក់ឱ្យឃើញពីភាពចាំបាច់ក្នុងការកំណត់រកអ្នកដែលត្រូវបានគេទុកចោល និងកំណត់ឱ្យដឹងថាតើពួកគេត្រូវបានទុកចោលដោយរបៀបណា" (UN, 2016)។

របាយការណ៍នេះគូសបញ្ជាក់ថា បរិយាបន្នសង្គមមិនត្រឹមតែជាលក្ខខណ្ឌតម្រូវផ្នែកសីលធម៌ជាមូលដ្ឋានប៉ុណ្ណោះទេ វាក៏មានឥទ្ធិពលលើហានិភ័យនៃការអភិវឌ្ឍ ដែលពាក់ព័ន្ធជាមួយនឹងកំណើនសេដ្ឋកិច្ច បរិបទនយោបាយ បរិស្ថាន សុវត្ថិភាព និងសន្តិសុខ និងផលិតភាពផងដែរ។ យុទ្ធសាស្ត្រជាតិដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពតម្រូវឱ្យមានការដាក់ចេញសកម្មភាពជាក់លាក់ដើម្បីកាត់បន្ថយវិសមភាព និងលើកកម្ពស់កំណើនប្រកបដោយបរិយាបន្ន។ ដូច្នេះការសម្រេចទៅបាននូវការបញ្ចប់ភាពអត់ឃ្លាន ក្រោមគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅកម្ពុជា ពឹងអាស្រ័យលើការសម្រេចឱ្យបាននូវចំណុចដៅពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយមិនគិតពីលក្ខណៈប្រជាសាស្ត្រ សង្គម ជាតិពន្ធ និងភូមិសាស្ត្ររបស់ពួកគេ។ ការស្វែងយល់ឱ្យបានស៊ីជម្រៅអំពីស្ថានភាពបច្ចុប្បន្ន ដោយប្រើប្រាស់ស្ថិតិដែលមានស្រាប់ ផ្តល់នូវមូលដ្ឋានសម្រាប់កំណត់ពីយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីគ្របដណ្តប់លើអ្នកដែលត្រូវការអន្តរាគមន៍ទាំងនេះច្រើនជាងគេបំផុត។

# ៣. ការវិភាគស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (PESTLE)

## ៣.១ និន្នាការនយោបាយ និងច្បាប់

នៅក្នុងបរិយាកាសនយោបាយ គោលនយោបាយ និងច្បាប់មាននិន្នាការសំខាន់ៗជាច្រើន ដែលគេត្រូវកត់សម្គាល់ ដោយសារតែភាពពាក់ព័ន្ធរបស់វាចំពោះស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ជាពិសេសគេចាំបាច់ត្រូវដឹងថាមានគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តន៍ ដើម្បីបង្កលក្ខណៈដល់ការឆ្លើយតបចំពោះស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

### គោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

បរិបទគោលនយោបាយត្រូវបានសម្រួចដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (RGC, 2014b)ដែលជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់

រាជរដ្ឋាភិបាលកម្ពុជា (RGC, 2013)។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបាន រៀបចំឡើងក្នុងបរិបទនេះ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ "កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព" ត្រូវបានដាក់អនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត ដូច្នេះយុទ្ធសាស្ត្រ និងផែនការនេះគឺជាមូលដ្ឋាន សម្រាប់សម្រួចក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍នានា។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងឆ្នាំចុងក្រោយនៃការអនុវត្ត មុនការបោះឆ្នោតឆ្នាំ ២០១៨ មកដល់។ ក្រោយការបោះឆ្នោត នឹងមានការធ្វើបច្ចុប្បន្នភាពគោលនយោបាយ ព្រមទាំងយុទ្ធសាស្ត្រពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធភាគច្រើន ដំណើរការចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៨ និងបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ខណៈពេលដែលមានការសម្រេចបានវឌ្ឍនភាពមួយចំនួន ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រទាំងនេះ គោលបំណងជាច្រើនក្នុងចំណោមគោលបំណងដែលត្រូវបានដាក់ចេញនៅតែមានភាពពាក់ព័ន្ធនៅឡើយសម្រាប់ការអនុវត្តក្នុងរយៈពេលវែង។

ក្របខ័ណ្ឌរៀបចំផែនការដែលមានភាពរឹងមាំ និងយន្តការសម្រាប់សម្របសម្រួលត្រូវបានដាក់ឱ្យអនុវត្ត ដោយមានការបែងចែកការទទួលខុសត្រូវដល់ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលដែលត្រូវសហការគ្នា ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ផែនការសកម្មភាពជាតិកាត់បន្ថយភាពអត់ឃ្លាននៅកម្ពុជា ២០១៦-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៤-២០១៨ ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០ និងផែនការយុទ្ធសាស្ត្រតាមវិស័យដទៃទៀតដែលពាក់ព័ន្ធជាមួយនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០ ដែលពីពេលថ្មីៗនេះ បានទទួលការបំពេញបន្ថែម ដោយផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយភាពអត់ឃ្លាននៅកម្ពុជា ២០១៦-២០២៥ ខិតខំបង្កើនការយកចិត្តទុកដាក់លើការកែលម្អអាហារូបត្ថម្ភ ដើម្បីឈានទៅសម្រេចចំណុចដៅ ២.២ នៃគោលដៅទី ២ នៃ SDG ពោលគឺ៖ "ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃបញ្ហាអាហារូបត្ថម្ភរួមទាំងការសម្រេចបាននៅឆ្នាំ២០២៥នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិសក្រិន និងភាពស្គមស្គាំងរបស់កុមារ ក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងចាស់ជរា។"។

គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធជាច្រើនត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីគាំទ្រដល់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការអនុវត្តក្រមប្រតិបត្តិអន្តរជាតិស្តីពីការផ្សព្វផ្សាយផលិតផលជំនួសទឹកដោះម្តាយ (FAO et al., 2016) ការកំណត់ពីការទទួលខុសត្រូវជាផ្លូវការលើការបញ្ចូលមីក្រូសារជាតិទៅក្នុងអំបិល និងទឹកស៊ីអ៊ីវ (GAIN, 2015) និងការបញ្ចូលបញ្ហាកង្វះអាហារូបត្ថម្ភ/លើសអាហារូបត្ថម្ភទៅក្នុងផែនការ និង/ឬយុទ្ធសាស្ត្រអភិវឌ្ឍរបស់កម្ពុជា (IDS, 2015)។ ច្បាប់ស្តីពីម្ហូបអាហារកំពុងត្រូវបានរៀបចំឡើង ដើម្បីគ្រប់គ្រងការលក់ដូរម្ហូបអាហារ និងសុវត្ថិភាពម្ហូបអាហារ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើក្របខ័ណ្ឌគោលនយោបាយជាតិ គាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដើម្បីពង្រឹងប្រព័ន្ធកិច្ចគាំពារសង្គម និងផ្តល់កិច្ចគាំពារដល់ប្រជាពលរដ្ឋគ្រប់រូប។ ពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភវិញ គោលនយោបាយនេះមានគោលបំណងផ្តល់ជំនួយ រាប់បញ្ចូលទាំងការឆ្លើយតបចំពោះស្ថានភាពអាសន្ន (ឧទាហរណ៍ ការផ្គត់ផ្គង់ស្បៀងនៅក្នុងស្ថានភាពមានវិបត្តិ) ការការពារស្ត្រីមានផ្ទៃពោះ និងកុមារ (ធ្វើឱ្យប្រសើរនូវស្ថានភាពអាហារូបត្ថម្ភ) និងកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលប្រើប្រាស់ផលិតផលម្ហូបអាហារ ដែលដាំដុះនៅក្នុងមូលដ្ឋាន (RGC, 2016b)។

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ខែ មិថុនា ឆ្នាំ ២០១៥ គាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ក្នុងការឈានទៅសម្រេចសសរស្តម្ភនូវសន្តិសុខស្បៀង ដែលផ្តោតលើស្ថិរភាពស្បៀង។ ច្បាប់នេះមានគោលបំណង "គ្រប់គ្រងគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជា" ដើម្បីឈានទៅសម្រេចគោលដៅ មានដូចតទៅ៖ ១) ការបង្ការ ការបន្សាំ និងការកាត់បន្ថយមុនពេលដែលមានគ្រោះមហន្តរាយកើតឡើង ដោយសារមូលហេតុធម្មជាតិ ឬមូលហេតុបង្កឡើងដោយមនុស្ស ២) ការឆ្លើយតបបន្ទាន់ក្នុងអំឡុងពេលមានគ្រោះមហន្តរាយកើតមានឡើង ៣) ការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ (RGC, 2015b)។ បច្ចុប្បន្ននេះ កំពុងមានការបន្តអនុវត្តការងារ ដើម្បីអនុវត្តច្បាប់នេះតាមរយៈការចេញនូវអនុក្រឹត្យជាច្រើន ដែលចាំបាច់ដើម្បីបញ្ជាក់ឱ្យច្បាស់ពីការរៀបចំស្ថាប័ន ការបែងចែកការទទួលខុសត្រូវ និងធនធានដល់គ្រប់វិស័យទាំងអស់ ដែលធ្វើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។

## យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ដោយសារតែគោលនយោបាយដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភជាច្រើនកំពុងមានស្រាប់រួចទៅហើយនោះការកំណត់ឱ្យបានច្បាស់លាស់ក៏ដូចជាការបែងចែកការទទួលខុសត្រូវ និងធនធានត្រូវការការបញ្ជាក់ឱ្យកាន់តែច្បាស់បន្ថែមទៀត។ ជាលក្ខណៈប្រពៃណី គោលនយោបាយដាក់ចេញនូវក្របខ័ណ្ឌ នៅក្នុងនោះយុទ្ធសាស្ត្រកំណត់នូវគោលបំណង និងសកម្មភាពជាទិសដៅ សម្រាប់អនុវត្តច្រើនឆ្នាំ និងមានការដាក់ចេញនូវផែនការសកម្មភាព ដែលកំណត់ពីសកម្មភាព និងថវិកាជាក់លាក់ ដែលជាការបញ្ជាក់ច្បាស់ពីធនធានដែលចាំបាច់ត្រូវមាន ដើម្បីសម្រេចសកម្មភាពដែលបានដាក់ចេញទាំងនោះ។ ដោយចងចាំពីចំណុចនេះ ចាំបាច់ដែលត្រូវមានការបញ្ជាក់ឱ្យបានច្បាស់ពីការតម្រឹម/ឋានានុក្រម ឬភាពស៊ីសង្វាក់គ្នា រវាងឯកសារផ្សេងៗ ដើម្បីធានាឱ្យមានចក្ខុវិស័យច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលដៅចុងក្រោយ ដែលនាំឱ្យមានការរៀបចំផែនការច្បាស់លាស់ និងកៀងគរធនធាន ដើម្បីសម្រេចគោលដៅទាំងនោះ។ ផ្សារភ្ជាប់ជាមួយនឹងចំណុចនេះ ចាំបាច់ត្រូវមានការកំណត់អាទិភាពពាក់ព័ន្ធនឹងការកៀងគរធនធាន និងផែនការអនុវត្ត ឱ្យបានកាន់តែច្បាស់លាស់បន្ថែមទៀត ដែលត្រូវផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគណនេយ្យភាព និងក្របខ័ណ្ឌលទ្ធផលជាក់លាក់ ផ្តោតចំគោលដៅ ដើម្បីធានាឱ្យមានការពង្រឹងការអនុវត្តបន្ថែមទៀត (CARD, 2017a)។

កន្លងមក ការពង្រឹងអភិក្រមដែលមានលក្ខណៈសមាហរណកម្ម ដើម្បីឆ្លើយតបចំពោះស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានទទួលការគាំទ្រជាច្រើន។ លទ្ធផលរកឃើញនៃកិច្ចពិគ្រោះយោបល់ជាច្រើនដែលរៀបចំឡើង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បង្ហាញឱ្យឃើញពីភាពចាំបាច់ ដើម្បីបន្តពង្រឹងការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះ ដោយប្រើប្រាស់អភិក្រមពហុវិស័យ រួមនឹងការច្របាច់បញ្ចូលគ្នាសកម្មភាពទាំង ៦៤ និងសូចនាករដែលពាក់ព័ន្ធដោយរៀបចំចេញជាអាទិភាព និងកំណត់លំដាប់លំដោយឱ្យបានច្បាស់លាស់ ពង្រឹងទំនាក់ទំនងជាមួយថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តនៅមូលដ្ឋាន ធានាឱ្យមានការផ្តល់ថវិកាឱ្យបានកាន់តែច្រើនដល់មូលដ្ឋាន ដើម្បីធានាឱ្យមានការផ្គត់ផ្គង់ធនធានប្រកបដោយចីរភាពដល់ការអនុវត្តអាទិភាពទាំងនេះ និងសំដៅឆ្ពោះទៅរកការផ្តោតលើលទ្ធផល ជាជាង លើសកម្មភាព) (CARD, 2017b, 2017c)។

## សម្ព័ន្ធភាពនៅថ្នាក់តំបន់ និងថ្នាក់សកល

គោលនយោបាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់អាស៊ាន មានគោលបំណងចម្បង "ដើម្បីធានាឱ្យការផ្គត់ផ្គង់ប្រកបដោយចីរភាពនូវស្បៀងអាហារគ្រប់គ្រាន់ក្នុងតម្លៃសមរម្យមានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដែលបំពេញទៅតាមតម្រូវការអាហាររបស់ប្រជាពលរដ្ឋនៅក្នុងអាស៊ាន ដែលមានចំនួន

កើនឡើង”។ រដ្ឋជាសមាជិកត្រូវដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រង ដែលកាន់តែមានបរិយាបន្នជាងមុនដើម្បីៈ

- លើកកម្ពស់អភិបាលកិច្ច ប្រព័ន្ធស្បៀងអាហារ និងកសិកម្ម ដោយផ្តោតលើអាហារូបត្ថម្ភ
- លើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ជាតិ
- លើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមគ្រួសារ
- បង្កើនផលិតភាពកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ
- ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីនានា ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ។

ដោយសារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាបញ្ហាអន្តរវិស័យ រដ្ឋជាសមាជិកត្រូវបានលើកទឹកចិត្តឱ្យបង្កើតគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលគ្របដណ្តប់លើវិស័យចម្រុះដូចជាកសិកម្ម ទីផ្សារ និងតម្លៃ គោលនយោបាយពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការកាត់បន្ថយភាពក្រីក្រ និងវិស័យសង្គម សុខាភិបាល អប់រំ ប្រជាជន ម៉ាក្រូសេដ្ឋកិច្ច អត្រាប្តូរប្រាក់ គោលនយោបាយសារពើពន្ធ និងរូបិយប័ណ្ណជាដើម (លេខាធិការដ្ឋានអាស៊ាន ឆ្នាំ ២០១៧)។

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើក្របខ័ណ្ឌ យ៉ូហ្គោ (Hyogo) ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយជាមួយនឹងការប្តេជ្ញាចិត្តឆ្លើយតបចំពោះភាពងាយរងគ្រោះពាក់ព័ន្ធនឹងអាកាសធាតុដែលត្រូវបានគូសបញ្ជាក់ម្តងទៀតកាលពីពេលថ្មីៗនេះក្នុងទីក្រុងខេនឃូន (Cancun) និងសេនដាយ (Sendai)។ ក្រៅពីនេះ សមាគមនអាស៊ានក៏មានផ្តល់នូវគោលការណ៍ណែនាំបន្ថែមដល់រដ្ឋជាសមាជិក អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបចំពោះស្ថានភាពអាសន្ននៅក្នុងបរិបទថ្នាក់តំបន់ដែរ។

## ការសម្របសម្រួលតាមវិស័យ

ការយកចិត្តទុកដាក់លើបញ្ហាអាហារូបត្ថម្ភ មានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយក្នុងប្រទេសកម្ពុជាមានអង្គការសង្គមស៊ីវិលជាច្រើនបានអនុវត្តសកម្មភាព ដើម្បីលើកកម្ពស់លទ្ធផលសង្គម សេដ្ឋកិច្ច និងអាហារូបត្ថម្ភ ក្រោមក្របខ័ណ្ឌគោលនយោបាយដែលកាន់តែមានលក្ខណៈអំណោយផលសម្រាប់ការបំពេញការងាររបស់ពួកគេ។ ការងារនេះត្រូវបានទទួលការគាំទ្របន្ថែមទៀត ពីការបង្កើតចលនាបង្កើនអាហារូបត្ថម្ភ (SUN) រួមនឹងក្រុមការងារបច្ចេកទេសវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលបានផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងអន្តរវិស័យជុំវិញការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

បន្ទាប់ពីមានការធ្វើកំណែទម្រង់ស្ថាប័ននៅក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃការចូលរួមរបស់កម្ពុជាជាមួយនឹងចលនាបង្កើនអាហារូបត្ថម្ភកម្រិតសកលលោកចាប់តាំងពីឆ្នាំ ២០១៤ មក មានការកត់សម្គាល់ឃើញពី ការសម្រេចបានលទ្ធផលខ្ពស់ក្នុងការប្រមូលផ្តុំអ្នកពាក់ព័ន្ធនានា ឱ្យចូលរួមធ្វើសកម្មភាពរួមគ្នាតែមួយ។ថ្វីបើគេឃើញមានវឌ្ឍនភាពច្រើនពីមួយឆ្នាំទៅមួយឆ្នាំលើការតាមដាននិងការកៀរគរធនធានក្តី វឌ្ឍភាពលើវិស័យនេះនៅតែមានភាពយឺតយ៉ាវធៀបទៅនឹងស្ថាប័នដ៏ទៃផ្សេងទៀត។ ការដាក់ពិន្ទុអំពីវឌ្ឍនភាពនេះ យកគំរូតាមក្របខ័ណ្ឌពិនិត្យតាមដានវឌ្ឍនភាពជាសកលនៃចលនាបង្កើនអាហារូបត្ថម្ភ និងត្រូវបានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍ប្រចាំឆ្នាំ ផ្អែកទៅតាមវឌ្ឍនភាព ដែលត្រូវបានស្វ័យវាយតម្លៃដោយរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និងទីភ្នាក់ងារសហប្រជាជាតិ។ ពិន្ទុអតិបរមាគឺ ១០០% សម្រាប់ប៉ារ៉ាម៉ែត្រនីមួយៗ។ ជារួម ប្រទេសកម្ពុជាបានបង្កើនលទ្ធផលការងារនៃស្ថាប័នរបស់ខ្លួន សម្រាប់សកម្មភាពបង្កើនអាហារូបត្ថម្ភ ក្នុងកំណើនចំនួន ២០% ក្នុងឆ្នាំ ២០១៧ ដែលកំណើននេះកើនឡើងប្រមាណ ៥០%

ធៀបនឹងឆ្នាំ ២០១៥ (រូបភាពទី ៦)។ ក្នុងឆ្នាំ ២០១៧ បណ្ដាញបង្កើនអាហារូបត្ថម្ភនៅកម្ពុជា បានចាត់ទុកការជំរុញឱ្យមានការចូលរួមពីវិស័យឯកជន ការបង្កើនការប្ដេជ្ញាចិត្តក្នុងការផ្ដល់ហិរញ្ញប្បទានដល់សកម្មភាពអាហារូបត្ថម្ភ ការអនុវត្តកម្មវិធីរយៈវែងរបស់ដៃគូអភិវឌ្ឍន៍ និងការកែលម្អការធ្វើបញ្ញត្តិកម្មលើ ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ថាជាអាទិភាពសំខាន់ៗសម្រាប់ឆ្នាំ ២០១៧-២០១៨។




រូបភាពទី ៦៖ ការបង្កើនអាហារូបត្ថម្ភ - វឌ្ឍនភាពស្ថាប័ននៅកម្ពុជាឆ្នាំ ២០១៥-២០១៧ (SUN, ២០១៥, ២០១៦, ២០១៧)

ជាមួយនឹងមូលដ្ឋានគោលនយោបាយរឹងមាំ ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រួមជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល អ្នកផ្ដល់ជំនួយ និងដៃគូអភិវឌ្ឍន៍សំខាន់ៗកំពុងធ្វើការងាររួមគ្នា តាមរយៈអនុក្រុមបច្ចេកទេសទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ដើម្បីជំរុញឱ្យមានការអនុវត្តសកម្មភាពរួមគ្នា ដែលផ្ដោត លើអាទិភាពសំខាន់ៗដូចខាងក្រោម៖

១ តែងតាំងមន្ត្រីបង្គោលដែលអាចប្រមូលផ្ដុំចំណេះដឹងអំពីទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ
២ រៀបចំយុទ្ធសាស្ត្រអន្តរវិស័យ ដែលរៀបរាប់បង្ហាញពីការរួមចំណែករបស់គោលនយោបាយ ទឹកស្អាត និងអនាម័យ និងគោលនយោបាយអាហារូបត្ថម្ភបច្ចុប្បន្នក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ
៣ ជំរុញឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបង្កើនការវិភាជថវិកាជាតិសម្រាប់វិស័យអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ និងជំរុញឱ្យអ្នកផ្ដល់ជំនួយបង្កើនឱកាសដាក់ថវិការួមគ្នា (Development Initiatives, 2017, p.56)។

បច្ចុប្បន្ននេះ កិច្ចខិតខំប្រឹងប្រែងសម្របសម្រួលអន្តរវិស័យ បន្តធ្វើនៅថ្នាក់ជាតិ ហើយក៏មានឱកាសធ្វើការពង្រីកការសម្របសម្រួលបែបនេះទៅដល់ថ្នាក់ក្រោមជាតិផងដែរ ដោយប្រើប្រាស់រចនាសម្ព័ន្ធ ដែលមានស្រាប់របស់សាលាខេត្ត។

លើសពីនេះ ផែនការធំៗជាច្រើនដែលត្រូវបានដាក់ចេញក្រោមយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាមទារឱ្យមានការពង្រឹងបន្ថែម និងការចាត់អាទិភាព។

យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានសកម្មភាពអាទិភាពចំនួន ៦៤ ព្រមទាំងសូចនាករដែលពាក់ព័ន្ធ ដែលសកម្មភាពអាទិភាពមួយចំនួនសម្រេចបានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ដូចបង្ហាញក្នុងរបាយការណ៍បូកសរុបវឌ្ឍនភាពឆ្នាំ ២០១៦ (CARD, 2017d) ដើម្បីធានាឱ្យមានការសម្រេចលទ្ធផលចាំបាច់ត្រូវមាន ការបង្កើនការផ្ដោតការយកចិត្តទុកដាក់លើគោលដៅដែលកំណត់បានច្បាស់លាស់ និងងាយវាស់វែង និងដាក់ចេញនូវសូចនាករ និងចំណុចដៅមួយចំនួនតូច ដែលផ្សារភ្ជាប់ទំនាក់ទំនងជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងមានការបែងចែកការទទួលខុសត្រូវ និងគណនេយ្យភាពឱ្យបានច្បាស់លាស់ជុំវិញគោលដៅទាំងនេះ ដើម្បីផ្ដល់ការលើកទឹកចិត្ត និងតម្រង់ទិសដល់អ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន។ ដើម្បីសម្រេចគោលដៅទាំងនេះ ទាមទារឱ្យមានការរៀបចំផែនការអនុវត្តឱ្យបានច្បាស់លាស់ ដោយត្រូវផ្សារភ្ជាប់ជាមួយនឹងធនធាន និងកំណត់ឱ្យបានច្បាស់លាស់ពីភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងការរៀបចំការសម្របសម្រួល។

## ហិរញ្ញប្បទានការអភិវឌ្ឍ

ខណៈពេលដែលវិស័យភាគច្រើន សុទ្ធតែមានផែនការយុទ្ធសាស្ត្ររៀងៗខ្លួន ផែនការយុទ្ធសាស្ត្រទាំងនេះពុំត្រូវបានគេប៉ាន់ប្រមាណចំណាយសម្រាប់អនុវត្តឡើយ លើកលែងតែផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងវិស័យសុខាភិបាល។ ដូច្នេះ ចាំបាច់ត្រូវមានការកំណត់អាទិភាព និងប៉ាន់ប្រមាណចំណាយឱ្យបានពេញលេញនៃយុទ្ធសាស្ត្ររបស់វិស័យសំខាន់ៗផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ដំណើរការនៃការផ្តល់ហិរញ្ញប្បទានពីប្រភពខាងក្រៅ និងពីប្រភពក្នុងស្រុក ចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងជាមួយគ្នាតាមរយៈវដ្តនៃការរៀបចំផែនការ និងថវិកា ហើយត្រូវមានការបែងចែកធនធានសម្រាប់អាទិភាព ទៅតាមតម្រូវការជាក់ស្តែង ជាជាងទៅតាមការចង់បានរបស់អ្នកដែលផ្គត់ផ្គង់ធនធានទាំងនោះ (WFP, 2017c)។

កិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទូទាំងប្រទេសកម្ពុជា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (CARD, 2017b, 2017c) បានរំលេចឱ្យឃើញពីសារៈសំខាន់នៃការផ្តល់ហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់ដល់វិស័យនេះ ដើម្បីសម្រេចទៅតាមលទ្ធផលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយត្រូវធានាយ៉ាងណាឱ្យមានការគ្របដណ្តប់លើគ្រប់ផ្នែកជាអាទិភាពទាំងអស់។ ការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅថ្នាក់ជាតិ ក្រោមក្របខ័ណ្ឌរបៀបវារៈឆ្នាំ ២០៣០ និងមហិច្ឆតារបស់កម្ពុជាក្នុងការក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ តម្រូវឱ្យមានការបង្កើនទុនវិនិយោគឱ្យបានច្រើន ដោយប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ព្រមទាំងបង្កើតនូវរចនាសម្ព័ន្ធរៀបចំផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអំណោយផល និងប្រើប្រាស់ធនធានពីប្រភពវិស័យឯកជនផង និងវិស័យសាធារណៈផង (CRDB & CDC, 2017)។ ចាំបាច់ត្រូវមានការផ្សារភ្ជាប់ទំនាក់ទំនងរវាងដំណើរការរៀបចំផែនការ និងថវិកា ដែលកំពុងធ្វើដាច់ដោយឡែកៗពីគ្នា ឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត ដើម្បីធានាឱ្យមានការវិភាជថវិកាសម្រាប់អាទិភាពសំខាន់ៗ ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ។

ការចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជាសាជាថ្មី ជាប្រទេសចំណូលមធ្យមកម្រិតទាបអាចបង្កផលប៉ះពាល់ដល់ការទទួលបានការគាំទ្រពីប្រភពខាងក្រៅ។ ការផ្តល់មូលនិធិក្នុងទម្រង់ជាហិរញ្ញប្បទានឥតសំណងអាចត្រូវជំនួសដោយហិរញ្ញប្បទានសម្បទានវិញ ខណៈពេលជំនួយអភិវឌ្ឍន៍ផ្លូវការអាចនឹងមានការថយចុះ (CRDB & CDC, 2017)។

ផលធៀបរវាងហិរញ្ញប្បទានសហប្រតិបត្តិការ/ផលិតផលសរុបក្នុងស្រុក ថយចុះពី ១១% ក្នុងឆ្នាំ ២០១១ មកនៅ ៧,៤% ក្នុងឆ្នាំ ២០១៥ ហើយវិស័យសង្គមបានទទួលមូលនិធិជំនួយអភិវឌ្ឍន៍ផ្លូវការច្រើនជាងគេ ដល់ទៅ ៣៧% បន្ទាប់មកគឺវិស័យហេដ្ឋារចនាសម្ព័ន្ធប្រមាណជា ៣០% ក្នុងឆ្នាំ ២០១៥ (CRDB & CDC, 2016)។

ដើម្បីបន្តកិច្ចខិតខំប្រែងដែលកំពុងមាននាពេលបច្ចុប្បន្ន និងធានាឱ្យមានការបន្តសម្រេចសមិទ្ធផលដែលទទួលបានកន្លងមក គេចាំបាច់ត្រូវបង្កើតទំនាក់ទំនងឱ្យបានច្បាស់លាស់រវាងអាទិភាព លទ្ធផលរំពឹងទុក និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ព្រមទាំងផ្តួចផ្តើមការសហការជាមួយដៃគូដែលមានស្រាប់ និងដៃគូថ្មីៗ (ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស) ដើម្បីធានាឱ្យមានការរក្សាលំហូរធនធានបន្តទៀត។ គួរមានការស្វែងយល់បន្ថែមទៀតពីជម្រើសផ្តល់ហិរញ្ញប្បទានដែលមានលក្ខណៈច្នៃប្រឌិតពីប្រភពក្នុងស្រុក និងប្រភពខាងក្រៅដែលធ្លាប់មានកន្លងមក ដើម្បីបង្កើនចំណាយសាធារណៈសំខាន់ៗសម្រាប់គម្រោងអភិវឌ្ឍន៍ដែលកំពុងបន្តអនុវត្តនាពេលបច្ចុប្បន្ននេះ។

| | 2015 | | 2020 | | 2025 | |
|---|---|---|---|---|---|---|
| | USD m | %GDP | USD m | %GDP | USD m | %GDP |
| ចំណូលក្នុងស្រុក | 3,114 | 17.2 | 5,001 | 19.7 | 6,961 | 20.0 |
| ការវិនិយោគឯកជនក្នុងស្រុក | 2,147 | 11.9 | 3,048 | 12 | 4,176 | 12.0 |
| ការវិនិយោគផ្ទាល់ពីបរទេស (FDI) | 1,732 | 9.6 | 2,540 | 10 | 3,480 | 10.0 |
| ការផ្ញើរប្រាក់ | 397 | 2.2 | 914 | 3.6 | 1,740 | 5.0 |
| ជំនួយអភិវឌ្ឍន៍ផ្លូវការ | 767 | 4.2 | 800 | 3.1 | 800 | 2.3 |
| កិច្ចសហការភាគខាងត្បូង | 349 | 1.9 | 400 | 1.6 | 400 | 1.1 |
| មូលនិធិសម្រាប់ផ្នែកអាកាសធាតុ | 140 | 0.8 | 226 | 0.9 | 312 | 0.9 |
| អង្គការមិនមែនរដ្ឋាភិបាល | 226 | 1.3 | 225 | 0.9 | 225 | 0.6 |
| សរុបហិរញ្ញប្បទានអភិវឌ្ឍន៍ | 8,873 | 49.1% | 13,164 | 51.8% | 18,094 | 52.0% |

តារាងទី ២៖ សង្ខេបចំណូលវាយតម្លៃហិរញ្ញប្បទានអភិវឌ្ឍន៍ (CRDB & CDC, 2017)

### កត្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី១

មានឱកាសពង្រឹងបន្ថែម ដោយប្រើប្រាស់ក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ និងប្រើប្រាស់គោលនយោបាយទាំងនេះ ដើម្បីធានាយ៉ាងណាឱ្យគ្រប់ឯកសារយុទ្ធសាស្ត្រទាំងអស់ត្រូវបានបន្សុីគ្នា ដោយមានការដាក់ចេញផែនការច្បាស់លាស់ សម្រាប់អនុវត្ត និងពង្រឹងការអនុវត្ត ដូចជាការផ្តល់ធនធាន ការរៀបចំអភិបាលកិច្ច ការពិនិត្យតាមដាន និងសមត្ថភាពប្រមូលទិន្នន័យ។

ដើម្បីសម្រេចនូវគោលបំណងនៃការអភិវឌ្ឍ ដូចដែលបានដាក់ចេញក្រោមរបៀបវារៈឆ្នាំ ២០៣០ ចាំបាច់ត្រូវកៀងគរធនធានថវិកាឱ្យបានច្រើនបន្ថែមទៀតពីវិស័យសាធារណៈ និងវិស័យឯកជន ព្រមទាំងមានការតម្រឹមដំណើរការរៀបចំផែនការ និងថវិកាឱ្យកាន់តែស្របគ្នា ដោយប្រើប្រាស់ថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា។

កិច្ចសហប្រតិបត្តិការតាមរយៈក្រុមការងារបច្ចេកទេស និងបណ្តាញពង្រីកអាហារូបត្ថម្ភ ផ្តល់នូវមូលដ្ឋានដែលរឹងមាំសម្រាប់ឱកាសពង្រីកការសម្របសម្រួលឱ្យដល់ថ្នាក់ក្រោមជាតិ ហើយក្នុងពេលជាមួយគ្នាពង្រីកភាពជាដៃគូបន្ថែមទៀត ដើម្បីកៀរគរធនធាន និងជំនាញឯកទេសបន្ថែម។

## ៣.២ និន្នាការសេដ្ឋកិច្ច

និន្នាការម៉ាក្រូសេដ្ឋកិច្ចនៅប្រទេសកម្ពុជា បានបង្ហាញឱ្យឃើញពីកំណើនសេដ្ឋកិច្ចយ៉ាងរឹងមាំគួរឱ្យកត់សម្គាល់ ខណៈពេលដែលប្រទេសទទួលបានស្ថិរភាពចាប់ពីតាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មក ដែលនាំឱ្យមានការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើននៅថ្នាក់ជាតិ លើសពីអ្វីដែលប្រទេសដទៃផ្សេងទៀតអាចសម្រេចបាន។ អត្រាភាពក្រីក្រពហុសមាសភាគមានកម្រិតខ្ពស់ជាងអត្រានៃភាពក្រីក្ររាប់តាមចំនួនមនុស្ស (សូមមើលចំណុច ៤.២ ការទទួលបានស្បៀង) ហើយការបង្កើនចំណូលពុំត្រូវបានបែងចែកឱ្យបានស្មើៗគ្នានោះឡើយ ដោយបំណុលដែលជាប់ជំពាក់ដោយគ្រួសារដែលងាយរងគ្រោះជាងគេ នៅបន្តជាបញ្ហាប្រឈម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនសេដ្ឋកិច្ចនៅកម្ពុជាត្រូវបានជំរុញដោយកំណើនក្នុងវិស័យសេវាកម្ម ដែលមានន័យថា រចនាសម្ព័ន្ធរបស់សេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរងាក ចេញពីវិស័យកសិកម្ម ទៅរកវិស័យកម្មន្តសាល និងវិស័យសេវាកម្មវិញ។

## កំណើនម៉ាក្រូសេដ្ឋកិច្ច

ជាមួយនឹងការទទួលបានស្ថិរភាពចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មកប្រទេសកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់ក្នុងអត្រាជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១៦ ប្រទេសកម្ពុជារក្សាកំណើនខ្ពស់ក្នុងអត្រា ៧% ស្របតាមការព្យាករណ៍ពីកំណើន ផលិតផលក្នុងស្រុកសរុប ជាមធ្យមប្រចាំឆ្នាំ ៧% ក្នុងផែនការអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ហើយសក្តានុពលនេះ នៅអាចសម្រេចបានទៀត ខណៈពេលដែលកម្ពុជានៅអាចរក្សាបានអត្រាកំណើនជាមធ្យម ៧% ក្នុងរយៈពេលមធ្យម ដោយមានការគាំទ្រពីការបន្តធ្វើពិពិធកម្មការនាំចេញ (ADB, 2017; World Bank, 2017a; MEF, 2016) ។

> “ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ ដែលធានាឱ្យមានភាពប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ...”

កំណើនម៉ាក្រូសេដ្ឋកិច្ច ខ្ពស់បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៦ និងបង្កើនវត្តមានរបស់ប្រទេសនេះក្នុងបរិយាកាសពាណិជ្ជកម្មថ្នាក់តំបន់ និងថ្នាក់សកលលោក ដែលពោលពេញដោយភាពប្រកួតប្រជែង។ កំណើននៅក្នុងប្រទេសនេះ ត្រូវបានជំរុញដោយកត្តាជាច្រើន ដូចជា ការពង្រីកដ៏ឆាប់រហ័យនៃវិស័យសំណង់ កំណើនរឹងមាំនៃវិស័យឧស្សាហកម្ម ជាពិសេសការនាំចេញផលិតផលសម្លៀកបំពាក់ និងការបន្តពង្រីកវិស័យកសិកម្ម (ជាពិសេសផលិតកម្មស្រូវ) និងការកើនឡើងនូវចំនួនភ្ញៀវទេសចរណ៍។

ការពង្រីកដ៏ឆាប់រហ័សនៃវិស័យឧស្សាហកម្ម និងការពង្រីកវិស័យសេវាកម្ម បើទោះបីជាមិនលឿនដូចវិស័យឧស្សាហកម្មយ៉ាងណាក៏ដោយ ធ្វើឱ្យភាគរយនៃវិស័យកសិកម្មក្នុងសេដ្ឋកិច្ចរបស់ជាតិបន្តថយចុះ។ ក្នុងឆ្នាំ ២០១៦ ភាគរយនៃវិស័យកសិកម្មក្នុង ផលិតផលក្នុងស្រុកសរុប មានប្រមាណជា ២៦,៣% ឧស្សាហកម្ម ៣១,៣% និងសេវាកម្ម ៤២,៤% (ADB, 2017; World Bank, 2017a; MEF, 2016)។ ស្ថានភាពការនាំចេញទៅក្រៅប្រទេសបន្តមានភាពល្អប្រសើរ ដោយសារកំណើនការនាំចេញខ្ពស់ ជាមួយនឹងការពង្រីកបរិមាណការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង។ បើទោះបីជាការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងនេះបានថមថយបន្តិចនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការឡើងថ្លៃប្រាក់ដុល្លារ និងការប្រកួតប្រជែងពីប្រទេសក្នុងតំបន់ដែលមានប្រាក់ឈ្នួលទាបផ្សេងទៀត (World Bank, 2017a)។ បើទោះបីជាប្រទេសកម្ពុជានៅមានសក្តានុពលបន្តកំណើនវិជ្ជមានទាំងនេះយ៉ាងណាក៏ដោយ ហានិភ័យមួយចំនួន មានដូចជា ការឡើងចុះអត្រាប្តូរប្រាក់ ការងើបឡើងវិញនៃសេដ្ឋកិច្ចក្នុងល្បឿនយឺតយ៉ាវជាងការរំពឹងទុកក្នុងទីផ្សារសំខាន់ៗ ដូចជា ទីផ្សារនៅអឺរ៉ុប និងភាពមិនប្រាកដប្រជាជាទូទៅក្នុងពាណិជ្ជកម្មសកល ក៏ដូចជាលទ្ធភាពថមថយឧត្តមភាពប្រកួតប្រជែងរបស់ប្រទេសដោយសារប្រាក់ឈ្នួលមានការកើនឡើង។ ការបង្កើនការវិនិយោគលើធនធានមនុស្ស រួមទាំងការផ្តោតការយកចិត្តទុកដាក់ពិសេសលើអាហារូបត្ថម្ភគឺជាកិច្ចចាំបាច់ ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសទៅមុខទៀត (World Bank, 2017b; WFP, 2017b; WFP, 2017f) ។

ស្របពេលជាមួយគ្នានេះដែរ គ្រួសារដែលរស់នៅតាមតំបន់ជនបទអាចធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិតរបស់ពួកគេទៅរកការងារផ្សេងក្រៅពីការពារស្រែចម្ការ (ដូចជាក្នុងឧស្សាហកម្មកាត់ដេរ វិស័យសំណង់ និងវិស័យសេវាកម្មជាដើម) ដែលសុទ្ធតែបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ ត្រឹមឆ្នាំ ២០១៥ ចំណូលដែលបានពីប្រាក់ឈ្នួលពីការងារមិនមែនការងារកសិកម្ម ស្មើនឹងមួយភាគបីនៃចំណូលសរុបនៅជនបទ បើធៀបនឹងតិចជាងមួយភាគប្រាំក្នុងឆ្នាំ ២០០៧ (World Bank, 2017b)។

កំណើនប្រាក់ចំណូល និងប្រាក់ឈ្នួលខ្ពស់ទូទាំងប្រទេស រាប់បញ្ចូលទាំងការបង្កើនប្រាក់បៀវត្សរ៍វិស័យសាធារណៈផងនោះ កើតឡើងទន្ទឹមគ្នានឹងការកើនឡើងនូវតម្រូវការក្នុងស្រុក បើទោះបីជាអត្រាអតិផរណាមានការឡើងចុះ និងកើនឡើងបន្តិចដល់ប្រមាណជា ៤,៣% ក្នុងខែ មីនា ឆ្នាំ ២០១៧ បើធៀបនឹងខែ មីនា កាលពីឆ្នាំមុន និងថយចុះមកនៅត្រឹម ២,៣% ក្នុងខែ កក្កដា ឆ្នាំ ២០១៧ បើធៀបនឹងខែ កក្កដា ឆ្នាំមុន បើតាមទិន្នន័យផ្លូវការចុងក្រោយយ៉ាងណាក៏ដោយ។ មូលហេតុចម្បងដែលនាំមានការកើនឡើងនូវអត្រាអតិផរណានេះ គឺការកើតឡើងនូវតម្លៃស្បៀងអាហារ ដែលបានស្រូបយកអត្ថប្រយោជន៍មួយចំនួនដែលបានពីកំណើនចំណូលពិត (NIS, 2017; World Bank, 2017a)។

## ការកាត់បន្ថយភាពក្រីក្រ

ការកាត់បន្ថយភាពក្រីក្រ នឹងលើកយកមកបង្ហាញលម្អិតបន្ថែមទៀតក្រោមចំណុច ៤.២ ស្តីពីការទទួលបានស្បៀងនៅកម្រិតគ្រួសារ។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់នៅទីនេះ គឺថាកំណើនសេដ្ឋកិច្ចរឹងមាំគួរឱ្យកត់សម្គាល់នៅថ្នាក់ជាតិ បានជួយសម្រួលឱ្យមានការកាត់បន្ថយអត្រានៃភាពក្រីក្រ និងការបង្កើនសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស (HDI) របស់កម្ពុជាក្នុងកម្រិតមួយខ្ពស់។ ពីឆ្នាំ ១៩៩០ ដល់ ២០១៥ សន្ទស្សន៍ HDI ប្រចាំឆ្នាំរបស់កម្ពុជាបានកើនឡើងក្នុងអត្រា ១,៨៤% ពោលគឺខ្ពស់ជាងអត្រាមធ្យមនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិច ដែលបច្ចុប្បន្ននេះមានកម្រិត ១,៣៥% ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសទាំងប្រាំពីរក្នុងពិភពលោក ដែលមានអត្រាកំណើនសន្ទស្សន៍នៃការអភិវឌ្ឍមនុស្សលឿនជាងគេ និងជាប់ចំណាត់ថ្នាក់ទី ១៤៣ ក្នុងចំណោម ១៨៨ ប្រទេស។ ទោះជាយ៉ាងណាក៏ដោយនៅមានប្រជាពលរដ្ឋដែលបាត់បង់ឱកាសជាច្រើនដែលកំពុងស្ថិតនៅក្រោយការអភិវឌ្ឍ។ របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០១៦ កត់សម្គាល់ថាសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស ឆ្នាំ ២០១៥ របស់កម្ពុជាមានតម្លៃ ០,៥៦៣ ដែលនេះបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងកម្រិត ៥៧% ពី ០,៣៥៧ ក្នុងឆ្នាំ ១៩៩០។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះនៅទាបជាងតួលេខមធ្យម ០,៦៣១ សម្រាប់ប្រទេសដែលស្ថិតនៅក្នុងក្រុមប្រទេសដែលមានការអភិវឌ្ឍមនុស្សមធ្យម និងទាបជាងអត្រាមធ្យម ០,៧២១ សម្រាប់ប្រទេសនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិច (UNDP, 2016)។ ទន្ទឹមគ្នានេះដែរ ភាគរយនៃប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្ររបស់ជាតិបានថយចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកនៅ ១៣,២% ក្នុងឆ្នាំ ២០១៤ នេះបើតាមស្ថិតិផ្លូវការស្តីពីចំនួនប្រជាពលរដ្ឋក្រីក្រគិតតាមប្រាក់ចំណូល។ បើទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់យ៉ាងនេះក៏ដោយ ប្រទេសកម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមក្នុងការកាត់បន្ថយភាពក្រីក្រ និងវិសមភាព។ ដូច្នេះចាំបាច់ត្រូវមានការធានាយ៉ាងណាឱ្យមានការបែងចែកផលដែលបានពីការអភិវឌ្ឍមនុស្សនេះ ឱ្យបានសមធម៌ និងធានាយ៉ាងណាឱ្យមានការចូលរួមពីស្ត្រី។

### អត្ថាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី២

កំណើនសេដ្ឋកិច្ចខ្ពស់បានជួយឱ្យមានការកាត់បន្ថយភាពក្រីក្រ។ ក្នុងដំណើរផ្លូវទៅមុខទៀតគួរតម្រង់ទិសសមិទ្ធផលដែលសម្រេចបាននេះ ដោយផ្តោតការយកចិត្តទុកដាក់បញ្ហាអសមធម៌ និងលើកកម្ពស់កំណើនបរិយាបន្ន ដើម្បីឈានទៅសម្រេចចក្ខុវិស័យនៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ។

## ៣.៣ និន្នាការសង្គម-ប្រជាសាស្ត្រ

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានប្រជាជនវ័យក្មេង និងជាប្រទេសដែលចំនួនប្រជាជនបន្តមានការកើនឡើង ហើយទោះបីជាប្រជាពលរដ្ឋភាគច្រើនរស់នៅតាមទីជនបទ បើតាមជំរឿនចុងក្រោយយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាគឺជាប្រទេសដែលមានការអភិវឌ្ឍ និងការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស ដែលមូលហេតុចម្បង គឺដោយសារលំហូរនៃការធ្វើចំណាកស្រុក។ និន្នាការនេះជាសក្តានុពលសេដ្ឋកិច្ចផង ហើយតម្រូវឱ្យមានការកែសម្រួលគោលនយោបាយផង (NIS, 2013a, 2013b; Haslett et al., 2013)។ ស្របពេលជាមួយគ្នាបញ្ហាវិសមភាពយេនឌ័រនៅតែបន្តមាន បើទោះបីជាស្ត្រីជាអ្នករួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមយ៉ាងណាក៏ដោយ។

### និន្នាការប្រជាជន

ចំនួនប្រជាជននៅកម្ពុជាកើនឡើងពី ១១,៤៣ លាននាក់ក្នុងឆ្នាំ ១៩៩៨ ដល់ ១៣,៣៩ លាននាក់ក្នុងឆ្នាំ ២០០៨ ពោលគឺកើនឡើង ១,៩៦ លាននាក់ក្នុងទសវត្សរ៍មុនជំរឿនចុងក្រោយឆ្នាំ ២០០៨ (NIS, 2009a) និង ១៥,៧៦ លាននាក់ក្នុងឆ្នាំ ២០១៦ (World Bank, n.d.)។ ដង់ស៊ីតេប្រជាជនក្នុងប្រទេសនេះកើនឡើងពី ៦៤ ដល់ ៧៥ ក្នុងមួយគីឡូម៉ែត្រការ៉េ បើទោះបីជាបើតាមស្ថិតិផ្លូវការអត្រាកំណើនប្រជាជនប្រចាំឆ្នាំមានការថយចុះពី ២,៤៩% ក្នុងឆ្នាំ ១៩៩៨ មកនៅ ១,៥៤% ក្នុងឆ្នាំ ២០០៨ ខណៈពេលដែលស្ត្រីកម្ពុជាបានកូនកាន់តែតិចនាក់ ហើយអត្រាសាយកូនមានត្រឹម ៣,១ កំណើតក្នុងស្ត្រីម្នាក់ (NIS, 2009a)។ ទន្ទឹមគ្នានេះ ស្របពេលដែលអត្រាមរណភាពមាតា កុមារ និងទារកមានការថយចុះ មានការប៉ាន់ប្រមាណថា ចំនួនប្រជាជននឹងកើនឡើងជិត ២០ លាននាក់ត្រឹមឆ្នាំ ២០៣០ (ADB, 2014)។ ជំរឿនឆ្នាំ ២០០៨ បង្ហាញថាអត្រាមរណភាពទារកថយចុះតិចតួចពី ៦៦ មកនៅ ៦០ ក្នុង ១.០០០ កំណើតរស់ចន្លោះពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨ ខណៈពេលដែលការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ ២០១០ រាយការណ៍ថាមានករណីស្លាប់ ៤៥ ករណី ក្នុង ១០០០ កំណើតរស់ ហើយការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០១៤ រាយការណ៍ថាមានករណីស្លាប់ ២៨ ករណី ក្នុង ១.០០០ កំណើតរស់យ៉ាងណាក៏ដោយ។ មានការប៉ាន់ប្រមាណថា អត្រាមរណភាពមាតាបន្តនៅទ្រឹងពោលគឺ ៣៣៧ នាក់ក្នុងឆ្នាំ ២០០០ ឡើងមក ៤៧៧ នាក់ក្នុងឆ្នាំ ២០០៥ និង ៤៦៦ ក្នុង ១០០.០០០ កំណើតរស់ក្នុងឆ្នាំ ២០០៨ នេះបើតាមទិន្នន័យជំរឿន។ ទោះជាយ៉ាងណាក៏ដោយ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា រាយការណ៍ថា អត្រាមរណភាពមាតាមានប្រមាណជា ២០៦ ករណី ក្នុង ១០០.០០០ កំណើតរស់ ក្នុងឆ្នាំ ២០១០ និងថយចុះមកនៅ ១៧០ ករណីក្នុង ១០០.០០០ កំណើតរស់ក្នុងឆ្នាំ ២០១៤។ ដូច្នេះ មានវឌ្ឍនភាពល្អប្រសើរជាងមុនផ្នែកមរណភាពទារក និងកុមារបានបង្ហាញ ក្នុងទសវត្សរ៍កន្លងទៅនេះ (NIS 2009a, 2011, 2015)។

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានប្រជាជនវ័យក្មេង ដែលនេះគឺជាឱកាសសេដ្ឋកិច្ចដ៏ធំមួយ។ ប្រជាពលរដ្ឋដែលទើបពេញវ័យអាយុ ១៥ ដល់ ២៩ ឆ្នាំ មានប្រមាណជា ៣៣% នៃចំនួនប្រជាជនសរុប ហើយ ៣២% ទៀតមានអាយុក្រោម ១៥ ឆ្នាំ។ ប្រទេសនេះមានអត្រាកំណើតក្នុងចំណោមក្មេងជំទង់ខ្ពស់ ពោលគឺខ្ពស់ជាងអត្រាមធ្យមរបស់ប្រទេសនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ជិតពីរដង។ អត្រាកំណើតក្នុងចំណោមស្ត្រីអាយុ ១៥ ដល់ ១៩ ឆ្នាំនៅកម្ពុជា គឺ ៥១,៦ កំណើតក្នុង ១.០០០ នាក់ បើធៀបនឹង ២៣,១ កំណើតក្នុងស្ត្រី ១.០០០ នាក់ក្នុងតំបន់នេះ (UNDP, 2016; WFP, 2017a)។

ប្រជាជនកម្ពុជាក៏មានអាយុកាន់តែវែងផងដែរ។ ចាប់ពីឆ្នាំ ១៩៩៥ ដល់ ២០១៥ អាយុរំពឹងទុករបស់កម្ពុជានៅពេលកើត កើនឡើង ១៥,២ ឆ្នាំ (UNDP, 2016) ដោយអាយុកាលរំពឹងទុកគឺ ៦០,៥ ឆ្នាំ

សម្រាប់បុរស និង ៦៣,៥ ឆ្នាំ សម្រាប់ស្ត្រីក្នុងជំរឿនចុងក្រោយ ហើយគេរំពឹងថា នឹងកើនឡើងដល់ ៦៦,៤ ឆ្នាំ សម្រាប់បុរស និង ៦៩,៩ ឆ្នាំ សម្រាប់ស្ត្រី ត្រឹមឆ្នាំ ២០៣០។ គេរំពឹងថា ចំនួនមនុស្សចាស់នឹងមានការកើនឡើង ជាមួយនឹងអត្រាអ្នករស់នៅក្នុងបន្ទុកកាន់តែខ្ពស់។ ភាគរយនៃចំនួនប្រជាជនកម្ពុជាអាយុជាង ៦៩ ឆ្នាំ កំពុងមានការកើនឡើង និងត្រូវបានគេប៉ាន់ប្រមាណថា នឹងឡើងដល់ ៦% នៃចំនួនប្រជាជនសរុបត្រឹមឆ្នាំ ២០៣០ ដែលតម្រូវឱ្យមានការដាក់ចេញគោលនយោបាយ សុខភាព និងគោលនយោបាយគាំពារសង្គម ដោយសារតែមនុស្សចាស់មានភាពងាយរងគ្រោះខ្ពស់ ជាពិសេស ស្ត្រីដែលមានអាយុកាលរំពឹងទុកកាន់តែវែង (NIS, 2009a; ADB, 2014)។ ទោះជាយ៉ាងណាក៏ដោយ មនុស្សចាស់បានរួមចំណែកជាវិជ្ជមានជាច្រើនដល់ជីវិតគ្រួសារ ដូចជាការជួយមើលថែកុមារជាដើម។ ក្នុងរបាយការណ៍ដែលចេញផ្សាយដោយ UNDP កាលពីពេលថ្មីៗនេះ វត្តមានរបស់សមាជិកគ្រួសារជាមនុស្សចាស់មានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងការផ្លាស់ប្តូរស្ថានភាពរបស់គ្រួសារ ទៅជាគ្រួសារដែលលែងមានជីវភាពក្រីក្រ នេះបើតាមទិន្នន័យឆ្នាំ ២០១៤ (Foraci/UNDP, 2017)។

ដង់ស៊ីតេប្រជាជនពុំមានរបាយស្មើគ្នាទូទាំងប្រទេសនោះឡើយ ដោយប្រជាជនរស់នៅប្រមូលផ្តុំគ្នាច្រើនក្នុងតំបន់វាលទំនាបភូមិភាគអាគ្នេយ៍ តាមបឹងទន្លេសាប និងភូមិភាគពាយព្យនៃប្រទេសនេះ។ តំបន់ព្រៃសាន និងនិរតីមានដង់ស៊ីតេទាបជាងគេ (រូបភាពទី ៧)។ គេត្រូវចងចាំពីចំណុចខុសគ្នាទាំងនេះ នៅពេលធ្វើការពិចារណាពី គម្លាតនៃភាពងាយរងគ្រោះ តាមទីតាំងភូមិសាស្ត្រ បន្ទុកនៃភាពក្រីក្រគិតជាសមាមាត្រ ឬភាគរយ (ប្រេវ៉ាឡង់) និងគិតជាចំនួនគត់ (ចំនួន ប្រជាពលរដ្ឋ ជាក់ស្តែងដែល ទទួលរងផលប៉ះពាល់) ពុំត្រូវបាន បែងចែកឱ្យបានស្មើគ្នាតាមគ្រប់តំបន់ ទាំងអស់ ក្នុងប្រទេស នេះឡើយ។ ចំណុចនេះ អាចមាន ភាពពាក់ព័ន្ធជាច្រើន ដល់ការរៀបចំ យុទ្ធសាស្ត្រអន្តរាគមន៍ និងវិធីសាស្ត្រកំណត់រក ក្រុមគោលដៅ (Haslett et al., 2013).




រូបភាពទី ៧៖ ដង់ស៊ីតេប្រជាជន (ជំរឿនប្រជាជនទូទាំងប្រទេសរបស់ប្រទេសកម្ពុជា ២០០៨) ( Haslett et al., 2013)។ សម្គាល់៖ ផែនទីនេះត្រូវបានរៀបចំឡើងមុនពេលមានការបែងចែកខេត្តកំពង់ចាមជាពីរ ដូច្នេះផែនទីនេះពុំបានបញ្ចូលខេត្តត្បូងឃ្មុំឡើយ។

## ការធ្វើចំណាកស្រុក

ការសិក្សានានាបង្ហាញថា ការធ្វើចំណាកស្រុកពីតំបន់ជនបទទៅតំបន់ប្រជុំជនស្មើនឹង ៥៦% នៃការធ្វើចំណាកស្រុកសរុប ដែលភាគច្រើនប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរាជធានីភ្នំពេញ និងតំបន់ជាយក្រុង។ ការធ្វើចំណាកស្រុកទាំងនេះកើតឡើងភាគច្រើនដោយកត្តាសេដ្ឋកិច្ច ដែលបានជួយជំរុញឱ្យមានកំណើន និងការកាត់បន្ថយភាពក្រីក្រ (WFP, 2017f)។ លទ្ធផលរកឃើញនេះត្រូវបានគូសបញ្ជាក់បន្ថែមទៀត ដោយគម្រោងទេសន្តរប្រវេសន៍ពីតំបន់ជនបទទៅតំបន់ប្រជុំជននៅកម្ពុជា ដែលប៉ាន់ប្រមាណថា ការធ្វើចំណាកស្រុកចេញពីតំបន់ជន បទពាក់កណ្តាលគឺទៅទីក្រុងភ្នំពេញ

"ប្រមាណជាពាក់កណ្តាល់នៃការធ្វើចំណាកស្រុកចេញពីតំបន់ជនបទគឺទៅទីក្រុងភ្នំពេញ និងប្រមាណជាមួយភាគបីទៅប្រទេសផ្សេងទៀត.."

និងប្រមាណជាមួយភាគបី ជាការធ្វើចំណាកស្រុកទៅក្រៅប្រទេស ដែលក្នុងនោះចំណាកស្រុកភាគច្រើនលើសលុបគឺ ទៅប្រទេសថៃ។ ការធ្វើចំណាកស្រុក ពីតំបន់ជនបទទៅតំបន់ប្រជុំជនបែបនេះ នាំឱ្យចំនួនប្រជាជននៅរាជធានីភ្នំពេញកើនឡើង ៧០% ពីជិត ១ លាននាក់ដល់ជិត ១,៧ លាននាក់ ចន្លោះពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១៣ ទន្ទឹមគ្នានេះ មានការប៉ាន់ប្រមាណថា ភាគរយនៃគ្រួសារជនបទបានថយចុះពី ៨០,៥% នៃចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០០៨ មកនៅ ៧៨,៦% ក្នុងឆ្នាំ ២០១៣ ដោយសារការធ្វើចំណាកស្រុកនេះ។ ការធ្វើចំណាកស្រុកពីតាមភូមិ ដែលមានទីតាំងនៅកៀកនឹងផ្លូវជាតិ និងដែលប្រជាពលរដ្ឋអាចទទួលបានសេវាក្នុងកម្រិតខ្ពស់ជាងមុន ដូចជា សេវាអគ្គិសនីជាដើម ត្រូវបានសង្កេតថាមានការថយចុះ។ លើសពីនេះ ដោយសារតែអ្នកធ្វើចំណាកស្រុកភាគច្រើន គឺជាមនុស្សដែលទើបពេញវ័យ នេះមានន័យថា នឹងមានការកើនឡើងបន្តិចម្តងៗនូវចំនួនមនុស្សចាស់រស់នៅតំបន់ជនបទ ស្របពេលជាមួយគ្នានេះ និន្នាការដែលឪពុកម្តាយទុកកូនចោលជាមួយជីដូនជីតា ក៏ជាបញ្ហាប្រឈមបន្ថែមមួយទៀត ដែលពាក់ព័ន្ធនឹងការផ្តល់ការការពារដល់កុមារផងដែរ។ ឧទាហរណ៍ក្នុងចំណោមអ្នកធ្វើចំណាកស្រុកដែលមានកូននៅរាជធានីភ្នំពេញ ប្រមាណជា ២០% ទុកកូនរបស់ខ្លួនឱ្យរស់នៅកន្លែងផ្សេងទៀត (MoP, 2012; NIS, 2013a, 2013b)។



រូបភាពទី ៨៖ ភាគរយនៃចំណាកស្រុកតាមទិសដៅ
(WFP, 2017f)

អ្នកធ្វើចំណាកស្រុកមកពីតំបន់ជនបទភាគច្រើន ច្រើនរស់នៅតំបន់ជាយក្រុង ដូចជា កម្មករកាត់ដេរ និងពលករគ្មានជំនាញភាគច្រើន ដែលកំពុងរស់នៅតំបន់ជាយក្រុង។ ខណៈពេលដែលពួកគេមានលក្ខណៈមួយចំនួនដូចគ្នានឹងអ្នកដែលរស់នៅកណ្តាលក្រុងដែរ ភាពងាយរងគ្រោះហាក់បីដូចជាមានកម្រិតខ្ពស់ជាងនៅតំបន់ជាយក្រុង។

## ការពង្រីក និងការអភិវឌ្ឍទីក្រុង

ទិន្និន័យប្រជាសាស្ត្របង្ហាញថា ចំនួនប្រជាជនដែលរស់នៅក្នុងតំបន់ទីក្រុងបន្តមានការកើនឡើង។ ក្នុងចំណោមប្រជាជនកម្ពុជា ១៤,៦៨ លាននាក់ ស្មើនឹង ៣,១៦ លានគ្រួសារ ប្រមាណជា ២,៥ លានគ្រួសារ គឺជាប្រជាជនដែលរស់ក្នុងតំបន់ជនបទ និង ០,៦៦ លានគ្រួសារជាប្រជាជនរស់នៅក្នុងតំបន់ប្រជុំជន (NIS, 2009a)។ ខណៈពេលប្រទេសកម្ពុជាភាគច្រើនរស់នៅតំបន់ជនបទ ចំនួនប្រជាជននៅតំបន់ប្រជុំជនមានការកើនឡើងដល់២១,៤%នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ២០១៣ពី១៩,៥%ក្នុងឆ្នាំ២០០៨។ទីក្រុងភ្នំពេញគឺជាតំបន់ប្រជុំជនធំជាងគេ (ធំជាងតំបន់ប្រជុំជនដទៃទៀតទាំងអស់បញ្ចូលគ្នា)។ ចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញស្មើនឹងប្រមាណ១១,៥%នៃចំនួនប្រជាជនសរុប និងស្មើនឹង ៥៣,៧% នៃចំនួនប្រជាជនដែលរស់នៅក្នុងតំបន់ប្រជុំជន។ គ្រួសារដែលរស់នៅតំបន់ប្រជុំជនមានចំនួនសមាជិក (៤,៨ នាក់) ច្រើនជាងគ្រួសារដែលរស់នៅតំបន់ប្រជុំជនបន្តិចតែប៉ុណ្ណោះ (៤,៦ នាក់ (NIS, 2013a,2013b)។ការកើនឡើងនូវចំនួនប្រជាជនដែលរស់នៅក្នុងទីក្រុង ដោយសារការធ្វើចំណាកស្រុកពីតំបន់ជនបទ ក៏មានភាពពាក់ព័ន្ធគួរឱ្យកត់សម្គាល់ផ្នែកគោលនយោបាយផងដែរ។

”ការកើនឡើងនូវចំនួនប្រជាជនដែលរស់នៅក្នុងទីក្រុង ដោយសារការធ្វើចំណាកស្រុកពីតំបន់ជនបទ ក៏មានភាពពាក់ព័ន្ធគួរឱ្យកត់សម្គាល់ផ្នែកគោលនយោបាយផងដែរ...”

កំណើនល្បឿននៃការពង្រីក និងការអភិវឌ្ឍទីក្រុងនាំឱ្យមានការកើនឡើងនូវចំនួនតំបន់ជាយក្រុងដែលប្រជាពលរដ្ឋមានជីវភាពរស់នៅក្រីក្រ ដែលជាកត្តាបង្កើនគម្លាតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ប្រជុំជន ដោយប្រជាជនដែលមានជីវភាពក្រីក្រជាងគេ និងប្រជាជនដែលមានជីវភាពធូរធារជាងគេ រស់នៅកៀកៗគ្នា។ សម្រាប់អ្នកដែលរស់នៅតំបន់ជាយក្រុង ដែលមិនសូវមានឱកាស ដូចជា អ្នកដែលធ្វើការងារក្នុងរោងចក្រកាត់ដេរ និងរោងចក្រដទៃទៀត ការទទួលបានទឹកស្អាត អនាម័យ និងសេវាសុខភាពនៅតែជាបញ្ហាប្រឈមបើទោះបីជាសេវាទាំងនេះមានលក្ខណៈល្អប្រសើរជាងតំបន់ជនបទយ៉ាងណាក៏ដោយ។ ខណៈពេលដែលល្បឿននៃការពង្រីក និងការអភិវឌ្ឍទីក្រុងនៅបន្តកើតមាន គេរំពឹងថានិន្នាការនេះនឹងដាក់សម្ពាធមកលើលទ្ធភាពទទួលបានសេវា ដែលកំពុងតែជួបបញ្ហាប្រឈមរួចស្រេចទៅហើយនោះ (WFP, 2017f; UNFPA, 2014)។

ការសិក្សាឆ្នាំ ២០១៦ បង្ហាញថា សមត្ថភាពរកប្រាក់ចំណូលរបស់អ្នក ដែលរស់នៅក្នុងរាជធានីភ្នំពេញ សូម្បីតែអ្នកដែលរស់នៅតាមជាយក្រុងគឺខ្ពស់ជាងប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទយ៉ាងហោចណាស់ពីរដង។ទោះជាយ៉ាងណាក៏ដោយខណៈពេលដែលមានគ្រួសារត្រឹមតែ១០%ប៉ុណ្ណោះដែលរស់នៅកណ្ដាលក្រុងភ្នំពេញ កំពុងជាប់បំណុល អត្រានេះកើនឡើងដល់ ៤០% សម្រាប់អ្នកដែលរស់នៅជាយក្រុងភ្នំពេញ និងកើនឡើងរហូតដល់ ៥៥% ក្នុងចំណោមគ្រួសារនៅតាមតំបន់ជនបទ ដែលបង្ហាញថា ការខ្ចីបុលនេះភាគច្រើនកើតមាននៅតំបន់ជនបទ ជាងតំបន់ទីក្រុង ហើយការខ្ចីបុលនេះកើនឡើងដោយសារតែភាពចាំបាច់មួយចំនួន។ លើសពីនេះ ទំហំកម្ចីជាមធ្យមរបស់គ្រួសារដែលរស់នៅជាយក្រុង (ប្រមាណជា ២៧ លានរៀល) គឺខ្ពស់ជាងគ្រួសារដែលរស់នៅកណ្ដាលក្រុង (ប្រមាណជា ១៦ លានរៀល) និងមានទំហំខ្ពស់ឆ្ងាយជាងកម្ចីនៅតំបន់ជនបទ (ប្រមាណជា ៩ លានរៀល)។ សម្រាប់គ្រួសារដែលរស់នៅកណ្ដាលក្រុង និងគ្រួសារដែលរស់នៅជាយក្រុង ប្រាក់កម្ចីទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសុខភាព។ គ្រួសារដែលរស់នៅកណ្ដាលក្រុងក៏ខ្ចីកម្ចីសម្រាប់គាំទ្រដល់ការសិក្សារបស់កូនផងដែរ (WFP, 2017f)។

គ្រួសារដែលរស់នៅជាយក្រុង មានលទ្ធភាពទទួលបានទំនិញ និងសេវាមួយចំនួន ដូចជា សម្ភារៈប្រើប្រាស់ក្នុងផ្ទះ សេវាអគ្គិសនី និងទូរស័ព្ទដៃ ស្រដៀងគ្នានឹងគ្រួសារដែលរស់នៅកណ្ដាលក្រុងផងដែរ។ ប៉ុន្តែមានតែ ១៨% ប៉ុណ្ណោះដែលមានគណនីធនាគារ ឬគណនីជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បើធៀបនឹង ៤១%សម្រាប់គ្រួសារដែលរស់នៅកណ្ដាលក្រុង។ខណៈពេលដែលប្រជាពលរដ្ឋទាំងនេះមានលទ្ធភាពទទួល



រូបភាពទី ៩៖ ភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងភ្នំពេញ
ស្ថានភាព ភាពងាយរងគ្រោះ និងការធ្វើចំណាកស្រុក (WFP, 2017f)

បានទឹកស្អាតប្រើប្រាស់ដូចគ្នាយ៉ាងណាក៏ដោយ គ្រួសារដែលរស់នៅជាយក្រុងមានស្ថានភាពអនាម័យ និងសុខភាពរបស់កុមារ ទាបជាង ដូចដែលត្រូវបានបង្ហាញតាមរយៈអត្រាជំងឺរាករូសខ្ពស់ ពោលគឺ ២១% ធៀបនឹង ១២% (WFP, 2017f)។

ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខស្បៀងនៃគ្រួសារដែលរស់នៅតំបន់ប្រជុំជនវិញ ចំណាយលើស្បៀងអាហាររបស់គ្រួសារដែលរស់នៅកណ្តាលក្រុង គឺខ្ពស់ជាងចំណាយរបស់គ្រួសារដែលរស់នៅជាយក្រុងបន្តិច និងមានការប្រើប្រាស់ទំនិញមួយចំនួន ដូចជា គ្រឿងស្រវឹង និងបារី ច្រើនជាង។ គ្រួសារដែលរស់នៅកណ្តាលក្រុងក៏ចំណាយប្រាក់ច្រើនជាងគ្រួសារដែលរស់នៅជាយក្រុងបន្តិច លើទំនិញមិនមែនជាស្បៀងអាហារផងដែរ ដូចជាការអប់រំរបស់កូន និងការវិនិយោគលើអាជីវកម្មជាដើម។ អាហារបរិភោគរបស់គ្រួសារដែលរស់នៅកណ្តាលក្រុង និងគ្រួសារដែលរស់នៅជាយក្រុងមានលក្ខណៈស្រដៀងគ្នា ទោះជាយ៉ាងនេះក្តី គ្រួសារដែលរស់នៅជាយក្រុងបរិភោគបាយ និងប្រហុកក្នុងបរិមាណច្រើនជាង។ ក្រុមទាំងពីរនេះទិញអាហារពីផ្សារ ក៏ប៉ុន្តែគ្រួសារជាយក្រុងបង្កបង្កើនផលសម្រាប់បរិភោគខ្លួនឯងមានភាគរយខ្ពស់ជាង ពោលគឺ ១៧% ធៀបនឹង ៥,៥% (WFP, 2017f)។

## ស្ថានភាពយេនឌ័រ

សន្ទស្សន៍វិសមភាពយេនឌ័រ (GII) របស់កម្ពុជា (ដែលសំដៅលើការបាត់បង់ការអភិវឌ្ឍមនុស្សដោយសារវិសមភាពរវាងលទ្ធផលដែលសម្រេចបានដោយស្ត្រី និងបុរសពាក់ព័ន្ធនឹងសុខភាពបន្តពូជ សិទ្ធិអំណាច និងសកម្មភាពសេដ្ឋកិច្ច) ដាក់ចំណាត់ថ្នាក់ប្រទេសនេះនៅលេខរៀងទី ១១២ ក្នុងចំណោមប្រទេស ១៥៩ ក្នុងសន្ទទស្សន៍នេះ។ នេះបង្ហាញឱ្យឃើញពីគម្លាតដ៏ធំរវាងលទ្ធផលដែលសម្រេចបានដោយបុរស និងស្ត្រី នឹងបង្ហាញពីភាពចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហានេះ (UNDP, 2016)។ ស្ត្រីបន្តជួបប្រទះនឹង អសមធម៌ក្នុងការទទួលបានសេវាសង្គម ដោយសារបញ្ហានៃភាពក្រីក្រ ពាក់ព័ន្ធនឹងយេនឌ័រ។ ថ្វីបើស្ត្រីបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធស្បៀងអាហារ ដូចជានៅក្នុងផលិតកម្ម ការកែច្នៃ ការរៀបចំ ការបរិភោគ និងការបែងចែកស្បៀងអាហារ ពួកគេភាគច្រើនជាអ្នកដែលជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង។ គ្រួសារកម្ពុជាប្រមាណ ២៧% មានស្ត្រីជាមេគ្រួសារ ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួសារនេះ ច្រើនតែមានជីវភាពក្រីក្រ (FAO, 2016)។ ក្នុងចំណោមគ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រមានជាង ៣០% មានស្ត្រីជាមេគ្រួសារ។

ស្ត្រីបន្តជួបប្រទះនឹង អសមធម៌ក្នុងការទទួលបានសេវាសង្គម ដោយសារបញ្ហានៃភាពក្រីក្រ ពាក់ព័ន្ធនឹងយេនឌ័រ

បញ្ហានានាដូចជា ការអប់រំនៅមានកម្រិត កង្វះការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងអំណាចធ្វើសេចក្តីសម្រេចចិត្ត ការជួញដូរមនុស្ស ការធ្វើចំណាកស្រុក អំពើហិង្សាយេនឌ័រ លទ្ធភាពតិចតួចក្នុងការទទួលបានធនធានសម្រាប់ផលិតកម្ម និងការផ្តល់តម្លៃទាបដល់ការរួមចំណែករបស់ស្ត្រី គឺជាកត្តាចម្បងដែលបង្កផលប៉ះពាល់ដល់សន្តិសុខស្បៀងរបស់ពួកគេ។ លើសពីនេះកាន់តែមានការទទួលស្គាល់ពីភាពងាយរងគ្រោះលើសលប់របស់ស្ត្រី ចំពោះបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ និងភាពចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហានេះ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីដែលហៅកាត់ថា នារីរតនៈទី៤ ២០១៤-២០១៨ របស់ក្រសួងកិច្ចការនារី បានដាក់ចេញនូវការប្តេជ្ញាចិត្ត និងអាទិភាពរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ព្រមទាំងលើកកម្ពស់សមភាពយេនឌ័រ ក្នុងការរៀបចំផែនការសកម្មភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់គោលនយោបាយ និងកម្មវិធីទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការធានាយ៉ាងណាឱ្យក្រសួងស្ថាប័នពាក់ព័ន្ធទទួលបានថវិកាជាតិ ដែលចាំបាច់សម្រាប់ការងារបញ្ជ្រាបយេនឌ័រ។

ផែនការនេះអំពាវនាវឱ្យមានការបង្កើនការយល់ដឹងជាសាធារណៈអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកកម្ពស់វិធានការ ដើម្បីឆ្លើយតបចំពោះករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ការបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងគ្រួសារ និងសហគមន៍ ការទទួលបានសិទ្ធិដីធ្លី និងការគ្រប់គ្រងដីធ្លី តាមរយៈកំណែទម្រង់ដីធ្លី ដែលគិតគូរពីយេនឌ័រ ការបង្កើនលទ្ធភាពទទួលបានការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការលើកកម្ពស់លក្ខខណ្ឌអំណោយផល ដើម្បីឱ្យស្ត្រីកាន់តែមានលទ្ធភាពទទួលបានការបណ្ដុះបណ្ដាលជំនាញការងារ និងធនធានបម្រើផលិតកម្ម (MoWA, 2014)។ ទិដ្ឋភាពយេនឌ័រត្រូវបានឆ្លុះបញ្ចាំងក្នុងយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភស្របតាមខ្លឹមសារនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលទទួលស្គាល់ថា បើទោះបីជាមានការសម្រេចបានវឌ្ឍនភាពក្នុងទសវត្សរ៍មុននេះយ៉ាងណាក៏ដោយ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីនៅទ្រឹង ដោយមានប្រជាពលរដ្ឋមួយភាគធំរស់នៅខាងលើបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ (FAO, 2016; WFP, 2017e; IDS, 2014) ។ ទោះជាយ៉ាងណាក៏ដោយនៅមានចំណុចខ្វះខាតមួយចំនួនក្នុងការតម្រឹមអភិក្រមដែលប្រើប្រាស់សម្រាប់ការអនុវត្តគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីឱ្យមានការគិតគូរពីយេនឌ័រ ហើយចាំបាច់ត្រូវមានការផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជាក់ច្បាស់បន្ថែមទៀត រវាងយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភជាមួយក្របខ័ណ្ឌ និងការប្ដេជ្ញាចិត្តនៅកម្រិតអន្តរជាតិ និងកម្រិតជាតិជុំវិញសមភាពយេនឌ័រ ដូចជា អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ ស្ដីពីសមភាពយេនឌ័រ ដែលបានលើកឡើងផងដែរ អំពីចំណុចសំខាន់ៗ ដែលត្រូវបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤។

## ការអប់រំ

ការអប់រំនៅតែមានសារៈសំខាន់សម្រាប់ការវិនិយោគធនធានមនុស្ស។ ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពជាវិជ្ជមានជាច្រើនក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ កម្រិតបឋមសិក្សា ជាពិសេសនៅតំបន់ជនបទ ដោយអត្រាពិតនៃការសិក្សានៅបឋមសិក្សាកើនឡើងពី ៨១% ក្នុងឆ្នាំ ២០០១ ដល់ ៩៨,៤% ក្នុងឆ្នាំ ២០១៥។ ចាប់ពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ២០១៥ ចំនួនឆ្នាំនៃការរៀនសូត្រក្នុងសាលារៀនជាមធ្យម នៅកម្ពុជាកើនឡើងប្រមានជាពីរឆ្នាំរហូតដល់ ៤,៧ ឆ្នាំ។ គេរំពឹងថាចំនួនឆ្នាំនៃការរៀនសូត្រក្នុងសាលារៀននឹងកើនឡើង ៤,២ ឆ្នាំ រហូតដល់ ១០,៩ ឆ្នាំ (UNDP, 2016)។ ទោះជាយ៉ាងណាក៏ដោយគុណភាពនៃការអប់រំទាមទារឱ្យមានការបន្តកែលម្អបន្ថែមទៀត ដោយសារក្នុងឆ្នាំ ២០១៥ ក្នុងចំណោមសិស្សរៀនថ្នាក់ទី ៦ មានប្រមាណ ៣៩% អាចអានភាសាខ្មែរក្នុងកម្រិតទាបជាងកម្រិតមូលដ្ឋាន (MoEYS, 2015)។

ការមានចំនួនគ្រូដែលទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ក្នុងចំនួនតិចតួច និងអត្រាបោះបង់ចោលការសិក្សាប្រចាំឆ្នាំខ្ពស់ពោលគឺ៥,៥%នៅកម្រិតបឋមសិក្សា១៨,៥%នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ២០,៨% នៅកម្រិតមធ្យមសិក្សាទុតិយភូមិ (MoEYS, 2017) គឺជាបញ្ហាប្រឈមបន្ថែមពីលើបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការចូលរៀន និងអវត្តមានរបស់សិស្ស។ សមាហរណកម្មអាស៊ានក្នុងឆ្នាំ ២០១៥ និងបំណងប្រាថ្នារបស់ប្រទេសកម្ពុជា ដែលចង់ក្លាយជាប្រទេសចំណូលមធ្យមត្រឹមឆ្នាំ ២០៣០ តម្រូវឱ្យប្រទេសកម្ពុជាបោះទុនវិនិយោគយ៉ាងច្រើនក្នុងវិស័យអប់រំ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនថវិកាជាតិសម្រាប់វិស័យអប់រំប្រមាណ ១៧% ដល់ ២,៣៨ ទ្រីលាន (លានលាន) រៀលក្នុងឆ្នាំ ២០១៧ ២,០២ ទ្រីលានរៀលក្នុងឆ្នាំ ២០១៦ (MEF, 2016a; MEF, 2017)។ ពាក់ព័ន្ធនឹងលទ្ធផលនៃការអប់រំវិញ ផលធៀបរវាងសិស្សស្រី និងប្រុសគឺប្រមាណ ១:២ ខណៈពេលដែលមានស្ត្រីពេញវ័យត្រឹមតែ ១៣,២% ប៉ុណ្ណោះ ដែលរៀនបានយ៉ាងហោចណាស់កម្រិតមធ្យមសិក្សា បើធៀបនឹង ២៦,១% សម្រាប់មនុស្ស

ពេញវ័យជាបុរស។ ការចូលរួមរបស់ស្ត្រីក្នុងទីផ្សារការងារមានកម្រិតទាបត្រឹម ៧៥,៥% បើធៀបនឹង ៨៦,៧% សម្រាប់បុរស (UNDP, 2017)។

### កត្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៣

ដើម្បីបង្កើនសក្តានុពលរបស់យុវជន និងប្រជាជនរស់នៅទីក្រុងដែលកំពុងកើនចំនួន ចាំបាច់ត្រូវមានការវិនិយោគលើការកសាងសមត្ថភាព ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើក្មេងជំទង់ និងការសម្រេចឱ្យបាននូវលទ្ធផលអាហារូបត្ថម្ភ។ ទន្ទឹមគ្នានេះ ការផ្ទេរចំណាកស្រុកដ៏ឆាប់រហ័សទាមទារឱ្យមានការពិនិត្យតាមដានលើផលប៉ះពាល់ និងចាំបាច់ត្រូវមានការឆ្លើយតបចំពោះបញ្ហាអតុល្យភាពយេនឌ័រ ដែលនៅសេសសល់។

## ៣.៤ និន្នាការបច្ចេកវិទ្យា

ការកើនឡើងយ៉ាងឆាប់រហ័សនូវការមាន និងការទទួលបានបច្ចេកវិទ្យា ដែលមានតម្លៃទាប គឺជាឱកាសដ៏ប្រសើរ ដើម្បីប្រទេសកម្ពុជាបង្កើនការវិនិយោគលើធនធានមនុស្ស និងបង្កើនការយល់ដឹងអំពីបញ្ហាសំខាន់ៗ។ នៅក្នុងប្រទេសកម្ពុជាការប្រើប្រាស់វិទ្យុ និងទូរទស្សន៍ ដើម្បីទទួលបានព័ត៌មានមានការថយចុះ ហើយទន្ទឹមគ្នានេះ ការប្រើប្រាស់អ៊ីនធឺណែត និងទូរសព្ទដៃ មានការកើនឡើង។ ការសិក្សាមួយដែលធ្វើឡើងដោយ BBC Media Action (2014) បានរកឃើញថា យុវជន (អាយុ ១៥ ដល់ ២៤) ភាគច្រើននៅកម្ពុជាមើលទូរទស្សន៍ (៩២%) ស្តាប់វិទ្យុ (៩២%) និងប្រើទូរសព្ទដៃ (៩៦%)។ ការប្រើប្រាស់អ៊ីនធឺណែត មានការកើនឡើង។ យុវជនមួយភាគបីនៅក្នុងប្រទេសនេះ ដែលភាគច្រើនរស់នៅតំបន់ទីក្រុងមានអិនធឺណែតប្រើប្រាស់។ ពួកគេបានលើកឡើងថា ពួកគេប្រើប្រាស់អ៊ីនធឺណែតដើម្បីទទួលបានព័ត៌មាន (៧៣%) និងបណ្តាញទំនាក់ទំនងសង្គម (៦៣%) (BBC Media Action 2014)។

ខណៈពេលដែលបច្ចេក-វិទ្យាអាចបំពេញ តួនាទីជាមូលដ្ឋានដ៏សំខាន់ ដើម្បីជំរុញឱ្យមានការផ្សព្វផ្សាយ ព័ត៌មាន និងផ្តល់លទ្ធភាពឱ្យមាន ការពង្រីក ការគ្របដណ្តប់ លើប្រជាជនឱ្យបាន កាន់តែច្រើននាក់ ក៏ដូចជា ក្រុមគោលដៅជាក់លាក់ បញ្ហាថ្មីមួយដែលកើតឡើង គឺការជឿទុកចិត្តលើ ព័ត៌មានដែលមាន។ ការអង្កេតលើបច្ចេកវិទ្យានៅកម្ពុជា បានរកឃើញថា អ្នកឆ្លើយតបសំណួរប្រមាណ ៥៥% ជឿ




រូបភាពទី ១០៖ ទិដ្ឋភាពរួមនៃស្ថានភាពប្រព័ន្ធផ្សព្វផ្សាយក្នុងខេត្តរតនគិរី ព្រៃវែង និងភ្នំពេញ (BBC Media Action, 2014)

ទុកចិត្តព័ត៌មានតាម ហ្វេសប៊ុក ខណៈពេលដែល ៤៥% ទៀតមិនជឿទុកចិត្ត ឬជឿទុកចិត្ត “ខ្លះ” ប៉ុណ្ណោះ។ ការមិនជឿទុកចិត្តព័ត៌មានពីប្រភពហ្វេសប៊ុក មានកម្រិតខ្ពស់ជាងគេ ពាក់ព័ន្ធនឹងការអានព័ត៌មាន ដែលក្នុងនោះអ្នកឆ្លើយតបប្រមាណ ៣០% បានលើកឡើងថា ពួកគេបានទទួលព័ត៌មាន “ក្លែងក្លាយ” តាមរយៈហ្វេសប៊ុក។ ស្របពេលដែលប្រជាជនកម្ពុជាកាន់តែប្រើហ្វេសប៊ុកច្រើនឡើងៗ ដូចជា មធ្យោបាយសម្រាប់ទទួលបានដំណឹង និងព័ត៌មានផ្សេងទៀតផងនោះ ភាពចាំបាច់ដើម្បីធានាឱ្យមានការផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបានមានសារៈសំខាន់យ៉ាងខ្លាំង ជាពិសេសពាក់ព័ន្ធនឹងក្មេងជំទង់ និងយុវជន ដូចជា ព័ត៌មានអំពីបញ្ហាសុខភាព និងអាហារូបត្ថម្ភជាដើម (BBC Media Action, 2014; WFP, 2017a)។

### កត្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៤

ដោយសារប្រជាពលរដ្ឋ ជាពិសេស យុវជន ទទួលបានបច្ចេកវិទ្យាកាន់តែច្រើនជាងមុន និងកាន់តែយល់ដឹងច្រើនជាងមុនអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ឱកាសបង្កើនការវិនិយោគលើធនធានមនុស្ស ក៏មានកាន់តែច្រើនផងដែរ តាមរយៈការបង្កើត និងបង្កលក្ខណៈងាយស្រួលឱ្យពួកគេទទួលបានព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភពីប្រភពដែលអាចជឿទុកចិត្តបាន។

## ៣.៥ និន្នាការបរិស្ថាន

ប្រទេសកម្ពុជា ជាប្រទេសដែលសំបូរធនធានបរិស្ថានចម្រុះ។ ការរេចរិលបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងការកើតឡើងនូវគ្រោះមហន្តរាយប្រចាំឆ្នាំនៅកម្រិតទាប ដូចដែលត្រូវបានកត់សម្គាល់ក្នុងផ្នែក ៤.៤ ស្តីពីនិន្នាការស្ថិរភាពកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានមកលើលទ្ធភាពរបស់សហគមន៍ងាយរងគ្រោះ ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស។ អ្នកដែលទទួលរងផលប៉ះពាល់ម្តងហើយម្តងទៀតប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់ ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ដូចជាការខ្ចីបុលបន្ថែមជាដើម (WFP, 2017b) ហើយក្នុងពេលជាមួយគ្នាហានិភ័យដែលបង្កឡើងដោយសារការរេចរិលធនធានធម៌ជាតិ អាចបង្កផលប៉ះពាល់ជាអវិជ្ជមានមកលើនិរន្តរភាពសេដ្ឋកិច្ច។

ការប៉ាន់ប្រមាណជាផ្លូវការពីក្រសួងបរិស្ថានបង្ហាញថា គម្របព្រៃឈើបានថយចុះពីប្រមាណ ៦០% ក្នុងឆ្នាំ ២០០៦ មកនៅតិចជាង ៤៧% ក្នុងឆ្នាំ ២០១៤ ហើយព្រៃឈើដែលនៅសេសសល់ត្រូវប្រឈមនឹងការកាប់បំផ្លាញ។ ទន្ទឹមគ្នានេះ ក៏មានការបាត់បង់តំបន់ដីសើមជាច្រើនផងដែរ (MoE, 2016)។ ការគ្រប់គ្រងធនធានធម្មជាតិពុំបានល្អ ការវិនិយោគតិចតួចលើការគ្រប់គ្រងប្រកបដោយចីរភាព និងការពង្រីកដីសម្រាប់ផលិតកម្មកសិកម្ម ជាកត្តារួមចំណែកធ្វើឱ្យមាននិន្នាការនេះកើតមានឡើង (World Bank & ADB, 2015; World Bank, 2017b)។

ដោយសារតែ មានប្រជាពលរដ្ឋក្រីក្រនៅជនបទ ប្រមាណ ៨០% ពឹងអាស្រ័យលើ បរិស្ថានធម្មជាតិ និងកសិកម្មសម្រាប់ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ (Climate Investment Funds, 2016) ការគ្រប់គ្រងធនធានធម្មជាតិទាំងនេះប្រកបដោយចីរភាព ហើយក្នុងពេលជាមួយគ្នានៅតែអាចធានាបាននូវការអនុវត្តវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួល

អាកាសធាតុមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនាពេលអនាគត។ ផ្សារភ្ជាប់ជាមួយចំណុចនេះ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលធន់ទ្រាំទៅនឹងទឹកជំនន់ ការធានាឱ្យមានស្តង់ដារអប្បបរមាសម្រាប់ការសាងសង់សំណង់នានា និងធានាឱ្យមានការប្រើប្រាស់ផែនការទីក្រុង ដើម្បីបង្កើនភាពធន់ទ្រាំ មានសារៈសំខាន់សម្រាប់កាត់បន្ថយផលប៉ះពាល់ និងការខាតបង់ដែលបង្កឡើងដោយគ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស (FAO, et al., 2016; UNDP, 2014)។

### គន្លាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៥

ការរេចរិលបរិស្ថាន ការប្រែប្រួលអាកាសធាតុ ការកើតឡើងនូវគ្រោះមហន្តរាយជារៀងរាល់ឆ្នាំនៅកម្រិតមូលដ្ឋាន កំពុងបង្កផលប៉ះពាល់អវិជ្ជមានលើលទ្ធភាពរបស់សហគមន៍ ដែលងាយរងគ្រោះក្នុងការទប់ទល់ដែលតម្រូវឱ្យមាន ការអនុវត្តគោលនយោបាយបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធាន ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

# ៤. ការវិភាគលើស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

កំណើនសេដ្ឋកិច្ច ការធ្វើពិពិធកម្មសេដ្ឋកម្ម និងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគួរឱ្យកត់សម្គាល់រួមគ្នាធ្វើឱ្យមានការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងកម្រិតមួយខ្ពស់ ដូចដែលត្រូវបានឆ្លុះបញ្ចាំងក្នុងពិន្ទុនៃសន្ទស្សន៍ភាពអត់ឃ្លានពិភពលោកឆ្នាំ ២០១៧។ បើទោះបីជាប្រទេសកម្ពុជាត្រូវបានដាក់ពិន្ទុថានៅកំពុងជួបប្រទះនឹងបញ្ហាភាពអត់ឃ្លានច្រើនយ៉ាងណាក៏ដោយ មានការរីកចម្រើនយ៉ាងឆាប់រហ័សជាច្រើនកំពុងកើតមាននៅក្នុងប្រទេសកម្ពុជា ហើយឥឡូវនេះ ប្រទេសកម្ពុជាកំពុងឈានទៅរកចំណាត់ថ្នាក់ជាប្រទេសដែលមានបញ្ហាភាពអត់ឃ្លានកម្រិតមធ្យម។ ប្រទេសកម្ពុជា គឺជាប្រទេសដែលថយចុះភាគរយខ្ពស់ជាងគេសម្រាប់ប្រទេស ដែលត្រូវបានវាស់វែងថាមានភាពអត់ឃ្លានចាប់ពីកម្រិតធ្ងន់ធ្ងរឡើងទៅ នៅក្នុងការដាក់ពិន្ទុសន្ទស្សន៍ភាពអត់ឃ្លានសកលលោក សម្រាប់រយៈពេលពីឆ្នាំ ២០០០-២០១៧ (von Grebmer, et al., 2017) (រូបភាពទី១១)។

## ៤.១ និន្នាការនៃភាពមានស្បៀង

### ផលិតកម្មស្បៀង និងទីផ្សារស្បៀង

ផលិតកម្មកសិកម្ម ដែលមានការផ្តោតការយកចិត្តទុកដាក់សំខាន់លើដំណាំស្រូវ និងបន្ទាប់មកលើដំណាំរួមផ្សំដទៃទៀត បានសម្រេចកំណើនលឿនជាងកំណើនចំនួនប្រជាជន និងតម្រូវការរបស់ប្រជាជនដែលនាំឱ្យស្ថានភាពនៃការមានស្បៀងមានភាពល្អប្រសើរជាងមុន។ ដំណាំស្រូវ គឺជាដំណាំដែលត្រូវបានដាំដុះច្រើនជាងគេក្នុងផលិតកម្មកសិកម្ម ហើយបច្ចុប្បន្ននេះការដាំដុះដំណាំស្រូវស្មើនឹងប្រមាណ ៧ ២% នៃសកម្មភាពដាំដុះសរុប (MAFF, 2017; NIS, 2009b, 2014)។ ប្រទេសកម្ពុជាអាចផលិតស្រូវបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងស្រុកចាប់តាំងពីឆ្នាំ ១៩៩៦ មក ហើយផលិតកម្មស្រូវបានកើនឡើងពីប្រមាណ ៤ លានតោន ដល់ ជិត១០ លានតោនពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៦។ ទន្ទឹមគ្នានេះ




រូបភាពទី ១១៖ សន្ទស្សន៍ភាពអត់ឃ្លានសកលលោក វឌ្ឍនភាពចាប់តាំងពីឆ្នាំ ២០០០ មក (von Grebmer, et al., 2017)

ការនាំចេញស្រូវក្នុងអត្រាមួយខ្ពស់ ធ្វើឱ្យតួលេខនាំចេញកើនឡើងពីត្រឹមក្រោមកន្លះលានតោន រហូតដល់ប្រមាណ ៤,៧ លានតោន សម្រាប់ការនាំចេញចន្លោះពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៦ (World Bank, 2017b; MAFF, 2017)។







រូបភាពទី ១២៖ ផលិតកម្មស្រូវ និងផលិតកម្មដំណាំឧស្សាហកម្មដទៃ (MAFF, 2017; NIS, 2014)

ទោះបីជាផលិតកម្មស្រូវមានការកើនឡើងយ៉ាងណាក៏ដោយ បើនិយាយពីទស្សន៍នៃភាពមានស្បៀង ការផ្តោតតែលើដំណាំណាមួយបែបនេះ មានន័យថា កម្ពុជាបានធ្វើពិពិធកម្មដំណាំរបស់ខ្លួនក្នុងកម្រិតមួយតិចតួចនៅឡើយ។ ការផ្តោតលើដំណាំតិចមុខបែបនេះ ត្រូវបានឆ្លុះបញ្ចាំងក្នុងនិន្នាការនៃរបបអាហារតាមគ្រួសារ ដែលក្នុងនោះ បើទោះជាស្បៀងអាហារកាន់មានច្រើននៅតាមទីផ្សារយ៉ាងណាក៏ដោយ អង្ករនៅតែជាអាហារសំខាន់ជាងគេក្នុងរបបអាហាររបស់ប្រជាពលរដ្ឋ។ បញ្ហាកង្វះអាហារូបត្ថម្ភបានថយចុះគួរឱ្យកត់សម្គាល់

ពី ២៩,២% (ក្នុងចំណោមប្រជាជនសរុប) ក្នុងឆ្នាំ ២០០០ មកនៅ ១៥,៣% ក្នុងឆ្នាំ ២០១៥ (FAO, 2017b) ដែលផ្អែកទៅតាម តារាងតុល្យការស្បៀងអាហារនៅថ្នាក់ជាតិ ដែលនេះបង្ហាញថា ការរីកចម្រើនផ្នែកផលិតកម្មស្បៀង គួបផ្សំនឹងការនាំចូល និងការនាំចេញ កំពុងបង្កភាពងាយស្រួលឱ្យប្រជាពលរដ្ឋកាន់តែច្រើននាក់ អាចបំពេញតម្រូវការថាមពលរបស់ខ្លួន។




រូបភាពទី ១៣៖ បញ្ហាកង្វះអាហារូបត្ថម្ភ ២០០៤-២០១៤ (FAO, 2017b; NIS, 2005, 2009b, 2014)

## ការដាំដុះបន្លែ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

ការដាំដុះដំណាំរួមផ្សំ (ពោត ដំឡូងមី ដំឡូងជ្វា បន្លែ និងសណ្ដែកបាយ) មានការកើនឡើងជាង ៥% នៅក្នុងអំឡុងឆ្នាំ ២០១៥-២០១៦ ស្របពេលនឹងមានការបន្តកើនឡើងផ្ទៃដីផលិតកម្មសម្រាប់ដំណាំទាំងនេះ។ ចេញពីស្ថិតិផ្លូវការ គេពិបាកកំណត់ថា តើការកើនឡើងទាំងនេះប៉ុន្មានពាក់ព័ន្ធនឹងដំណាំ ដែលត្រូវបានប្រើប្រាស់ផ្ទាល់ជាស្បៀងអាហារ និងថាតើដំណាំប៉ុន្មានដែលប្រើប្រាស់ជាចំណីសត្វ និង/ឬកែច្នៃសម្រាប់ការនាំចេញ។ ផ្ទៃដីផលិតកម្មសម្រាប់ដំណាំឧស្សាហកម្មដូចជាសណ្ដែកសៀង ស្វាយចន្ទី ល្ង អំពៅ ក្រចៅ និងថ្នាំជក់ មានការប្រែប្រួលខុសៗគ្នា និងមានការថយចុះ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គេមិនអាចកំណត់ឱ្យដឹងថា តើការផ្លាស់ប្ដូរផ្ទៃដីផលិតកម្មទាំងនេះបង្កផលប៉ះពាល់ប៉ុណ្ណា ដល់ភាពមានស្បៀង និងការទទួលបានស្បៀង ទូទាំងប្រទេសនោះឡើយ។ ការកីនឡីងនូវផ្ទៃដីសម្រាប់ដាំដំឡូងមី ដលែជាដំណាំត្រូវបានប្រើប្រាស់ភាគច្រើនសម្រាប់ការកែច្នៃសម្រាប់ឧស្សាហកម្ម និងការនាំចេញ អាចបង្កផលប៉ះពាល់ដល់ការដាំដំណាំចម្រុះមុខតាមគ្រួសារ ហើយដំណាំនេះក៏ទំនងជានាំឱ្យមានការកើនឡើងនូវផ្ទៃដីសម្រាប់ដាំដំណាំរួមផ្សំផងដែរ។




រូបភាពទី ១៤៖ ការផ្គត់ផ្គង់ស្បៀង និងរបបអាហារចម្រុះ (Development Initiatives, 2017; IFReDI, 2012)

បើតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១៧) ការចិញ្ចឹមសត្វបានសម្រេចលើសពីគោលដៅ ដោយចំនួនសត្វមានការកើនឡើង ដែលនិន្នាការនេះគឺជានិន្នាការរយៈពេលវែង ដែលកើតមានជាយូរមកហើយ។ ចំនួនសត្វសុរប ដែលចិញ្ចឹមដោយកសិករខ្នាតតូចមានការកើនឡើង ៣,៥% បើទោះបីជាចំនួនសត្វគោថយចុះ ០,២% យ៉ាងណាក៏ដោយ។ ចំនួនបក្សីចិញ្ចឹមមានការកើនឡើងខ្លាំង ប្រមាណ ៦,៤% ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៦។ ចំនួនសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មពោលគឺសត្វគោ និងសត្វជ្រូកក៏មានការកើនឡើងខ្លាំងផងដែរ។ ចំនួនបក្សីដែលចិញ្ចឹមតាមផ្ទះមានការថយចុះ ទន្ទឹមគ្នានឹងមានការកើនឡើងយ៉ាងច្រើននូវចំនួនបក្សីនាំចូល។ ផលិតកម្មត្រីពីគ្រប់ប្រភពទាំងអស់ដូចជាការចិញ្ចឹមត្រីតជាលក្ខណៈគ្រួសារតាមតំបន់នេសាទ និងតាមវាលស្រែ ក៏ដូចជាវារីវប្បកម្មមានការកើនឡើងតិចតួចពីឆ្នាំ ២០១៥ ដល់ ឆ្នាំ ២០១៦ (MAFF 2017)។

នៅដើមឆ្នាំ២០១៦ទិន្នន័យតម្លៃត្រូវបានប្រមូលពីទីផ្សារចំនួន៩៥នៅទូទាំងប្រទេសដើម្បីផ្ដល់ព័ត៌មានដល់ការវិភាគការចំណាយលើរបបអាហារ ក្នុងគោលបំណងកំណត់ពីលទ្ធភាពចាយវាយទិញអាហារដែលមានអាហារូបត្ថម្ភនៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា។ ផ្សារចំនួន ៩៥ ត្រូវបានជ្រើសរើសជាសំណាកគំរូចេញពីផ្សារសរុបចំនួន ២០២ ដែលបានចុះបញ្ជីនៅការិយាល័យស្ថិតិតម្លៃនៃនាយកដ្ឋានផែនការ និងស្ថិតិក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងចំណោមផលិតផលអាហារក្នុងបញ្ជីចំនួន៥០០ មុខ ការអង្កេតនេះអាចប្រមូលព័ត៌មានតម្លៃផលិតផលចម្លោះពី ២៣២ ដល់ ៣៤២ មុខ ក្នុងផ្សារនីមួយៗ ដែលឆ្លុះបញ្ចាំងពីភាពអាចរកបាននូវផលិតផលក្នុងចំនួនខុសៗគ្នាពីផ្សារមួយទៅផ្សារមួយទៀតទូទាំងប្រទេស។




រូបភាពទី ១៥៖ ផលិតផលស្បៀងអាហារ ដែលមានក្នុងផ្សារចំនួន ៩៥ ទូទាំងប្រទេសកម្ពុជា (WFP, 2017d)

## កសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ

ករណីសិក្សាដែលត្រូវបានរៀបចំកាលពីពេលថ្មីៗនេះដោយ FAO (2017) បង្ហាញពីហេតុផលវិជ្ជមានសម្រាប់លើកទឹកចិត្តឱ្យមានការធ្វើកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភនៅកម្ពុជា។ ការលើកទឹកចិត្តឱ្យមានរបបអាហារចម្រុះ ដោយមានការគាំទ្រពីផលិតកម្មចម្រុះ ជាមួយនឹងលទ្ធផលរកឃើញបង្ហាញថា ការប្រើប្រាស់ «អាហារដែលមានភាពប្រសើរសម្រាប់អនាគត» ពោលគឺអាហារដែលសំបូរដោយអាហារូបត្ថម្ភ ធន់ទ្រាំទៅនឹងអាកាសធាតុ មានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច និងអាចរកបាននៅក្នុងស្រុក ឬអាចបន្សាំទៅនឹងស្ថានភាពក្នុងស្រុក និងការធ្វើកសិកម្មចម្រុះ ដូចជា ការដាំដំណាំចម្រុះ ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីអាចបង្កើនភាពចម្រុះនៃអាហារបាន។ លើសពីនេះ ការផលិតអាហារតាមផ្ទះដែលផ្ដល់ឱ្យកសិករខ្នាតតូចនូវជំនាញ និងធនធានសម្រាប់ផលិតអាហារដែលនាំមកនូវសុខភាពល្អជាច្រើនប្រភេទ ពេញមួយឆ្នាំ ក៏ដូចជាពង្រឹងទំនាក់ទំនងរបស់កសិករទាំងនេះជាមួយនឹងទីផ្សារ ជាកត្តាអាចជួយលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ពួកគេ។ ភ្ជាប់ជាមួយនឹងចំណុចនេះ ការកែលម្អទៅលើវិធីរក្សាទុកអាហារឱ្យបានយូរ និងការកែច្នៃអាហារដើម្បីរក្សាអាហារូបត្ថម្ភ បង្កើនរយៈពេលលក់បានយូរ និងសុវត្ថិភាពអាហារ ក៏នឹងមានឥទ្ធិពលជាវិជ្ជមានលើសន្តិសុខស្បៀងផងដែរ គួបផ្សំជាមួយនឹងការបង្កើនការយល់ដឹងអំពីអាហារូបត្ថម្ភ និងសុវត្ថិភាពអាហារសម្រាប់អ្នកផលិត និងសម្រាប់អតិថិជន ដោយដាក់ឱ្យប្រើប្រាស់នូវបទដ្ឋានម្ហូបអាហារ។

ដោយសារតែស្ត្រីក្នុងវិស័យកសិកម្មមានចំនួនច្រើន ការគាំទ្រដល់ការទទួលបានអាហារដែលមានសុវត្ថិភាពសម្រាប់ម្តាយ និងការបង្កើនការយល់ដឹងដល់ពួកគេអំពីសុវត្ថិភាពអាហារ និងការថែទាំកូន ក៏ដូចជាការពង្រឹងសិទ្ធិអំណាចក្នុងការអប់រំរបស់ស្ត្រី ដើម្បីផ្តល់លក្ខណៈងាយស្រួលឱ្យមានការចូលរួមពីពួកគេ ក៏អាចជួយសម្រេចលទ្ធផលជាវិជ្ជមានជុំវិញសន្តិសុខស្បៀង និងអាហារូបត្ថម្ភផងដែរ។ ចុងក្រោយ ចាំបាច់ត្រូវមានការលើកកម្ពស់ការធ្វើសមាហរណកម្ម រវាងវិស័យកសិកម្ម វិស័យសុខាភិបាល វិស័យទឹកស្អាត និងអនាម័យ ដើម្បីធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភកាន់តែមានលក្ខណៈប្រសើរ ជាងមុន ក៏ដូចជាតាមរយៈកម្មវិធីអប់រំ អំពីផលិតកម្មស្បៀង និងការប្រើប្រាស់អាហារ ដើម្បីពង្រឹងការយល់ដឹងអំពីអាហារូបត្ថម្ភ (FAO, 2017a)។

### គន្លឹះយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៦

ផលិតកម្មកសិកម្ម ដែលភាពរឹងមាំបានគាំទ្រឱ្យមានការលើកកម្ពស់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ បច្ចុប្បន្ននេះចាំបាច់ត្រូវមានការបង្កើនការយកចិត្តទុកដាក់លើគុណភាព ភាពចម្រុះ ភាពធន់ទ្រាំ និងការគិតគូរពីអាហារូបត្ថម្ភក្នុងការធ្វើកសិកម្ម។

## ៤.២ និន្នាការនៃការទទួលបានស្បៀង

កំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់នៅកម្រិតម៉ាក្រូ បានបង្កលក្ខណៈឱ្យមានការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រនៅកម្រិតគ្រួសារ។ អត្ថប្រយោជន៍ដែលបានពីកំណើននេះពុំត្រូវបានបែងចែកឱ្យបានស្មើគ្នានោះឡើយ ដែលនេះរំលេចឱ្យឃើញពីភាពពាក់ព័ន្ធនៃរបៀបវារៈឆ្នាំ ២០៣០ ដែលមានគោលបំណង “មិនទុកអ្នកណាម្នាក់ចោល”។

### ការកាត់បន្ថយភាពក្រីក្រ

ភាគរយប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិបានថយចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកនៅ ១៣,៥% ក្នុងឆ្នាំ ២០១៤ នេះបើតាមស្ថិតិផ្លូវការ អំពីចំនួនប្រជាពលរដ្ឋក្រីក្រ (MEF, 2016b)។ ប្រទេសកម្ពុជាក៏បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រពហុសមាសភាគ ដែលខុសពីភាពក្រីក្រដែលផ្អែកទៅលើប្រាក់ចំណូល។ សន្ទស្សន៍នៃភាពក្រីក្រពហុសមាសភាគ (MPI) នេះ រាប់បញ្ចូលផងដែរនូវ ការលំបាកផ្នែកសុខភាព ការអប់រំ និងជីវភាពនៅក្នុងកម្រិតគ្រួសារ។ សន្ទស្សន៍នៃ MPI របស់កម្ពុជាថយចុះពី ០,២១១ ក្នុងឆ្នាំ ២០១១ មក ០,១៥០ ក្នុងឆ្នាំ ២០១៤ ហើយប្រសិនបើរាប់ជាចំនួនមនុស្សវិញ ភាពក្រីក្រពហុសមាសភាគថយចុះពី ៤៦,៨% មកនៅ ៣៣,៨% ក្នុងរយៈពេលដូចគ្នា។ បច្ចុប្បន្ននេះ ចំនួនប្រជាពលរដ្ឋដែលស្ថិតនៅក្នុងភាពក្រីក្រពហុសមាសភាគមាន ៣១,៦% នៃចំនួនប្រជាជនសរុប ពោលគឺខ្ពស់ជាងចំនួនប្រជាពលរដ្ឋក្រីក្រផ្អែកទៅលើប្រាក់ចំណូល ដោយសារតែមានការបញ្ចូលសមាសភាគបន្ថែមមួយចំនួនទៅក្នុងការគណនា។ តួលេខទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថា ប្រជាពលរដ្ឋដែលក្រីក្រ ច្រើនជួបនឹងផលប៉ះពាល់ជាអវិជ្ជមាននៅពេលដែលមានវិបត្តិនានាកើតឡើង ដូចជានៅពេលដែលមានជំងឺឈឺថ្កាត់ ជាដើម។ ក្រៅពីកង្វះប្រាក់ចំណូលដើម្បីបំពេញតម្រូវការរបស់ខ្លួន ពួកគេក៏ពុំមានលទ្ធភាពទទួលបានសេវាថែទាំសុខភាព ឬបន្តឱ្យកូននៅរៀនដែរ ដែលធ្វើឱ្យពួកគេកាន់តែមានការពិបាកក្នុងការងើបចេញ ឬរំដោះខ្លួនចេញពីភាពក្រីក្រ និងនាំឱ្យពួកគាត់ប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់ដែលអាចនាំមកនូវផលប៉ះពាល់កាន់តែអវិជ្ជមាន (UNDP, 2016)។

ស្របជាមួយនឹងកិច្ចខិតខំប្រឹងប្រែងវាស់វែងភាពក្រីក្រ ដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និន្នាការភាពក្រីក្រស្រដៀងគ្នានេះត្រូវបានបង្ហាញក្នុងទិន្នន័យរបស់ធនាគារពិភពលោក ដែលបានកំណត់នូវបន្ទាត់ភាពក្រីក្រថ្មីមួយ ដែលមានលក្ខណៈខុសគ្នាបន្តិចពីបន្ទាត់នៃភាពក្រីក្ររបស់រដ្ឋាភិបាល ប៉ុន្តែបង្ហាញឱ្យឃើញពីនិន្នាការដូចគ្នា។ ការវាយតម្លៃភាពក្រីក្រដែលធ្វើឡើងដោយធនាគារពិភពលោក (២០១៣) គូសបញ្ជាក់ថា បើទោះបីជាអត្រានៃភាពក្រីក្រមានការថយចុះគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ ដែលមូលហេតុចម្បងគឺដោយសារវិស័យកសិកម្ម និងការកើនឡើងប្រាក់ឈ្នួលនៅតំបន់ជនបទ ប្រជាពលរដ្ឋកម្ពុជាមួយភាគធំ បានងើបចេញផុតពីបន្ទាត់នៃភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ដែលធ្វើឱ្យពួកគាត់ជាច្រើនងាយរងគ្រោះខ្លាំង ប្រសិនបើមានវិបត្តិនានាកើតមានឡើង។ ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការប្រៀបធៀបបន្ទាត់នៃភាពក្រីក្ររបស់ធនាគារពិភពលោក និងបន្ទាត់នៃភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងបានរកឃើញថា អត្រានៃភាពក្រីក្រងាយនឹងប្រែប្រួលទៅតាមការផ្លាស់ប្តូរបន្តិចបន្តួច ក្នុងកម្រិតនៃភាពក្រីក្រ ដែលមានន័យថា គ្រួសារកម្ពុជាដែលកំពុងរស់នៅលើបន្ទាត់នៃភាពក្រីក្រតែបន្តិច ("អ្នកជិតក្រ") ងាយរងគ្រោះខ្លាំង ដោយសារវិបត្តិខាងក្រៅ (ដូចជា ការឡើងថ្លៃស្បៀងអាហារ និងទំនិញប្រើប្រាស់ជាមូលដ្ឋាន ការចំណាយលើបញ្ហាសុខភាពដែលកើតឡើងដោយមិនបានរំពឹងទុក និងគ្រោះមហន្តរាយដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ)។ ដូចនេះ គេចាំបាច់ត្រូវគិតពិចារណាអំពីភាពងាយរងគ្រោះទាំងនេះក្នុងការតាក់តែងគោលនយោបាយនានា (ADB, 2014)។

## (ខ) សមភាពប្រាក់ចំណូល

បើទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងនេះ ដោយសារកំណើននៅថ្នាក់ជាតិយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅបន្តជួបប្រទះនឹងបញ្ហាប្រឈមក្នុងការកាត់បន្ថយភាពក្រីក្រ និងវិសមភាព។ បញ្ហាប្រឈមទាំងនេះ រួមមាន ការសម្រេចបានវឌ្ឍនភាពពុំបានដូចៗគ្នានៅទូទាំងប្រទេស និងក្នុងចំណោមក្រុមប្រជាសាស្ត្រ និងក្រុមសង្គមសេដ្ឋកិច្ចផ្សេងៗគ្នា ស្របពេលដែលប្រទេសកម្ពុជានៅមានភាពយឺតយ៉ាវនៅឡើយក្នុងការសម្រេចទៅតាមសូចនាករអភិវឌ្ឍន៍មនុស្សជាច្រើន។ ចាំបាច់ត្រូវតែមានការធានាយ៉ាងណាឱ្យមានការបែងចែកការអភិវឌ្ឍន៍មនុស្សប្រកបដោយសមធម៌ ពោលដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបអាចទទួលបានភាគផលពីវឌ្ឍនភាពដែលសម្រេចបាន ជាពិសេស ត្រូវមានការគិតគូរផ្តល់ភាគផលទាំងនេះទៅដល់ស្ត្រី។ ដើម្បីសម្រេចតាមគោលបំណង "មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ" នៃរបៀបវារៈឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងដើម្បីផ្តល់សេវាទៅដល់អ្នកដែលស្ថិតនៅក្រោយគេមុនគេ ចាំចាច់ត្រូវមានការខិតខំប្រឹងប្រែងផ្តល់អាទិភាពដល់ក្រុមដែលជួបការលំបាក ដោយត្រូវសម្លឹងឱ្យហួសពីប្រជាជនធម្មតា ដើម្បីស្វែងរកក្រុមទាំងនោះ កន្លែងដែលពួកគាត់នៅ និងអ្វីដែលជាតម្រូវការរបស់ពួកគាត់។ ជារឿយៗ ក្រុមដែលនៅក្រោយការអភិវឌ្ឍ ភាគច្រើនគឺជាក្រុមដែលមិនសូវមានឱកាស ដូចជា ស្ត្រី ជនពិការ ចាស់ជរា និងជនជាតិភាគតិច។ល។ (Overseas Development Institute, 2017)។

ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច បើទោះបីជាកំណើនប្រាក់ចំណូលមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះពុំត្រូវបានបែងចែកប្រកបដោយសមធម៌ឡើយ។ ទិន្នន័យតំណាងឱ្យប្រទេសទាំងមូល (លើកលែងទីក្រុងភ្នំពេញចេញ) ដែលប្រមូលកាលពីខែធ្នូ ឆ្នាំ ២០១៦ បានបង្ហាញថាប្រជាពលរដ្ឋ ៨០% អាចរកប្រាក់ចំណូលបានត្រឹមតែ ៤០,២% នៃប្រាក់ចំណូលសរុបតែប៉ុណ្ណោះ ខណៈពេលដែលប្រជាជនតិចជាង ២០% ជាអ្នករកចំណូលបាន ៥៩,៨% នៃចំណូលសរុប (WFP, 2016)។ កំណើនប្រទេសកម្ពុជាធ្វើឱ្យ ផលិតផលសរុបក្នុងស្រុក ក្នុងប្រជាជនម្នាក់កើនឡើងពី ១.២១៥ ដុល្លារ ក្នុងឆ្នាំ ២០១៥ ដល់ ១.៤៣៥ ដុល្លារ ក្នុងឆ្នាំ ២០១៧ (ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី, ២០១៨) ខណៈពេលដែលការចំណាយក្នុងប្រជាជនម្នាក់ក៏មានការកើនឡើងផងដែរ។ កំណើននេះបានផ្តល់លទ្ធភាពឱ្យ

ប្រជាជន អាចបង្កើនចំណាយលើស្បៀងអាហារដែលកើនឡើង ៥,៥% ចន្លោះពីឆ្នាំ ២០០៩ ដល់ ២០១៥ ខណៈពេលដែលចំណាយលើ ទំនិញមិនមែនអាហារ ក្នុងរយៈពេលដូចគ្នានេះកើនឡើង១១%។ តួលេខ ទាំងនេះបង្ហាញពីកំណើនកម្លាំងទិញរបស់ប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្របំផុត ខណៈពេលដែលកំណើនប្រាក់ចំណាយ មានន័យថា បច្ចុប្បន្ននេះចំណាយលើស្បៀងអាហារមានភាគរយថយចុះក្នុងចំណាយសរុប ដែលបង្ហាញពីការថយចុះនូវភាពងាយរងគ្រោះ ចំពោះបញ្ហាអសន្តិសុខស្បៀង (NIS, 2009b, 2014)។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រទទួលបានភាពល្អប្រសើរក្នុងល្បឿនយឺតជាង ក្រុមប្រជាជនដែលមានជីវភាពធូរធារ ដោយប្រជាពលរដ្ឋដែលស្ថិតនៅ ៥០% ខាងក្រោមគេ រស់នៅជាមួយនឹងប្រាក់ចំណូលក្រោម ២,៥០ ដុល្លារក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ។ ដើម្បីសម្រេចនូវការអភិវឌ្ឍប្រកបដោយចីរភាព កម្រិតនៃអសមធម៌ទាំងនេះ ទាមទារឱ្យមានដំណោះស្រាយជាផ្នែកមួយនៃរបៀបវារៈ “មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ”។




រូបភាពទី១៦៖ ចំណែកនៃប្រាក់ចំណូលប្រចាំគ្រួសារ ទៅតាមចំណែកបញ្ចភាគ (WFP, 2016)




រូបភាពទី ១៧៖ ភាគរយនៃប្រជាជនបែងចែកតាមប្រាក់ចំណូលក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ (FAO et al., 2016)

ដោយសារកំណើនមួយភាគធំកើនឡើងដោយសារការងារដែលប្រើជំនាញកម្រិតទាប និងការធ្វើចំណាកស្រុក ការងារបែបនេះអាចផ្តល់ជាឱកាស ប៉ុន្តែក៏ជាហានិភ័យក្នុងការធានាចីរភាពកំណើននាពេលអនាគត និងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាផងដែរ ប្រសិនបើប្រទេសកម្ពុជានៅបន្តផ្តោតលើឧស្សាហកម្មដែលត្រូវការជំនាញទាប និងផ្តល់ប្រាក់ឈ្នួលទាប ដោយពុំធ្វើការវិនិយោគបន្ថែមលើធនធានមនុស្សនោះ។ ដើម្បីធានាកំណើន និងការអភិវឌ្ឍប្រកបដោយចីរភាព កម្ពុជាមិនអាចពឹងអាស្រ័យលើវិធីសាស្ត្រកន្លងមកដែលធ្លាប់ជួយឱ្យកម្ពុជាទទួលបានការរីកចម្រើនខ្ពស់ និងការកាត់បន្ថយភាពក្រីក្រក្នុងអំឡុងពេលទសវត្សរ៍ចុងក្រោយនេះឡើយ។ ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងបន្ថែមឆ្លើយតបចំពោះបញ្ហាអតុល្យភាព និងការវិនិយោគលើធនធានមនុស្ស។

## លទ្ធភាពចំណាយលើរបបអាហារ ការចំណាយផ្សេងៗ និងការជាប់បំណុល

ការវិភាគលើចំណាយលើរបបអាហារបានបង្ហាញថា ជាមធ្យមមានគ្រួសារប្រមាណ ២១% ពុំអាចមានលទ្ធភាពទិញក្នុងបរិមាណគ្រប់គ្រាន់នូវអាហារដែលសម្បូរជីវជាតិ និងក្នុងតម្លៃថ្លៃបំផុតនោះឡើយ។ ចំណាយលើរបបអាហារប្រកបដោយអាហារូបត្ថម្ភសម្រាប់កុមារដែលពុំបៅដោះម្តាយ ខ្ពស់ជាងកុមារដែលបៅដោះម្តាយ ៤៤%។ ចំណាយលើរបបអាហារកើនឡើង ១០-១៥% នៅពេលដែលក្មេងស្រីជំទង់មានផ្ទៃពោះ ឬត្រូវបំបៅកូន។ ស្រដៀងគ្នានេះដែរ ការបរិភោគចំណីដែលធ្វើឱ្យសុខភាពមិនល្អ អាចបង្កើនចំណាយសម្រាប់កុមារ ៣៨% (WFP, 2017d)។

ការមានស្បៀងអាហារក្នុងមូលដ្ឋានផ្ទាល់ ព្រមទាំងតម្លៃស្បៀងអាហារទាំងនោះ លក្ខណៈប្រជាសាស្ត្ររបស់គ្រួសារ និងកម្រិតចំណូល មានឥទ្ធិពលយ៉ាងធំធេងលើលទ្ធភាពរបស់គ្រួសារមួយក្នុងការទទួលបានរបបអាហារ ដែលមានអាហារូបត្ថម្ភក្នុងកម្រិតគ្រប់គ្រាន់។

ចំណាយសង្គមសំខាន់ៗលើសេវាថែទាំសុខភាព និងការអប់រំ ជារឿយៗធ្វើឱ្យបាត់បង់តុល្យភាពសម្រាប់គ្រួសារដែលងាយរងគ្រោះភាគច្រើន។ ចំណាយលើការថែទាំសុខភាពអាចមានរហូតដល់ប្រមាណ ៧0% នៃចំណាយសរុបរបស់គ្រួសារ។ការសិក្សាមួយក៏បានរកឃើញផងដែរថា ចំណាយធំៗលើសុខភាពបន្ទាប់ពីគ្រោះរាំងស្ងួត ដែលបង្កឡើងដោយបាតុភូត អែលនីណូ (El Nino) ទំនងបំផុត ជាកត្តាដែលធ្វើឱ្យគ្រួសារធ្លាក់ចូលទៅក្នុងបំណុល (FAO et al., 2017b; UNICEF et al., 2016)។ ខណៈពេលដែលចំណាយរបស់រដ្ឋាភិបាលលើការថែទាំសុខភាពនិងការអប់រំមានការកើនឡើងពោលគឺ១,៣%នៃផលិតផលក្នុងស្រុកសរុប សម្រាប់វិស័យសុខាភិបាល និង ២,១% សម្រាប់វិស័យអប់រំក្នុងឆ្នាំ ២០១៥ ចំណាយនេះគឺនៅទាបជាងកម្រិតមធ្យមសម្រាប់ប្រទេសចំណូលមធ្យមកម្រិតទាប ដោយសារតែមានការពឹងផ្អែកលើការផ្តល់មូលនិធិពីខាងក្រៅ សម្រាប់ការផ្តល់សេវា។

ជំនួយសង្គមតាមសាលាក្នុងទម្រង់ជាការផ្តល់អាហារ និងអាហារូបករណ៍ ក៏កំពុងទទួលបានការយកចិត្តទុកដាក់ច្រើនជាងមុនផងដែរ ដើម្បីជួយឱ្យកុមារ ដែលងាយរងគ្រោះបំផុតអាចទៅរៀនបានទៀងទាត់ ប៉ុន្តែ ចាំបាច់ត្រូវមានការពង្រីកកម្មវិធីជំនួយសង្គមបែបនេះបន្ថែមទៀត ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។

គេរកឃើញថា គ្រួសារងាយរងគ្រោះ កាន់តែជាប់បំណុលច្រើនជាងមុន និងក្នុងរយៈពេលយូរជាងមុន បើធៀបនឹងគ្រួសារផ្សេងទៀត ដោយបំណុលនេះត្រូវបានប្រើប្រាស់ជាយុទ្ធសាស្ត្រសម្រាប់ទប់ទល់នឹងវិបត្តិ (FAO et al., 2017b)។ ពេលខ្លះបំណុលអាចមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងការងើបចេញពីភាពក្រីក្រ និងភាពងាយរងគ្រោះ ប្រសិនបើបំណុលនេះត្រូវបានប្រើប្រាស់ជាទុនបម្រុង ដូចដែលមានបង្ហាញក្នុងការសិក្សាថ្មីៗនេះដោយ UNDP។ ក៏ប៉ុន្តែ នៅពេលដែលបំណុលកាន់តែកើនឡើងជាបន្តបន្ទាប់ វាមិនអាចជួយកាត់បន្ថយភាពក្រីក្រនោះទេ និងអាចពុំមានចីរភាពក្នុងរយៈពេលយូរឡើយ (Foraci/UNDP, 2017; Collins et al., 2009; WFP, 2017b) ។

នៅក្នុងពេលដែលមានវិបត្តិកើតមានឡើង គ្រួសារដែលងាយរងគ្រោះ ខ្ចីបុល (បន្ថែម) ភាគច្រើនក្នុងអត្រាការប្រាក់ដ៏ខ្ពស់ ជាយុទ្ធសាស្ត្រដោះស្រាយមួយគ្រា ប៉ុន្តែវាច្រើនតែនាំមកវិញនូវផលប៉ះពាល់ជាអវិជ្ជមាន។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវកម្រិតអត្រាការប្រាក់ខ្ពស់បំផុតត្រឹម១៨%សម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលកាលពីមុន អត្រាការប្រាក់អាចខ្ពស់រហូតដល់ចន្លោះពី ២០-៣០% (Leng/NBC, 2016)។

## កិច្ចគាំពារសង្គម

ដោយទទួលស្គាល់ពីសារៈសំខាន់នៃយន្តការគាំពារសង្គម ចំពោះការការពារក្រុមដែលងាយរងគ្រោះបំផុត បច្ចុប្បន្ននេះ កំពុងមានការខិតខំប្រឹងប្រែង ធ្វើឡើងក្រោមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ (RGC, 2016b) ដែលពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលយន្តការនេះតាមរយៈការរួមចំណែកជាវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងបរិយាបន្នតាមរយៈកម្មវិធីជំនួយសង្គម និង កម្មវិធីធានារ៉ាប់រងសង្គម ដែលជាសមាសភាគទាំងពីរនៃផែនការយុទ្ធសាស្ត្រជាតិនេះ។ ទោះជាយ៉ាងណាក៏ដោយចាំបាច់ត្រូវមានការផ្តល់ហិរញ្ញប្បទានបន្ថែមទៀត ដើម្បីសម្រេចគោលបំណង “មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ” ដោយត្រូវយកចិត្តទុកដាក់ ចំពោះសមាសភាគសំខាន់ៗនៃកិច្ចព្រមព្រៀងសង្គម ដូចជាកិច្ចគាំពារសង្គម ការគ្របដណ្តប់ជាសកលនូវសេវាសុខភាព និងសកលកម្មនៃ

ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា (ODI, 2017)។

ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិ ស្ដីពីកិច្ចគាំពារសង្គមនេះ មានសារៈសំខាន់យ៉ាងខ្លាំង ដោយសារ ចំណាយសង្គមមួយចំនួន លើវិស័យសុខាភិបាល និងវិស័យអប់រំ ជារឿយៗជាកត្តាដែលនាំឱ្យមានអតុល្យភាពសម្រាប់គ្រួសារ ដែលងាយរងគ្រោះភាគច្រើនពាក់ព័ន្ធនឹងបញ្ហាស្លឹរភាពស្បៀង ដូចកត់សម្គាល់ក្នុងផ្នែក ៤.៤។ កម្មវិធីជំនួយសង្គម និងកម្មវិធីធានារ៉ាប់រងសង្គម ក្រោមក្របខ័ណ្ឌគោលនយោបាយជាតិស្ដីពីកិច្ចគាំពារសង្គមនេះ មានវិសាលភាព នៅមានកម្រិតនៅឡើយ។ ក្របខ័ណ្ឌនេះទទួលស្គាល់ពីបញ្ហាប្រឈមជាច្រើនដែលត្រូវជម្នះ ដូចជា ភាពចាំបាច់ដើម្បី៖ កែលម្អបរិយាកាសវិនិយោគ និងការបញ្ជាក់ឱ្យបានច្បាស់ពីគោលនយោបាយពន្ធ ពាក់ព័ន្ធនឹងប្រព័ន្ធកិច្ចគាំពារសង្គម រួមបញ្ចូលគ្នានូវការគ្រប់គ្រងរបបគាំពារសង្គមផ្សេងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធ “កំណត់អត្តសញ្ញាណ និងចុះឈ្មោះប្រជាជន” និងប្រព័ន្ធ “កំណត់អត្តសញ្ញាណ និងចុះឈ្មោះគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ” ដើម្បីឆ្លើយតបចំពោះបញ្ហាចុះឈ្មោះស្ទួន និងការផ្ដល់អត្ថប្រយោជន៍ផ្សេងៗត្រួតគ្នា នឹងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ដោយសារតែនៅមានការយល់ដឹងតិចតួចអំពីប្រព័ន្ធនេះ និងអត្ថប្រយោជន៍របស់វា (RGC, 2016b, pp. xv-xvi, 39-41)។

ផែនការយុទ្ធសាស្ត្រជាតិគាំពារសង្គម មានគោលបំណងផ្ដល់ជំនួយសង្គម ផ្សារភ្ជាប់ជាមួយនឹងសន្តិសុខស្បៀង និងអាហារូត្ថម្ភ ដោយផ្ដោតការយកចិត្តទុកដាក់ លើចំនុចដូចខាងក្រោម៖

- ការឆ្លើយតបចំពោះ ស្ថានភាពអាសន្ន ឧទាហរណ៍ ការផ្គត់ផ្គង់ស្បៀងនៅក្នុងពេលដែលមានវិបត្តិកើតឡើង
- ការការពារស្ត្រីមានផ្ទៃពោះ និងកុមារ ឧទាហរណ៍ ផ្ដោតការយកចិត្តទុកដាក់លើការលើកកម្ពស់អាហារូបត្ថម្ភ សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ
- កម្មវិធីផ្ដល់ស្បៀងអាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលដែលដាំដុះតាមសហគមន៍

ប្រភព៖ RGC (2017b)

## ភក្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៧

កំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ត្រូវការការគាំទ្របន្ថែមទៀត តាមរយៈការបង្កើនការយកចិត្តទុកដាក់លើការលើកកម្ពស់ការទទួលបានស្បៀងប្រកបដោយសមធម៌។

# ៤.៣ និន្នាការនៃការបឺតស្រូបស្បៀង

និន្នាការនៃការបឺតស្រូបស្បៀងនៅកម្ពុជាមានការផ្លាស់ប្ដូរជាវិជ្ជមាន មួយផ្នែកដោយសារការកើនឡើងនូវប្រាក់ចំណូល ទ្រព្យសម្បត្តិ ការមានស្បៀង និងការទទួលបានសេវាជាមូលដ្ឋានល្អប្រសើរជាងមុន។

## និន្នាការអាហារូបត្ថម្ភកុមារ

ការកើនឡើងនូវចំណូល និងទ្រព្យសម្បត្តិ ការមានរបបអាហារចម្រុះជាងមុន ការអប់រំ (ជាពិសេសការអប់រំសម្រាប់ម្ដាយ) ការពង្រីកការគ្របដណ្ដប់នៃសេវាថែទាំសុខភាព ការទទួលទឹកស្អាត និងសេវាអនាម័យល្អប្រសើរជាងមុន និងឥរិយាបទលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ដូចជា ការបំបៅកូន

ដោយទឹកដោះម្ដាយតែមួយមុខគត់ សុទ្ធតែជាកត្តាដែលនាំឱ្យស្ថានភាពអាហារូបត្ថម្ភមានភាពល្អប្រសើរជាងមុន (UNICEF, 2016a, 2016b)។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ បរិយាកាសគោលនយោបាយមានលក្ខណៈអំណោយផល (RGC 2014c; MoH 2014) ក៏បាននាំឱ្យមានការយកចិត្តទុកដាក់កាន់តែច្រើនជាងមុន លើការលើកកម្ពស់ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភផងដែរ និងមានការគាំទ្រឱ្យមានការអនុវត្តអភិក្រមចម្រុះរួម ដើម្បីសម្រេចគោលដៅទាំងនេះ។




រូបភាពទី ១៨៖ និន្នាការបញ្ហាអាហារូបត្ថម្ភកុមារ (NIS et al., 2001, 2006, 2011, 2015)

អត្រាបញ្ហា អាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិសក្រិន) បានថយចុះ ៥០% ក្នុងឆ្នាំ ២០០០ មក ៣២% ក្នុងឆ្នាំ ២០១៤ ដែលស្ថិតនៅតាម ផែនការគ្រោងទុកក្នុងការឈានទៅ សម្រេចគោលបំណង ដែលត្រូវបានដាក់ចេញក្នុងផែនការ យុទ្ធសាស្ត្រជាតិស្ដីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ក្នុងរយៈពេលដូចគ្នានេះ អត្រាស្គមស្គាំងបានថយចុះពី ១៧ ទៅ ១០% ខណៈពេលដែលអត្រាកង្វះទម្ងន់ថយចុះមកនៅ ២៣,៩%។ ភាពស្លេកស្លាំងក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ ថយចុះពី ៦២ ដល់ ៥៦%។ ស្របគ្នានេះដែរ ចាប់តាំងពីឆ្នាំ ១៩៩០ មកប្រទេសនេះបានកាត់បន្ថយអត្រាមរណភាពមាតាបានជាងពាក់កណ្ដាល (NIS et al., 2015; UN, 2015b; FAO, 2017b)។

បើទោះបីជាមានការកត់សម្គាល់ឃើញពីនិន្នាការជាវិជ្ជមានបែបនេះក៏ដោយ ស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជានៅពុំទាន់នឹងនរនៅឡើយ ដោយសារបញ្ហាអាហារូបត្ថម្ភបន្តនាំឱ្យមានការខូចខាតដែលមិនអាចស្ដារឡើងវិញបានចំពោះការអភិវឌ្ឍផ្នែកចំណេះដឹង និងកាយសម្បទារយៈពេលវែងរបស់កុមារ ហើយក៏ជាកត្តាដែលរួមចំណែកធ្វើឱ្យពួកគេមានប្រាក់ឈ្នួលទាប និងបាត់បង់ផលិតភាព នៅពេលពួកគេក្លាយជាមនុស្សពេញវ័យផងដែរ (NIS et al., 2001, 2006, 2011, 2015).។

ការវិភាគលើនិន្នាការនៃការក្រិសក្រិន បង្ហាញថា ប្រេវ៉ាឡង់នៃបញ្ហាក្រិសក្រិននេះបានថយចុះ ក្នុងគ្រប់កម្រិតជីវភាពទាំងអស់។ ប៉ុន្តែស្ថិតិបង្ហាញថា គ្រួសារដែលមានជីវភាពក្រីក្រជាងគេ សម្រេចបានវឌ្ឍនភាពយឺតយ៉ាវ ខណៈពេលដែលការថយចុះបញ្ហាក្រិសក្រិន ក្នុងចំណោមគ្រួសារដែលមានជីវភាពធូរធារជាងគេហាក់បីដូចជានៅទ្រឹង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១៤ ១៨,៥% នៃកុមារអាយុក្រោម ៥ ឆ្នាំ មកពីក្រុមគ្រួសារដែលមានជីវភាពធូរធារជាងគេ មានបញ្ហាក្រិសក្រិន (Development Initiatives, 2017)។ នេះបង្ហាញថា ថ្វីបើទ្រព្យសម្បត្តិអាចសម្រួលលទ្ធភាពក្នុងការកាត់បន្ថយហានិភ័យកង្វះអាហារូត្ថម្ភក៏ដោយ នៅមានកត្តាដទៃទៀត ដូចជា ឥរិយាបថក្នុងការបរិភោគ និងការថែទាំ ជាដើម អាចមានឥទ្ធិពលយ៉ាងច្រើនមកលើបញ្ហាអាហារូបត្ថម្ភរ៉ាំរ៉ៃនៅកម្ពុជា។

ប្រមាណ ៤៥% នៃបន្ទុកសេដ្ឋកិច្ចប្រចាំឆ្នាំ ចំនួន ២៦៦ លានដុល្លារ ដោយសារបញ្ហាអាហារូបត្ថម្ភត្រូវបានគេប៉ាន់ប្រមាណថា កើតឡើងដោយសារបញ្ហាក្រិសក្រិននេះ ខណៈពេលដែលបន្ទុកសេដ្ឋកិច្ចក្រោម ៣% ប៉ុណ្ណោះ ដែលមានទំនាក់ទំនងជាមួយនឹងបញ្ហាអាហារូបត្ថម្ភស្រួចស្រាវ។ ដូច្នេះ ចំណុចនេះបង្ហាញយ៉ាងច្បាស់ថា ការឆ្លើយតបចំពោះបញ្ហាក្រិសក្រិនអាចនាំមកនូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចជាច្រើន




រូបភាពទី ១៩៖ ប្រេវ៉ាឡង់នៃក្រេះក្រិន និងបំលាស់ប្តូរនៃភាពក្រិសក្រិន តាមឆ្នាំ
តាមចំណែកបញ្ចភាគនៃស្ថានភាពទ្រព្យសម្បត្តិ (Development Initiatives, 2017)

ហើយក្នុងពេលជាមួយគ្នា ការបន្តកិច្ចខិតខំប្រឹងប្រែងព្យាបាលបញ្ហាស្គមស្គាំង នៅតែមានសារៈសំខាន់ ដោយសារតែភស្តុតាងបង្ហាញថា បញ្ហាស្គមស្គាំងនេះអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។ ដោយសារតែបញ្ហាក្រិសក្រិននិងបញ្ហាស្គមស្គាំងមានកត្តាហានិភ័យដូចគ្នាជាច្រើន កិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយអាចជួយសម្រួលឱ្យមានការភ្ជាប់ទំនាក់ទំនងរវាង កម្មវិធីនានាជាមួយគ្នា ដើម្បីឈានទៅអនុវត្តកម្មវិធីអន្តរាគមន៍ ដែលកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ (NIS et al., 2015; NMCHC, 2016; CARD et al., 2013)។

ប្រសិនបើពុំមានការបង្កើនកិច្ចខិតខំប្រឹងប្រែងឆ្លើយតបចំពោះបញ្ហាកង្វះអាហារូបត្ថម្ភ ដែលពិបាកដោះស្រាយទាំងនេះនោះទេ នោះចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសំខាន់ៗជាច្រើនសម្រាប់កាត់បន្ថយបញ្ហាអាហារូបត្ថម្ភ នឹងមិនអាចសម្រេចបានឡើយ។ ដោយសារបញ្ហាអាហារូបត្ថម្ភបង្កផលប៉ះពាល់យ៉ាងច្រើនមកលើសេដ្ឋកិច្ច និងសង្គម គេចាំបាច់ត្រូវផ្តល់អាទិភាពដល់អន្តរាគមន៍អាហារូបត្ថម្ភថាជា "ចលករក្នុងការពន្លឿន" ដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ដែលនឹងជួយជំរុញឱ្យមានការសម្រេចគោលដៅនេះឱ្យបានឆាប់ ដើម្បីធានាឱ្យមានការសាយភាយដល់ផលជាវិជ្ជមានទៅលើវិស័យដទៃទៀត ដូចជា វិស័យអប់រំ សុខាភិបាល និងការមានកម្លាំងពលកម្ម ដែលមានផលិតភាព និងមានជំនាញជាដើម។

## របបអាហារចម្រុះ

ពិន្ទុរបបអាហារចម្រុះប្រចាំសប្តាហ៍របស់គ្រួសារ (DDS) វាស់វែងលើចំនួនក្រុមអាហារផ្សេងៗ ដែលគ្រួសារបរិភោគក្នុងរយៈពេល ៧ ថ្ងៃចុងក្រោយ ផ្អែកទៅតាមការចងចាំរបស់អ្នកឆ្លើយសំណួរ។ ពិន្ទុនេះបង្ហាញពីគុណភាពនៃរបបអាហាររបស់គ្រួសារមួយនឹងអាចបង្ហាញ និងរាយការណ៍ជាពិន្ទុមធ្យម និងភាគរយនៃគ្រួសារទៅតាមក្រុមរបបអាហារនីមួយៗ។ ពិន្ទុទាប(DDS<៤,៥) មធ្យម(DDS=៤,៥-៦) និងខ្ពស់ (DDS=៦+)។ ការវិភាគលើទិន្នន័យសន្តិសុខស្បៀងពីការអង្កេតសង្គម សេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៤ បង្ហាញថា ជាមធ្យមគ្រួសារកម្ពុជាបរិភាគអាហារចំនួន ៥,៦ ក្រុម ក្នុងរយៈពេល ៧ ថ្ងៃចុងក្រោយ។ និន្នាការនៃការបរិភោគអាហារនេះ គឺមានលក្ខណៈស្រដៀងគ្នា ក្នុងតំបន់ទាំងបួន។

ភាគរយគ្រួសារដែលមានរបបអាហារមិនគ្រប់គ្រាន់ ថយចុះគួរឱ្យកត់សម្គាល់ពី ៤៦% ក្នុងឆ្នាំ ២០០៨ មក ១២% ក្នុងឆ្នាំ ២០១៤ (NIS, 2009b, 2014)។ ក្នុងឆ្នាំ ២០១៤ គ្រួសារប្រមាណជា ៧៣% បានរាយការណ៍ពីរបបអាហារចម្រុះក្នុងកម្រិតមធ្យម។ ខណៈពេលដែលស្ថានភាពនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ២០០៨ មក ក៏មានការកត់សម្គាល់ឃើញពីការឡើងចុះច្រើនផងដែរ នៅក្នុង

ឆ្នាំមួយៗ ដោយសារតែវិបត្តិនានា។ នៅក្នុងឆ្នាំ ២០១៦ បន្ទាប់ពីរយៈពេលនៃបាតុភូតអែលនីណូ ភាពចម្រុះនៃរបបអាហារឡើងចុះចន្លោះពី ១៨ (ទាប) និង ៧៣ (មធ្យម) ក្នុងខែ ឧសភា និងចន្លោះពី ២៥ (ទាប) និង ៦៨ (មធ្យម) ភាគរយក្នុងខែ ធ្នូ ដែលបង្ហាញពីភាពផុយស្រួយនៃស្ថានភាពសន្តិសុខស្បៀង។

## បញ្ហាអាហារូបត្ថម្ភ ដោយសារកង្វះមីក្រូសារជាតិចិញ្ចឹម

បញ្ហាអាហារូបត្ថម្ភ ដោយសារកង្វះមីក្រូសារជាតិចិញ្ចឹមនៅតែជាបញ្ហាប្រឈមនៅកម្ពុជា។ ថ្វីបើអាហារបន្ថែម និងរបបអាហារគ្រប់គ្រាន់នាំឱ្យមានការកាត់បន្ថយបញ្ហាកង្វះវីតាមីនអា ដែលលែងជាកង្វល់ចំពោះសុខភាពសាធារណៈទៀត កង្វះសារធាតុរ៉ែ និងវីតាមីនផ្សេងទៀត នៅតែជាបញ្ហាធ្ងន់ធ្ងរ។ កង្វះសារធាតុស័ង្កសីនាំឱ្យមានការព្រួយបារម្ភជាពិសេស ដោយសារតែម្តាយប្រមាណជា ៦៣% ក៏ដូចជាកុមារអាយុចន្លោះពី ៦ ទៅ ២៤ ខែ ៦៥% ទទួលរងផលប៉ះពាល់ដោយសារបញ្ហានេះ។ ស្ថានភាពនេះរឹតតែធ្ងន់ធ្ងរទៅទៀត នៅតំបន់ប្រជុំជន ដែលមានការរកឃើញថាមានម្តាយ ៧២% ខ្វះសារធាតុស័ង្កសីក្នុងឆ្នាំ ២០១៤។ នេះជាការព្រួយបារម្ភមួយចំពោះប្រព័ន្ធការពាររាងកាយពីការឆ្លងជំងឺ និងការឈឺថ្កាត់នានា។ ស្ត្រីក៏ជួបប្រទះនឹងបញ្ហាកង្វះអាស៊ីតហ្វូលិក ក្នុងកម្រិតមួយខ្ពស់ ពោលគឺ ១៩% ដែលប៉ះពាល់ដល់ការវិវត្តន៍របស់ទារកក្នុងផ្ទៃ និងកង្វះវីតាមីនដេ ៣១% ដែលមានសារៈសំខាន់សម្រាប់ភាពរឹងមាំរបស់ឆ្អឹង។

កុមារអាយុក្រោយ ៥ ឆ្នាំ ប្រមាណ ៦៩% រស់នៅក្នុងគ្រួសារដែលប្រើអំបិលមានលាយសារធាតុអ៊ីយ៉ូដ។ ភាគរយនេះថយចុះពី ៨៣% ក្នុងឆ្នាំ ២០១០។ លើសពីនេះកុមារអាយុ ៦-៥៩ ខែ ៦៦% មានកំហាប់សារធាតុអ៊ីយ៉ូដទាបក្នុងទឹកនោមរបស់ពួកគេ។ ភាគរយនេះគឺ ៧៨% ក្នុងចំណោមស្ត្រីជាម្តាយ។ បញ្ហានេះនាំឱ្យមានការព្រួយបារម្ភ ជាពិសេស ចំពោះការអភិវឌ្ឍបញ្ញាស្មារតី។ ខណៈពេលដែលបញ្ហាស្លេកស្លាំងនៅបន្តមានកម្រិតខ្ពស់ ពោលគឺ ៤៥% សម្រាប់ម្តាយ ៥៣% សម្រាប់កុមារអាយុពី ៦-៥៩ ខែ ការវិភាគកម្រិតខ្ពស់បង្ហាញថា ប្រមាណតែ ២៥% នៃបញ្ហានេះតែប៉ុណ្ណោះ (ពោលគឺ ១១% ក្នុងចំណោមម្តាយ) មានទំនាក់ទំនងជាមួយនឹងមូលហេតុ ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ខណៈពេលដែលនៅសល់ ៧៥% ទៀត ជាកត្តាកំណត់ដោយហ្សែន។ ចំណុចនេះមានភាពពាក់ព័ន្ធជាមួយនឹងការរៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ដែលមានប្រសិទ្ធភាព។ ភាពអត់ឃ្លានកំបាំងមុខដូចជាបញ្ហាកង្វះសារជាតិ ដូចបញ្ជាក់ពីខាងលើនេះតម្រូវឱ្យមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាឱ្យមានការបន្តលើកកម្ពស់ស្ថានភាពសុខភាពសុខុមាលភាព និងផលិតភាពរបស់ប្រជាពលរដ្ឋ (NIS, 2015; Prak, 2016)។

## ស្ថានភាពអាហារូបត្ថម្ភរបស់មាតា

ស្ថានភាពអាហារូបត្ថម្ភ ឥរិយាបទ កង្វះវីតាមីន និងសារធាតុរ៉ែរបស់មាតា ក៏ដូចជាបញ្ហាប្រឈមនានាក្នុងការទទួលបានអាហារឱ្យបានគ្រប់គ្រាន់ អាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ តម្រូវការសារធាតុចិញ្ចឹមក្នុងកម្រិតខ្ពស់ ពេលមានផ្ទៃពោះ ក៏ធ្វើឱ្យស្ត្រីមានផ្ទៃពោះងាយជួបប្រទះនឹងបញ្ហាកង្វះអាហារូបត្ថម្ភផងដែរ ហើយទិន្នន័យបង្ហាញថា ភាពចម្រុះនៃរបបអាហារ ដែលមានកម្រិតទាបនៅពេលធម្មតា បង្ហាញពីការរីកចម្រើនតិចតួចប៉ុណ្ណោះ ក្រោយពេលមានផ្ទៃពោះ (NMCHC, 2016; WFP, 2017d)។ បច្ចុប្បន្ននេះ គោលដៅផែនការយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភដើម្បីឆ្លើយតបចំពោះបញ្ហាកង្វះអាហារូបត្ថម្ភរបស់ស្ត្រីក្នុងវ័យបន្តពូជពុំទាន់បានសម្រេចទៅតាមផែនការដែលបានគ្រោងទុកនៅឡើយទេ ដោយប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីទាំងនេះមាន ១៤% ក្នុងឆ្នាំ ២០១៤ ខ្ពស់ជាង ៨% ដែលជាចំណុចដៅសម្រាប់ឆ្នាំ ២០១៥។ បញ្ហាស្លេកស្លាំងក៏នៅមានកម្រិតខ្ពស់ផងដែរ ពោលគឺជាមធ្យមមានកម្រិត ៤៥% សម្រាប់ស្ត្រី។ បើតាមរបាយការណ៍អាហារូបត្ថម្ភសកលលោកឆ្នាំ ២០១៦ ប្រទេសកម្ពុជាជាប់លំដាប់ថ្នាក់ទី ១៦០ ក្នុងចំណោមប្រទេស ១៨៥ ដែលមាន

អត្រានៃភាពស្លេកស្លាំងក្នុងចំណោមស្រ្តីបន្តពូជខ្ពស់ជាងគេដែលនេះមានទំនាក់ទំនងជាមួយនឹងសរីរសាស្ត្រជាជាងជាមួយនឹងសុខភាព និងរបបអាហារ ដូច្នេះ ដំណោះស្រាយដែលអាចមានសម្រាប់ប្រទេសនេះពុំទាន់មានភាពច្បាស់លាស់នៅឡើយ (IFPRI, 2016; NIS et al., 2001, 2015; WFP, 2016d; Wieringa et al., 2016)។ អត្រាខ្ពស់នៃការមានផ្ទៃពោះ ក្នុងចំណោមក្មេងស្រីជំទង់ដែលមានចំណេះដឹងតិចតួចអំពីបញ្ហាអាហារូបត្ថម្ភ ក៏តម្រូវឱ្យមានការឆ្លើយតបតាមរយៈ ការផ្តោតការយកចិត្តទុកដាក់លើក្រុមក្មេងជំទង់ ជាផ្នែកមួយនៃអភិក្រមវដ្តនៃជីវិត (WFP, 2017a)។

## ការផ្តល់អាហារដល់ទារក និងកុមារតូច ( IYCF )

អត្រានៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ មានការកើនឡើងខ្ពស់ដល់ ៩៦% ទូទាំងប្រទេស ប៉ុន្តែនៅតំបន់ប្រជុំជនការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់មានកម្រិតទាប (៧៧%) ខណៈពេលដែលរយៈពេលនៃការបំបៅកូនសរុបក៏ទាបជាងតំបន់ប្រជុំជនផងដែរ (១៣,៥ ខែ ធៀបនឹង ១៨,៨ ខែ)។ មានកុមារត្រឹមតែ ៣៧% ប៉ុណ្ណោះ ដែលបន្តបៅដោះម្តាយរហូតដល់ ២ ឆ្នាំ។ ក្នុងក្រុមអាយុ ៦-២៣ខែ មានតែ៤៧,៦%ប៉ុណ្ណោះដែលទទួលបានអាហារចាប់ពីបួនក្រុមឡើងទៅ(ដោយរាប់បញ្ចូលទាំងការបៅដោះម្តាយផង) ខណៈពេលដែលកុមារ ៧២,២% ទទួលបានអាហារញឹកញាប់គ្រប់គ្រាន់។ ខណៈពេលដែលគេនៅមានឱកាសដើម្បីធ្វើការកែលម្អបន្ថែមទៀត ទម្លាប់ផ្តល់អាហារដល់ទារក និងកុមារតូចមានភាពល្អប្រសើរជាងមុន ដោយភាគរយកុមារដែលទទួលបានអាហារ ទៅតាមអនុសាសន៍ស្តីពីការផ្តល់អាហារដល់ទារក និងកុមារតូចកើនឡើង ៦% ចំណុច ពីឆ្នាំ ២០១០ (២៤%) ដល់ ២០១៤ (៣០%) (NMCHC, 2016; CARD et al., 2013; WFP, 2017d)។ គួរមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីពន្លឿននិន្នាការនេះ។

## ទឹកស្អាត អនាម័យបរិស្ថាន និងអនាម័យរាងកាយ

អសមធម៌ផ្នែកសង្គម និងសេដ្ឋកិច្ច និងការទទួលបានសេវាជាមូលដ្ឋាន ដូចជាសេវាសុខភាព សេវាទឹកស្អាត និងអនាម័យ និងសេវាអប់រំអាចនាំឱ្យមានការជួបការលំបាកមួយចំនួនដែលអាចរួមចំណែកធ្វើឱ្យមានបញ្ហាអាហារូបត្ថម្ភកើតមានឡើង (NMCHC, 2016)។ ការទទួលបានទឹកស្អាត និងអនាម័យមានភាពល្អប្រសើរជាងមុនយ៉ាងច្រើន។ ភាគរយនៃប្រជាជនដែលប្រើប្រាស់ប្រភពទឹកស្អាតសម្រាប់បរិភោគ កើនឡើងពីប្រមាណ ២៣% ក្នុងឆ្នាំ ១៩៩០ ដល់ ៧៥,៥% ក្នុងឆ្នាំ ២០១៥ ហើយភាគរយប្រជាជន ដែលប្រើប្រាស់បរិក្ខារអនាម័យ កើនឡើងពី ២,៩% ដល់ ៤២% ក្នុងរយៈពេលដូចគ្នានេះ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្ត អនាម័យតម្រូវឱ្យមាន ការកែលម្អបន្ថែម ទៀត ដើម្បីឆ្លុះបញ្ចាំងពី បទដ្ឋានក្នុងប្រទេស ដែលមានស្ថានភាព ជាប្រទេសចំណូល មធ្យម កម្រិតទាប (WHO & UNICEF, 2015; World Bank, 2017b)។




រូបភាពទី ២០៖ ការគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាត និងសេវាអនាម័យ ភាគរយនៃប្រជាជនសរុប (WHO & UNICEF, 2015)

ខណៈពេលដែលមានការសម្រេចទៅតាមចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហវត្សរ៍ នៅតំបន់ជនបទ ការទទួលបានបរិក្ខារអនាម័យដែលត្រូវបានកែលម្អនៅមានកម្រិតទាប (៣០,៥% នៅតំបន់ជនបទ ធៀបនឹង ៨៨,១% នៅតំបន់ប្រជុំជនក្នុងឆ្នាំ ២០១៥) ហើយការទទួលបានទឹកស្អាតក៏នៅមានកម្រិតទាបផងដែរ (៦៩,១% នៅតំបន់ជនបទ ធៀបនឹង ១០០% នៅតំបន់ប្រជុំជនក្នុងឆ្នាំ ២០១៥) (WHO & UNICEF, 2015)។ លើសពីនេះ ខណៈពេលដែលការទទួលបានសេវាទាំងនេះមានភាពល្អប្រសើរជាងមុន កម្រិតទាំងនេះនៅទាបជាងកម្រិតក្នុងប្រទេសដទៃដែលមានស្ថានភាពប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា ដែលតម្រូវឱ្យមានការកែលម្អបន្ថែមទៀត។

## បន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភ

កម្ពុជាបានផ្លាស់ប្តូរទម្លាប់ ទទួលទានអាហារទៅរកម្ហូបអាហារស្រាប់ ដែលផ្តល់ភាពងាយស្រួល ដែលកត្តានេះបង្កឱ្យមាននិន្នាការ កំណើននៃភាពធាត់ជ្រុល ជាពិសេសក្នុងចំណោមស្ត្រី និងបង្កើនហានិភ័យនៃការកើតមានជំងឺមិនឆ្លង (MoH, 2013)។ គោលដៅសម្រាប់បញ្ហាលើសអាហារូបត្ថម្ភក្នុងចំណោម ស្ត្រីវ័យបន្តពូជដែលត្រូវបានចែងនៅក្នុង យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ដោយមានចំណុចដៅត្រឹម ១២% សម្រាប់ឆ្នាំ ២០១៨ ប៉ុន្តែអត្រានេះមាន ១៨% ក្នុងឆ្នាំ ២០១៤ (NIS et al., 2001, 2015; NMCHC, 2016)។ បញ្ហាទាំងនេះមានទំនាក់ទំនងជាមួយនឹងការពង្រីក និងការអភិវឌ្ឍទីក្រុងដ៏ឆាប់រហ័យ ការបរិភោគបាយច្រើនលើសលុបក្នុងរបបអាហារ និងការកើនឡើងនូវការបរិភោគនំចំណីជាពិសេសក្នុងចំណោមកុមារ។ បញ្ហានេះមានទំនាក់ទំនងជាពិសេសជាមួយស្ត្រីវ័យបន្តពូជនៅតំបន់ប្រជុំជន ប៉ុន្តែក៏មានកើនឡើងនៅតំបន់ជនបទ និងកើតឡើងក្នុងចំណោមប្រជាជនគ្រប់ស្រទាប់វណ្ណៈទាំងអស់ក្នុងសង្គម។ នៅតំបន់ប្រជុំជន ស្ត្រី ២២,៥% មានបញ្ហាលើសទម្ងន់ ឬធាត់ជ្រុល បើធៀបនឹង ១៧% នៅតំបន់ជនបទ ហើយកុមារអាយុក្រោម ៥ ឆ្នាំ ២% ជួបប្រទះនឹងបញ្ហានេះ។ ក្នុងចំណោមស្ត្រីវ័យបន្តពូជ (១៥-៤៩ ឆ្នាំ) ស្ត្រីវ័យចំណាស់ប្រហែលជាងាយនឹងមានបញ្ហាលើសទម្ងន់ ខណៈពេលដែលបញ្ហាទម្ងន់ភាគច្រើនកើតឡើងចំពោះស្ត្រីនៅក្មេងៗ (NIS et al., 2015, NMCHC, 2016; WFP, 2017d; MoH, 2013)។




រូបភាពទី២១៖ ប្រេវ៉ាឡង់នៃកង្វះ និងភាពលើសអាហារូបត្ថម្ភក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ (NIS et al., 2015)

## ឥរិយាបទ និងទម្លាប់ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ

គន្លឹះដើម្បីពង្រឹងការវិនិយោគលើធនធានមនុស្សគឺ តាមរយៈការអន្តរាគមន៍អាហារូបត្ថម្ភផង និងការអប់រំផង។ កង្វះអាហារូបត្ថម្ភអាចបង្កផលប៉ះពាល់ដល់ការសម្រេចលទ្ធផលនៃការអប់រំ និងកាត់បន្ថយការរួមចំណែកនៅកន្លែងធ្វើការ ក៏ដូចជាបន្ថែមបន្ទុកលើវិស័យសុខាភិបាល ខណៈពេលដែលការវិនិយោគក្នុងវិស័យអប់រំអាចបង្កើនការយល់ដឹង និងការកែលម្អការអនុវត្ត ដែលមានលក្ខណៈអវិជ្ជមាន (CARD et al., 2013)។

ចាំបាច់ត្រូវតែមានការបន្តលើកកម្ពស់ និងពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីឱ្យមានការអនុវត្តផ្នែកសង្គម-វប្បធម៌ដែលវិជ្ជមាន តាមរយៈអន្តរាគមន៍ ដែលផ្តោតលើអាហារូបត្ថម្ភ ដូចជាការលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរឥរិយាបទតាមរយៈការប្រាស្រ័យទាក់ទង និងការអនុវត្តយុទ្ធសាស្ត្រផ្តោតលើបញ្ហាអាហារូបត្ថម្ភរ៉ាំរ៉ៃ

ដែលកំពុងបន្តកើតមានឡើង ការកែលម្អការអនុវត្តផ្នែកការផ្តល់អាហារ អនាម័យ ក៏ដូចជាបញ្ហាធាត់ជ្រុល និងបញ្ហាជំងឺមិនឆ្លង ដែលកំពុងមានការកើនឡើងនៅក្នុងរយៈពេលថ្មីៗនេះ។ ការបង្កើនការយល់ដឹងអំពីព័ត៌មានដែលបង្ហាញពីអាហារូបត្ថម្ភដែលមានក្នុងអាហារ និងរបបអាហារចម្រុះដែលមានតម្លៃសមរម្យ អាចធ្វើឡើងរួមគ្នាជាមួយនឹងការត្រួតពិនិត្យ ការផ្សព្វផ្សាយពាណិជ្ជកម្ម ជាពិសេសការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការប្រើប្រាស់អំបិល ស្ករ នឹងខ្លាញ់ ជាដើម។ ស្រដៀងគ្នានេះដែរ គេអាចបន្តជំរុញឱ្យមានការផ្សព្វផ្សាយសារអប់រំបែបវិជ្ជមានបន្ថែមទៀត ដូចជា តាមរយៈការប្រើប្រាស់ជនគំរូដើម្បីផ្សព្វផ្សាយពីអាហារូបត្ថម្ភ រួមទាំងការកែលម្អរបៀបផ្តល់អាហារ (ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ការផ្តល់អាហារដល់ទារក និងកុមារតូច និងការផ្តល់អាហារបន្ថែម) ការអភិវឌ្ឍកុមារតូច និងទម្លាប់អនាម័យ។ ចំណុចនេះគឺមានភាពពាក់ព័ន្ធជាពិសេសនៅក្នុងករណីក្រិសក្រិន ដែលកំពុងកើតមាននៅតំបន់ដែលការពុំមានលទ្ធភាពទិញអាហារហូបចុកមានកម្រិតខ្ពស់ផង និងកម្រិតទាបផង និងក្នុងចំណោមគ្រួសារដែលមានជីវភាពក្រីក្រ និងគ្រួសារដែលមានជីវភាពធូរធារ ដែលបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការផ្លាស់ប្តូរឥរិយាបទ ប្រសិនបើគេចង់សម្រេចឱ្យបាននូវចក្ខុវិស័យលុបបំបាត់បញ្ហាក្រិសក្រិនចំពោះកុមារអាយុក្រោម ២ ឆ្នាំ ត្រឹមឆ្នាំ ២០៣០ (RGC, 2016a)។

### គន្លាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៨

ដោយសារបញ្ហាអាហារូបត្ថម្ភគឺជា បញ្ហាដ៏ស្មុគស្មាញ និងបង្កឡើងដោយទំនាក់ទំនងរវាងកត្តាចម្រុះ ចាំបាច់ត្រូវមានការពង្រឹងលើការឆ្លើយតបពហុវិស័យ ដោយផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបទជុំវិញបញ្ហាអាហារូបត្ថម្ភ។

## ៤.៤ និន្នាការនៃស្ថិរភាពស្បៀងអាហារ

របៀបវារៈឆ្នាំ ២០៣០ ចាត់ទុកការបង្ការ និងកសាងភាពធន់ទ្រាំ ថាមានសារៈសំខាន់ពិសេស ដើម្បីធានាឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព (UN, 2015a)។ នេះរួមមានការឆ្លើយតបចំពោះបញ្ហាវិសមភាព ការពង្រឹងស្ថាប័ន និងសង្គមស៊ីវិល និងការធានាយ៉ាងណាឱ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា ត្រូវបានរៀបចំឡើងដោយមានការគិតគូរពីហានិភ័យ ពោលគឺការប្រើប្រាស់ការវិភាគស្ថានភាពដើម្បីចាប់យកឱកាសដែលមាន និងត្រៀមទប់ទល់ និងកាត់បន្ថយហានិភ័យ ដែលអាចកើតមានឡើងដោយត្រូវពិចារណា និងរៀបចំផែនការទប់ទល់នឹងហានិភ័យសំខាន់ៗ ដូចជា គ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស វិបត្តិសុខភាពសាធារណៈដែលអាចកើតមានឡើង (ដូចជាការរាតត្បាតជំងឺជាដើម) វិបត្តិសេដ្ឋកិច្ច វិបត្តិបរិស្ថាន ដូចជាការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ វិបត្តិ និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណែតដែលកំពុងសាយភាយកន្លងមកថ្មីៗនេះ (Stimson, 2017)។ ការធ្វើបច្ចុប្បន្នភាព និងការពិនិត្យតាមដានជាទៀងទាត់អនុញ្ញាតឱ្យគេប្រកាសអាសន្នទាន់ពេលវេលាអំពីបញ្ហាដែលអាចកើតមានឡើង ដើម្បីជំរុញឱ្យមានការធ្វើសកម្មភាព ដោយដាក់ចេញនូវយន្តការចាំបាច់ដើម្បីកំណត់រកហានិភ័យ ដែលអាចកើតមានឡើង និងរិះរកជម្រើសដើម្បីកាត់បន្ថយ ឬឆ្លើយតបចំពោះបញ្ហាទាំងនោះទៅតាមការចាំបាច់។

## គ្រោះធម្មជាតិ

ប្រទេសកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយទទួលរងគ្រោះធម្មជាតិនៅអាស៊ីអាគ្នេយ៍។ របាយការណ៍ស្តីពីហានិភ័យពិភពលោកឆ្នាំ ២០១៦ ចាត់ទុកប្រទេសកម្ពុជាជាប្រទេសដែលងាយប្រឈមនឹងហានិភ័យ លំដាប់ថ្នាក់ទី ៩ ដោយសារការប្រឈមរបស់កម្ពុជាទៅនឹងគ្រោះធម្មជាតិ និងចំនុចដែលសំខាន់នោះគឺដោយសារ សមត្ថភាពបន្សាំ និងសមត្ថភាពទប់ទល់របស់ប្រជាពលរដ្ឋ ក៏ដូចជាប្រទេសទាំងមូល រួមទាំងរចនាសម្ព័ន្ធ ដើម្បីបង្ការ និងកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយគ្រោះមហន្តរាយ នៅមានកម្រិតនៅឡើយ (Garschagen, et al., 2016)។ ហានិភ័យធំៗដែលកម្ពុជាជួបប្រទះមានដូចជា (តាមលំដាប់ប្រេវ៉ាឡង់)៖ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះទីហ្វុងភ្លើងឆេះព្រៃ ការបាក់ដី។ ហានិភ័យនេះរឹតតែធ្ងន់ធ្ងរទៅទៀត ដោយសារការបន្តរេចរិលធនធានធម្មជាតិ។ តួលេខប៉ាន់ប្រមាណជាផ្លូវការបង្ហាញថា គម្របព្រៃឈើថយចុះពីជិត ៦០% ក្នុងឆ្នាំ ២០០៦ មកនៅតិចជាង ៤៧% ក្នុងឆ្នាំ ២០១៤ (RGC, 2015a; World Bank, 2017b)។ ប្រជាជនដែលងាយរងគ្រោះជាងគេគឺជាអ្នកដែលរស់នៅជុំវិញបឹងទន្លេសាប។

ការប្រែប្រួលអាកាសធាតុ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ គេរំពឹងថានៅអំឡុងពេលបច្ចុប្បន្ននេះ ល្បឿននៃការប្រែប្រួលអាកាសធាតុនៅក្នុងរយៈពេល ៤០ ឆ្នាំទៀតទំនងជានឹងលឿនជាងលទ្ធភាពបន្សាំ របស់វិធីសាស្ត្រធ្វើកសិកម្មនៅតាមមូលដ្ឋាន (IFPRI, 2013)។

ខណៈពេលដែលគ្រោះមហន្តរាយ ដែលកើតឡើងតាមរដូវកាលជារៀងរាល់ឆ្នាំ ច្រើនមានទំហំពីតូចទៅមធ្យម ជាមួយនឹងប្រជាពលរដ្ឋប្រមាណ ៧០% ពឹងអាស្រ័យលើរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត គ្រោះមហន្តរាយធម្មជាតិអាចបង្កផលវិបាក ដែលនាំឱ្យអន្តរាយដល់មុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាភាគច្រើន។ ផលប៉ះពាល់មកលើសហគមន៍ដែលបង្កឡើងដោយសារគ្រោះមហន្តរាយដែលកើតមានជារៀងរាល់ឆ្នាំ ធ្វើឱ្យបញ្ហាប្រឈមជុំវិញការអភិវឌ្ឍ ដែលកើតឡើងដោយសារភាពក្រីក្រ នាពេលបច្ចុប្បន្ននេះកាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ដែលស្តែងចេញតាមរយៈការកើនឡើងនូវការជាប់បំណុលរបស់ប្រជាពលរដ្ឋ និងការប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់ ដែលនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានក្នុងចំណោមប្រជាពលរដ្ឋដែលងាយរងគ្រោះជាងគេ ដូចជាការធ្វើចំណាកស្រុកជាដើម (Humanitarian Response Forum, 2017)។ លើសពីនេះ ចីរភាពនៃវឌ្ឍនភាពដែលសម្រេចបានកន្លងមក អាចបាត់បង់ទៅវិញដោយសារវិបត្តិសេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិ ដូច្នេះចាំបាច់ត្រូវមានការបង្កើនការយកចិត្តទុកដាក់លើការកាត់បន្ថយហានិភ័យ និងការកសាងភាពធន់ទ្រាំ (RGC, 2017)។

បញ្ហាប្រឈមក្នុងការបន្តរក្សា ឬលើកកម្ពស់ចីរភាពនៃការរីកចម្រើនផ្នែកការទទួលបាន និងការបឺតស្រូបស្បៀងនៅបន្តកើតមានឡើង ដោយប្រជាពលរដ្ឋជាច្រើននាក់នៅបន្តងាយរងគ្រោះដោយសារវិបត្តិនានា ដែលនេះអាចកាត់បន្ថយផលចំណេញជាវិជ្ជមាន ដែលសម្រេចបានកន្លងមកនេះ។ ៩០% នៃប្រជាពលរដ្ឋក្រីក្រក្នុងប្រទេសកម្ពុជារស់នៅតំបន់ជនបទ ហើយពួកគេនៅបន្តងាយរងគ្រោះដោយសារវិបត្តិ ដែលកើតមានចំពោះរបរចិញ្ចឹមជីវិតរបស់ពួកគេ ឬវិបត្តិដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែលរស់នៅលើបន្ទាត់ភាពក្រីក្រ ធនាគារពិភពលោកបានរកឃើញថា នៅឆ្នាំ២០១១ វិបត្តិដែលបណ្តាលឱ្យពួកគេខាតបង់ប្រាក់ ១.២០០ រៀលក្នុងមួយថ្ងៃអាចបណ្តាលឱ្យពួកគេមានភាពក្រីក្រ ដែលបណ្តាលឱ្យមានកំណើនភាពក្រីក្រមានភាពទ្វេដង ក្នុងអំឡុងពេលនោះ” (World Bank, 2013)។

## ភាពងាយរងគ្រោះ និងយុទ្ធសាស្ត្រទប់ទល់

ការវិភាគលើភាពងាយរងគ្រោះដែលធ្វើឡើងដោយ UNDP បង្ហាញថា វិបត្តិនានាដូចជាវិបត្តិហិរញ្ញវត្ថុសកល និងវិបត្តិតម្លៃស្បៀងឆ្នាំ ២០០៩ បង្ហាញថា ជនដែលងាយរងគ្រោះ និងងាយទទួលរងផលប៉ះពាល់លើសលុប ដោយសារវិបត្តិសេដ្ឋកិច្ច។ ចន្លោះពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ ប្រជាពលរដ្ឋងាយរងគ្រោះ (៤៧%) និងប្រជាពលរដ្ឋដែលមានជីវភាពកម្រិតមធ្យម (៥៣%) បានធ្លាក់ចូលទៅក្នុងកម្រិតទាបជាងមុននៃភាពក្រីក្រ ដែលករណីនេះអាចបណ្តាលមកពីវិបត្តិស្បៀងអាហារកាលពីឆ្នាំ២០០៨ ដល់២០០៩ ដែលធ្វើឱ្យប៉ះពាល់ដល់កម្រិតនៃភាពក្រីក្រដែលសម្រេចបានត្រឹមឆ្នាំ២០០៨។ ក្រោយមក នៅអំឡុងឆ្នាំ២០០៩ ដល់២០១៤ គេឃើញមានភាពប្រសើរឡើងគួរជាទីចាប់អារម្មណ៍ ដោយប្រជាពលរដ្ឋ ក្រីក្រ និងងាយរងគ្រោះ (៥២%) និងប្រជាពលរដ្ឋដែលមានជីវភាពកម្រិតមធ្យម (៥%) ដែលរអិលត្រឡប់ទៅរកភាពក្រីក្រវិញ។

លទ្ធផលរកឃើញពីការសិក្សាមួយស្តីពីផលប៉ះពាល់នៃគ្រោះរាំងស្ងួត បង្កឡើងដោយបាតុភូតអែលនីញ្ញូ ក្នុងឆ្នាំ ២០១៥-២០១៦ ដោយ FAO et al. (2016a) បានបង្ហាញថា ក្នុងចំណោមប្រជាពលរដ្ឋដែលត្រូវបានសាកសួរសម្រាប់ការសិក្សានេះ មាន ៣៧% លើកឡើងពីបញ្ហាខ្វះខាតទឹក ដែលក្នុងនោះតម្លៃទឹកដែលថ្លៃជាងមុន បានដាក់សម្ពាធផ្នែកហិរញ្ញវត្ថុយ៉ាងច្រើនលើសលុបដល់គ្រួសារក្រីក្រ។ ការបាត់បង់ដំណាំដោយសារគ្រោះរាំងស្ងួត ធ្វើឱ្យទិន្នផលស្រូវ និងជំឡុងមីរបស់ប្រជាពលរដ្ឋថយចុះ ២២% និងមានប្រជាពលរដ្ឋ ៦២% រាយការណ៍ថាបានបាត់បង់ប្រាក់ចំណូលកាលពីមួយឆ្នាំមុននៃការសិក្សានេះ នៅក្នុងនោះប្រជាពលរដ្ឋបាត់បង់ចំណូលជាមធ្យមប្រមាណ ១៩% ពោលគឺ បាត់បង់ប្រមាណ ០,១៩ ដុល្លារក្នុងម្នាក់ក្នុងមួយថ្ងៃ សម្រាប់ប្រជាពលរដ្ឋដែលជិតក្រ។




រូបភាពទី២២៖ ផលប៉ះពាល់នៃបាតុភូត អែលនីញូ ទៅលើហិរញ្ញវត្ថុរបស់គ្រួសារ (FAO et al., 2016)

ជាការខិតខំ ប្រឹងប្រែងកាត់បន្ថយការខាតបង់ទាំងនេះគ្រួសារដែលរងផលប៉ះពាល់ បានប្រើប្រាស់ យុទ្ធសាស្ត្រទប់ទល់ ដែលនាំឱ្យមានផលវិបាក ជាអវិជ្ជមាននៅពេលក្រោយ ជាច្រើន ដូចជាការខ្ចីបុលបន្ថែម ជាមធ្យម ១.២៨២ ដុល្លារក្នុងមួយគ្រួសារដែលធ្វើឱ្យ បំណុលសរុបដែលជាប់ជំពាក់ដោយ គ្រួសារក្រីក្រមាននិន្នាការ កើនឡើងជាងមុន។ ការស្រាវជ្រាវបង្ហាញថា ថ្វីបើការខ្ចីបុលបែបនេះអាចជួយសម្រួល ដល់គ្រួសារដែលកំពុងរស់ក្នុងភាពក្រីក្រ និង/ឬភាពងាយរងគ្រោះក្នុងរយៈពេលខ្លី ប៉ុន្តែវាបង្កទៅជាបញ្ហាព្រួយបារម្ភពីចីរភាពក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលវែង (Foraci/UNDP, 2017)។




រូបភាពទី ២៣៖ ភាគរយគ្រួសារដែលមានរបបអាហារមិនគ្រប់គ្រាន់ (FAO et al., 2016)

វិបត្តិនានា ដូចជា វិបត្តិដែលបង្កឡើងដោយបាតុភូតអែលនីញ្ញូ ក៏បង្កផលប៉ះពាល់ជាអវិជ្ជមានមកលើភាពចម្រុះ

នៃរបបអាហាររបស់គ្រួសារផងដែរ ដែលថយចុះឱ្យកត់សម្គាល់ពី ១២% ក្នុងឆ្នាំ ២០១៤ មក ១៨% ក្នុងឆ្នាំ ២០១៦ (FAO et al, 2016) នៃគ្រួសារដែលរបបអាហារពុំមានលក្ខណៈចម្រុះគ្រប់គ្រាន់។

ដើម្បីគាំទ្រដល់ការកាត់បន្ថយហានិភ័យចាំបាច់ត្រូវមាននូវកិច្ចខិតខំប្រឹងប្រែងត្រៀមបង្ការនិងឆ្លើយតបក៏ដូចជា ការប្រមូល វិភាគទិន្នន័យ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹង ភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋតាមទីតាំងភូមិសាស្ត្រ ការពិនិត្យតាមដាន និងការផ្តល់ព័ត៌មានជាមុនអំពីអាកាសធាតុ ព្រមទាំងការពិនិត្យតាមដាននិន្នាការតម្លៃ ធ្វើយ៉ាងណាដើម្បីបង្កើនការយល់ដឹងអំពីវិបត្តិដែលអាចកើតមានឡើង និងផ្តល់នូវការតម្រង់ទិសដល់អ្នកតាក់តែងគោលនយោបាយ (CARD, 2017b)។

### កត្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី៩

ដោយសារតែប្រទេសកម្ពុជាងាយរងគ្រោះខ្លាំង ដោយសារវិបត្តិអាកាសធាតុ ជាការសំខាន់ណាស់ដែលគេត្រូវការពារសមិទ្ធផលដែលសម្រេចបាន ពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពីវិបត្តិធម្មជាតិ និងវិបត្តិសេដ្ឋកិច្ចនានាតាមរយៈការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងកិច្ចគាំពារសង្គម ដែលឆ្លើយតបចំពោះវិបត្តិទាំងនេះ។

# ៥. ដំណើរឆ្ពោះទៅសម្រេចរបៀបវារៈឆ្នាំ ២០៣០ មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ

ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តម្រូវឱ្យប្រជាពលរដ្ឋគ្រប់រូប នៃគ្រប់ទីតាំងភូមិសាស្ត្រ លក្ខណៈប្រជាសាស្ត្រ យេនឌ័រ ស្ថានភាពសង្គម សេដ្ឋកិច្ច វប្បធម៌ ឬជាតិពន្ធុទទួលបានភាគផលស្មើៗគ្នាពីកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ជាការពិត កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពពឹងអាស្រ័យលើលទ្ធភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីចូលរួម និងរួមចំណែកបន្តកំណើនសេដ្ឋកិច្ច។ ការផាត់ចេញក្រុមណាមួយអាចធ្វើឱ្យប៉ះពាល់ដល់អន្តរកាលរបស់ប្រទេសកម្ពុជា ដើម្បីក្លាយជាប្រទេសចំណូលមធ្យម និងងើបចេញពីចំណាត់ថ្នាក់ជាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

កំណើនបរិយាបន្ន តម្រូវឱ្យមានការកំណត់រកអ្នកដែលពុំត្រូវបានគិតគូរដោយយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលផ្តោតលើប្រជាជនភាគច្រើន។ ការវិភាគលើព័ត៌មាន ដែលមានស្រាប់ក្នុងគោលបំណងកំណត់រកឱ្យឃើញនូវគម្លាត និងវិសមភាព ដែលលាក់កំបាំងនៅខាងក្រោមតួលេខជាមធ្យមរបស់ប្រទេស ជួយឱ្យគេអាចទទួលបាននូវព័ត៌មានស៊ីជម្រៅសំខាន់ៗ និងផ្តល់ព័ត៌មានសម្រាប់រៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ផ្តោតចំគោលដៅ។ ការវិភាគទាំងនេះអាចបញ្ចូលការស្វែងយល់ពីភាពខុសប្លែកគ្នានៃលក្ខណៈប្រជាសាស្ត្រនិងលក្ខណៈសង្គម-សេដ្ឋកិច្ចរបស់អ្នកដែលងាយរងគ្រោះបំផុត(ដោយប្រើប្រាស់បញ្ហាអាហារូបត្ថម្ភជាកត្តាកំណត់) ផលធៀបភាពងាយរងគ្រោះគិតជាភាគរយរវាងនិងក្នុងចំណោមក្រុមនីមួយៗ (ប្រេវ៉ាឡង់) បន្ទុកចំពោះបញ្ហាប្រឈមរបស់ជាតិ (ចំនួនជនរងគ្រោះប៉ះពាល់ដោយសារភាពងាយរងគ្រោះមួយចំនួន) និងការលំបាកស្មុគស្មាញ ដែលក្រុមងាយរងគ្រោះជួបប្រទះ (ភាពងាយរងគ្រោះចម្រុះ)។

ការវិភាគស៊ីជម្រៅលើទិន្នន័យអំពីការអង្កេតប្រជាសាស្ត្រ សុខភាពកម្ពុជាឆ្នាំ ២០១៤ បានបង្ហាញថា "ក្នុងឆ្នាំ ២០១៤ ស្ថានភាពទ្រព្យសម្បត្តិ គឺជាកត្តាសង្គម-សេដ្ឋកិច្ចសំខាន់ជាងគេ ដែលពាក់ព័ន្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភ ហើយស្ថានភាពអាហារូបត្ថម្ភរបស់កុមារមានទំនាក់ទំនងខ្លាំងជាមួយនឹងស្ថានភាព

អាហារូបត្ថម្ភរបស់ម្ដាយពួកគេ” (Grefeuille et al., 2016)។ ការវិភាគស្រដៀងគ្នាលើស្ថានភាពអាហារូបត្ថម្ភរបស់ម្ដាយបានរកឃើញថា “ក្នុងឆ្នាំ ២០១៤ កត្តាដែលរួមចំណែកធ្វើឱ្យមានបញ្ហាស្គមស្គាំងរួមមាន អាយុតិចបំផុត បញ្ចភាគទ្រព្យសម្បត្តិទាបបំផុត និងភាពស្លេកស្លាំង។ ផ្ទុយទៅវិញ បញ្ហាលើសទម្ងន់មានទំនាក់ទំនងជាមួយនឹងក្រុមដែលមានវ័យកាន់តែចំណាស់ ស្ត្រីដែលទទួលបានការអប់រំតិចតួច ស្ត្រីរស់នៅតំបន់ប្រជុំជន និងស្ត្រីដែលស្ថិតនៅក្នុងបញ្ចភាគទ្រព្យសម្បត្តិខ្ពស់ជាងគេ និងមានផលប៉ះពាល់ជាអវិជ្ជមានជាមួយនឹងភាពស្លេកស្លាំង។ ការថែទាំផ្ទៃពោះ និងស្ថានភាពនៃការសម្រាលមានការរីកចម្រើនជាបន្តបន្ទាប់នៅក្នុងរយៈពេលមួយ ប៉ុន្តែមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ក្នុងចំណោមក្រុមស្ត្រី ដែលទទួលបានការអប់រំខ្ពស់ជាងគេ ស្ត្រីដែលរស់នៅតំបន់ប្រជុំជន និងស្ត្រីដែលមកពីក្រុមបញ្ចភាគទ្រព្យសម្បត្តិខ្ពស់ជាងគេ។ ដូច្នេះ ចាំបាច់ត្រូវអនុវត្ត អន្តរាគមន៍ជាក់លាក់ ផ្ដោតក្នុងវិស័យសុខាភិបាលផង និងក្រៅវិស័យសុខាភិបាលផង លើស្ត្រីដែលងាយរងគ្រោះជាងគេ ជាពិសេសស្ត្រីវ័យក្មេងជាងគេ ដើម្បីកាត់បន្ថយគម្លាតសមធម៌រវាងស្ត្រី ចំពោះអាហារូបត្ថម្ភ និងការទទួលបាន និងការប្រើប្រាស់សេវាមាតុភាពមុនពេលសម្រាល” (Grefeuille et al., 2015)។ កុមារក្រិសក្រិន និងកុមារដែលពុំមានសំបុត្របញ្ជាក់កំណើត ឬពុំបានចុះសំបុត្រកំណើត គឺជាក្រុមដែលងាយជួបនឹងការលំបាកច្រើនផ្ទួនៗក្នុងពេលតែមួយ ក្នុងកម្រិតខ្ពស់ជាងកុមារដែលមិនមានបញ្ហាក្រិសក្រិន (Karpatti et al., 2017)។

ស្រដៀងគ្នានេះដែរ ស្ត្រីបន្តជួបប្រទះនឹងបញ្ហាអសមធម៌ក្នុងការទទួលបានសេវាផង និងបន្តជួបប្រទះនឹងផលប៉ះពាល់ផ្នែកអាហារូបត្ថម្ភផង (FAO, 2016)។ ការបន្តជួបនឹងបញ្ហាប្រឈមនឹងភាពក្រីក្រ និងអាហារូបត្ថម្ភរឹតតែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត ដោយសារបញ្ហាដែលពាក់ព័ន្ធនឹងការទទួលបានឱកាសប្រកបមុខរបរចិញ្ចឹមជីវិត និងការទទួលបានសេវាសាធារណៈ ដូច្នេះដើម្បីធានាចីរភាពនៃការអភិវឌ្ឍសម្រាប់ប្រជាជនទាំងមូល ចាំបាច់ត្រូវតែមានការយកចិត្តទុកដាក់ចំពោះវិសាលភាពនៃបញ្ហាអសមធម៌ទាំងនេះ ជាផ្នែកមួយនៃរបៀបវារៈ “មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ” ដើម្បីផ្ដល់សេវាដល់អ្នកដែលនៅក្រោយគេ ឬឆ្ងាយជាងគេឱ្យបានមុនគេ។

ការឆ្លុះបញ្ចាំងពីគម្លាតរវាងទីតាំងភូមិសាស្ត្រមួយ និងទីតាំងភូមិសាស្ត្រមួយទៀតបង្ហាញថា អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចកើនឡើងកាន់តែច្រើននៅទីក្រុងភ្នំពេញ ជាងនៅតាមតំបន់វាលទំនាប ឬជុំវិញបឹងទន្លេសាប ដោយ គម្លាតប្រាក់ចំណូលមានកម្រិតខ្ពស់ជាងគេ នៅភូមិភាគព្រៃសាននៃប្រទេស ដែលមានគ្រួសារ ទទួលបានចំណូលតិចជាងគេមួយចំនួន កំពុងរស់នៅ (Foraci/UNDP, 2017; WFP, 2017b)។




រូបភាពទី ២៤៖ របាយនៃការជួបការលំបាក របស់កុមារអាយុ 0-៤ ឆ្នាំ បែងចែកទៅតាមភូមិភាគ (Karpati et al., 2017)

ការវិភាគ ភាពក្រីក្រពហុសមាសភាព បានរកឃើញថានៅទូទាំងប្រទេស មានកុមារអាយុ 0-៤ ឆ្នាំ ៩៧,២% ជួបប្រទះនឹងការលំបាក លើបញ្ហាចម្រុះចំនួន ៣ ទៅ ៦ យ៉ាងតិច (ដូចជា

លំនៅដ្ឋាន ទឹកស្អាត និងអនាម័យ សុខភាពអាហារូបត្ថម្ភ ការអភិវឌ្ឍកុមារតូច) ចំណែកឯនៅភូមិភាគឦសានវិញ អត្រានេះមានរហូតដល់ទៅ ៧៤,៧% (Karpatti et al., 2017)។

វិសមភាពនៃការទទួលបានសេវាមានន័យថា ខណៈពេលដែលអាហារអាចរកបានជាទូទៅ ការពុំមានលទ្ធភាពទិញអាហារទាំងនេះ នាំឱ្យប្រជាពលរដ្ឋពុំមានរបបអាហារចម្រុះគ្រប់គ្រាន់ ដែលបញ្ហានេះមានកម្រិតខ្ពស់បំផុតក្នុងចំណោមប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រជាងគេ។ ខណៈពេលដែលជាមធ្យមមានគ្រួសារ ២១% ពុំអាចមានលទ្ធភាពទទួលបានរបបអាហារឱ្យបានគ្រប់គ្រាន់ប្រកបដោយអាហារូបត្ថម្ភ និងអស់ចំណាយតិច តួលេខនេះមានចាប់ពី ១២% ក្នុងខេត្តពោធិ៍សាត់ និងខេត្តសៀមរាបរហូតដល់ ៦៦% ក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី (NIS, 2009b, 2014; von Grebmer, et al., 2014, 2017; FAO, 2017b; WFP, 2017d)។

គេអាចស្វែងយល់បន្ថែមទៀតពីបម្រែបម្រួលនៃភាពងាយរងគ្រោះ តាមរយៈការឆ្លុះបញ្ចាំងពីដង់ស៊ីតេប្រជាជន។ ប្រាកដណាស់ តំបន់ដែលមានអត្រាប្រវ៉ាឡង់ខ្ពស់នៃ បញ្ហាអាហារូបត្ថម្ភ និង/ឬភាពក្រីក្រពហុសមាសភាគ ត្រូវការយុទ្ធសាស្ត្រដោះស្រាយដែលផ្តោតចំគោលដៅ ដើម្បីធានាឱ្យអ្នកដែលនៅក្រោយគេទទួលបានការគាំទ្រចាំបាច់ ដើម្បីរីកចម្រើន និងទទួលបានភាគផលពីឱកាសកំណើនសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវមានការទទួលស្គាល់ផងដែរថា តំបន់ដែលមានអត្រាប្រវ៉ាឡង់ទាបអាចនឹងមានប្រជាពលរដ្ឋក្នុងចំនួនច្រើន ដែលរងផលប៉ះពាល់ ដោយសារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ តំបន់មួយអាចនឹងមានអត្រាប្រវ៉ាឡង់(ឬភាគរយ)ទាប ប៉ុន្តែដោយសារតំបន់នោះមានចំនួនប្រជាពលរដ្ឋច្រើន វាធ្វើឱ្យចំនួនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ក៏មានបរិមាណខ្ពស់ផងដែរ។

គេអាចប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗ ដើម្បីធានាយ៉ាងណាឱ្យអ្នកទាំងនេះអាចទទួលបាននូវសេវាមូលដ្ឋាន ព្រមទាំងអន្តរាគមន៍បង្កើនការយល់ដឹង និងផ្លាស់ប្តូរឥរិយាបទ។




រូបភាពទី ២៥៖ ចំនួនជាអត្រាប្រេវ៉ាឡង់ (រូបខាងឆ្វេង) (CDHS, 2014) ធៀបនឹង
ចំនួនជាតួលេខពិត ប៉ាន់ស្មាន (រូបខាងស្តាំ) (ទិន្នន័យឃុំ ឆ្នាំ ២០១៥) នៃកុមារដែលមានបញ្ហាក្រិសក្រិន។
សម្គាល់៖ ពណ៌ដិតខ្លាំងនៅលើផែនទីតំណាងឱ្យតំបន់ដែលមានកម្រិតនៃភាពក្រិសក្រិនខ្ពស់។

# អន្តរាគមន៍អាហារូបត្ថម្ភ ជាចលករពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ស្ថានភាពអាហារូបត្ថម្ភដ៏ប្រសើរបំផុតមានសារៈសំខាន់ណាស់ ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពភាគច្រើន ហើយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពភាគច្រើន ក៏មានឥទ្ធិពលត្រឡប់មកលើសន្តិសុខអាហារូបត្ថម្ភវិញដែរ។ ដូច្នេះអាហារូបត្ថម្ភក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគោលដៅ និងសូចនាករផ្សេងទៀតដែរ ក្រៅពីគោលដៅទី ២ ដែលផ្តោតលើការឆ្លើយតបចំពោះភាពអត់ឃ្លាន។ ហេតុដូច្នេះចាំបាច់ត្រូវមានការប្រើប្រាស់អភិក្រមសន្តិសុខអាហារូបត្ថម្ភពហុវិស័យដើម្បីសម្រេចជោគជ័យលើគោលដៅទាំងនេះ (SUN-CSA, 2017)។

ការព្រួយបារម្ភនៅតែមានជុំវិញស្ថានភាពអាហារូបត្ថម្ភ ដោយយោងតាមនិន្នាការបច្ចុប្បន្ននេះ ចំណុចដៅសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលផ្តោតលើការកាត់បន្ថយបញ្ហាអាហារូបត្ថម្ភនឹងមានការលំបាកក្នុងការសម្រេចបាន។ ដូច្នេះ ចាំបាច់ត្រូវមានការផ្តល់អាទិភាពលើអន្តរាគមន៍អាហារូបត្ថម្ភក្នុងនាមជា “ចលករពន្លឿន” ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឱ្យបានឆាប់រហ័ស ពីព្រោះអាហារូបត្ថម្ភនឹងបង្កឱ្យមានផលសាយភាយដល់វិស័យដទៃទៀត ដូចជា វិស័យអប់រំ សុខាភិបាល និងការបង្កើនកម្លាំង




រូបភាពទី២៦៖ អាហារូបត្ថម្ភមានសារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងអស់ (SUN-CSN, 2017)

ពលកម្មដែលមានផលិតភាព និងមានជំនាញជាដើម។ ក្រៅពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២ អាហារូបត្ថម្ភមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគោលដៅដទៃទៀតចំនួន ១១។ ហេតុដូច្នេះ អន្តរាគមន៍អាហារូបត្ថម្ភគឺជាចលករមួយដ៏ប្រសើរបំផុត ដែលអាចពន្លឿនការសម្រេច មិនត្រឹមតែគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ២ ប៉ុណ្ណោះទេ ថែមទាំងគោលដៅអភិវឌ្ឍន៍ជាច្រើនផ្សេងទៀត ដែលពឹងផ្អែកលើឥទ្ធិពលនៃសុខមាលភាពអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋកម្ពុជា។

ការបង្កើនការផ្ដោតការយកចិត្តទុកដាក់លើ ស្ថានភាពអាហារូបត្ថម្ភនៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩-២០២៣ ខាងមុននេះ អាចទទួលបានប្រយោជន៍ពីការគិតពិចារណាឡើងវិញទៅលើក្របខ័ណ្ឌដែលមានស្រាប់ ពីព្រោះ អាហារូបត្ថម្ភមិនគ្រាន់តែជាចំនុចសំខាន់របស់សសរស្តម្ភនៃការបឺតស្រូបស្បៀងនោះទេ វាគឺជាកត្តាចម្បងដ៏សំខាន់សម្រាប់ក្របខ័ណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់កម្ពុជានាពេលអនាគត។ ការគិតគូរបែបនេះនឹងលើកទឹកចិត្តឱ្យរាល់សកម្មភាពទាំងអស់រួមចំណែកក្នុងទម្រង់ជាអន្តរាគមន៍ដែលផ្ដោតលើអាហារូបត្ថម្ភ ឬអន្តរាគមន៍ដែលគិតគូរពីអាហារូបត្ថម្ភដើម្បីបន្តសម្រេចចំណុចដៅផ្នែកអាហារូបត្ថម្ភ និងធានាឱ្យមានការរួមចំណែកកាន់តែច្រើនជាងមុនដល់ការសម្រេចចំណុចដៅផ្សេងទៀតនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២ក៏ដូចជាគោលដៅដទៃទៀតក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងមូល។

## កត្តាយុទ្ធសាស្ត្រសម្រាប់ពិចារណា ទី១០

គោលការណ៍មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍអំពាវនាវឱ្យមានការវិភាគស៊ីជម្រៅលើទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីស្វែងរកក្រុមដែលងាយរងគ្រោះ។ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ពិសេសលើការរៀបចំ និងការកំណត់គោលដៅនៃយុទ្ធសាស្ត្រអន្តរាគមន៍ ដោយត្រូវផ្តល់ការយកចិត្តទុកដាក់ពិសេសលើអ្នកដែលនៅក្រោយគេ។ ដោយសារតែអាហារូបត្ថម្ភមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចំណុចដៅ ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១២ ការវិនិយោគលើអាហារូបត្ថម្ភមិនមែនគ្រាន់តែជាអន្តរាគមន៍រួមចំណែកនោះទេ។អាហារូបត្ថម្ភចាំបាច់គួរតែជាអន្តរាគមន៍ជាចម្បង សម្រាប់ឈានដល់ដល់ការសម្រេចក្របខ័ណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ហើយអន្តរាគមន៍អាហារូបត្ថម្ភអាចផ្តល់នូវភាគលាភដ៏ធំក្នុងកិច្ចខិតខំប្រឹងប្រែងជាតិក្នុងការឆ្ពោះទៅរកការសម្រេចរបៀបវារៈឆ្នាំ ២០៣០។

# បញ្ជីឯកសារយោង

## ឯកសាររបស់ស្ថាប័នរដ្ឋាភិបាល


Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of Cambodia. (2018). Speech Delivered at the Meeting to Commemorate the 39th Anniversary of the 7-January Victory (7 January 1979-2018) [Unofficial Translation] http://cnv.org.kh/39th-anniversary-7-january-victory/

Cambodian Rehabilitation and Development Board and Council for the Development of Cambodia. (2016). Development Cooperation and Partnerships Report

Cambodian Rehabilitation and Development Board and Council for the Development of Cambodia. (2017). Cambodia Development Finance Assessment.

Council for Agricultural and Rural Development. (2017a). Mid-Term and Strategic Review of the National Strategy for Food Security and Nutrition 2014-2018 - III. Strategic Directions Towards 2030.

Council for Agricultural and Rural Development. (2017b). NSFSN MTSR National Consultation Workshop Report.

Council for Agricultural and Rural Development. (2017c). NSFSN MTSR Regional Consultation Workshops Report.

Council for Agricultural and Rural Development. (2017d). Mid-Term and Strategic Review of the National Strategy for Food Security and Nutrition 2014-2018 - I. Progress Inventory 2016.

Council for Agricultural and Rural Development, United Nations Children's Fund, World Food Programme. (2013). The Economic Consequences of Malnutrition in Cambodia: A Damage Assessment Report.

Leng Soklong/National Bank of Cambodia. (2016). Interest Rate Understanding and Possible Distortions of Interest Rate Cap in Case of Cambodia.

Ministry of Agriculture Forestry and Fisheries. (2017). Annual Report and Direction 2017-2018 for Agriculture, Forestry and Fisheries 2016-2017.

Ministry of Economy and Finance. (2016a). Budget in Brief: Fiscal Year 2016.

Ministry of Economy and Finance. (2016b). Cambodia's Macroeconomic Progress: A Journey of 25 years.

Ministry of Economy and Finance. (2017). Budget in Brief: Fiscal Year 2017.

Ministry of Education, Youth and Sport. (2015). Results of Grade Six Student Achievement from the National Assessment in 2013.

Ministry of Education, Youth and Sport. (2017). Education Statistics and Indicators 2016-2017. Retrieved from http://www.moeys.gov.kh/en/emis/2461.html#.WjjGI_YxXOh

Ministry of Environment. (2016). Initial Forest Reference Level for Cambodia Under the UNFCCC Framework.

Ministry of Health. (2013). National Strategic Plan for the Prevention and Control of Noncommunicable Diseases 2013-2020.

Ministry of Health. (2014). Fast Track Road Map for Improving Nutrition 2014-2020.

Ministry of Planning. (2012). Report of the Cambodian Rural Urban Migration Project.

Ministry of Women's Affairs. (2014). Neary Rattanak IV, National Strategic Plan for Gender Equality and Women's Empowerment, 2014-2018.

National Institute of Statistics. (2005). Cambodia Socio-Economic Survey 2003-04, Household Survey 2004.

National Institute of Statistics. (2009a). 2008 General Population Census.

National Institute of Statistics. (2009b). Cambodia Socio Economic Survey.

National Institute of Statistics. (2013a). Cambodia Inter-Censal Population Survey: Provisional Report.

National Institute of Statistics. (2013b). Economic Census.

National Institute of Statistics. (2014). Cambodia Socio Economic Survey.

National Institute of Statistics. (2017). Consumer Price Index Report.

National Institute of Statistics, Directorate General for Health [Cambodia], and ORC Macro. (2001). Cambodia Demographic and Health Survey 2000.

National Institute of Statistics, Directorate General for Health [Cambodia], and ORC Macro. (2006). Cambodia Demographic and Health Survey 2005.

National Institute of Statistics, Directorate General for Health [Cambodia], and ORC Macro. (2011). Cambodia Demographic and Health Survey 2010.

National Institute of Statistics, Directorate General for Health, and ICF International. (2015). Cambodia Demographic and Health Survey 2014.

National Maternal and Child Health Center. (2016). National Nutrition Report.

Prak, Sophonneary. (2016, June). Nutrition Situation in Cambodia "Secondary 2014 CDHS Analysis", Presentation at Annual SUN Meeting.

Royal Government of Cambodia. (2013). Rectangular Strategy: Phase III.

Royal Government of Cambodia. (2014a). Fast Track Road Map for Improving Nutrition 2014-2020.

Royal Government of Cambodia. (2014b). National Strategic Development Plan 2014-2018.

Royal Government of Cambodia. (2014c). National Strategy for Food Security and Nutrition 2014-2018.

Royal Government of Cambodia. (2015a). Climate Change Financing Framework.

Royal Government of Cambodia. (2015b, June). Disaster Management Law, Articles 1 & 2.

Royal Government of Cambodia. (2016). Social Protection Policy Framework, 2016-2025.

Royal Government of Cambodia. (2016a). National Action Plan for the Zero Hunger Challenge in Cambodia 2016-2025.

Royal Government of Cambodia. (2016b). National Social Protection Policy Framework 2016-2025.

Royal Government of Cambodia. (2017). Mid-Term Review of the National Strategic Development Plan 2014-2018.

## ឯកសាររបស់ស្ថាប័ននានា

Alderman, H., & Ruel, M. (2013). Nutrition-sensitive Interventions and Programmes: How Can They Help to Accelerate Progress in Improving Maternal and Child Nutrition? The Lancet 382, 536-551.

ASEAN Secretariat. (2017). ASEAN Regional Guidelines on Food Security and Nutrition Policy.

Asian Development Bank. (2014). Cambodia Country Poverty Analysis.

Asian Development Bank. (2017). Asian Development Outlook: Economic Trends and Forecasts.

BBC Media Action. (2014). Youth in Cambodia: Media Habits and Information Sources.

Bhutta, Z. (2013). Early nutrition and adult outcomes: pieces of the puzzle. Lancet.

Bundy, D. et al. (2009). Rethinking School Feeding: Social Safety Nets, Child Development and the Education Sector. World Food Programme and the World Bank.

Climate Investment Funds. (2016). SREP Investment Plan for Cambodia.

Collins, D., Morduch, J., Rutherford, S., & Ruthven, O. (2009). Portfolios of the Poor.

Committee on World Food Security. (2014). Global Strategic Framework for Food Security & Nutrition.

Department for International Development. (2009). The neglected crisis of undernutrition: Evidence for action. London: Department for International Development.

Development Initiatives. (2017). Global Nutrition Report 2017: Nourishing the SDGs. Bristol, UK: Development Initiatives.

Food and Agriculture Organization. (2006). Policy Brief: Food Security.

Food and Agriculture Organization. (2009). Declaration of the World Summit on Food Security.

Food and Agriculture Organization. (2016). The Impact of Gender Policy Processes on the Right to Food: The Case of Cambodia.

Food and Agriculture Organization. (2017a). Ten Common Themes for Nutrtion-Sensitive Agriciulture in Cambodia.

Food and Agriculture Organization. (2017b). FAOSTAT: Cambodia: Country Indicator. Retrieved from http://www.fao.org/faostat/en/#country/115

Food and Agriculture Organization, United Nations Children's Fund and World Food Programme. (2016). Household resilience in Cambodia: A Review of Livelihoods, Food Security and Health: El Niño Situation Analysis.

Foraci, Marisa; United Nations Development Programme. (2017). In and Out of Poverty: An Analysis of Cambodian Poverty and Vulnerability Dynamics Between 2004 and 2014.

Freeland, N., & Cherrier, C.,. (2012). Social Transfers in the Fight Against Hunger: A Resource for Development Practitioners, Tools and Methods Series Reference Document. European Commission.

GAIN. (2015). Cambodia, first country to mandate fish and soy sauce with iron.

Garschagen, M., Hagenlocher, M., Comes, M., Dubbert, M., Sabelfeld, R., Lee, Y. J., . . . Birkmann, J. (2016). World Risk Report. Bündnis Entwicklung Hilft and UNU-EHS.

Grefeuille, V., Sophonneary, P., Laillou, A., Gauthier, L., Hong, R., Hong, R., . . . Berger, J. (2015). Inequity between Cambodian women for nutrition and antenatal care over the last 15 years (2000-2014). Nutrients.

Grefeuille, V., Sophonneary, P., Laillou, A., Gauthier, L., Hong, R., Hong, R., . . . Berger, J. (2016). Persistent Inequalities in Child under-Nutrition in Cambodia from 2000 till Today. Nutrients.

Haslett, S.; Jones, G.; and Sefton. A.;. (2013). Small-area Estimation of Poverty and Malnutrition in Cambodia. Cambodia: National Institute of Statistics, Ministry of Planning, Royal Government of Cambodia and the United Nations World Food Programme.

High-Level Panel of Experts. (2017). Nutrition and food systems. A report by the High Level Panel of Experts on Food Security and Nutrition of the Committee on World Food Security. Rome.

Humanitarian Response Forum. (2017). Contingency Plan.

Inland Fisheries Research and Development Institute. (2012). Food and Nutrition Security Vulnerability To Mainstream Hydropower Dam Development in Cambodia. Inland Fisheries Research and Development Institute.

Institute of Development Studies. (2014). Gender and Food Security: Towards Gender–Just Food and Nutrition Security.

Institute of Development Studies. (2015). The Hunger and Nutrition Commitment Index (HANCI 2014): Measuring the Political Commitment to Reduce Hunger and Undernutrition in Developing Countries.

International Food Policy Research Institute. (2013). Cambodian Agriculture Adaptation to Climate Change Impact.

Karpati, J., Boon, L., & de Neubourg, C. (2017). Child Poverty in Cambodia. Economic Policy Research Institute, Social Policy Research Institute.

Lancet. (2008). Maternal and Child Undernutrition, Special Series, 371.

Overseas Development Institute. (2017). 10 Things to Know about 'Leave No one Behind'.

Scaling Up Nutrition. (2015). SUN Movement Annual Progress Report 2015.

Scaling Up Nutrition. (2016). SUN Movement Annual Progress Report 2016.

Scaling Up Nutrition. (2017). SUN Movement Annual Progress Report 2017.

Stimson. (2017). Improving UN Situational Awareness.

SUN Civil Society Network. (2017). SDG Toolkit and Scorecard.

United Nations. (2015a, September 25). General Assembly Resolution 70/1. Transforming our world: the 2030 Agenda for Sustainable Development.

United Nations. (2015b). MDG Country Progress Snapshot-Cambodia.

United Nations. (2016). Report on the World Social Situation 2016.

United Nations Children's Fund. (2012). Pneumonia and diarrhoea: tackling the deadliest diseases for the world's poorest children. New York.

United Nations Children's Fund. (2016a). Maternal, Newborn and Child Health and Nutrition.

United Nations Children's Fund. (n.d.). Malnutrition Definition.

United Nations Development Programme. (2014). Post-Flood Early Recovery Need Assessment (PFERNA).

United Nations Development Programme. (2016). 2016 Human Development Report.

United Nations Development Programme. (2017). Cambodia has region's fastest growth rate in human development. Press Release.

United Nations. (n.d.). Sustainable Development Goals.

United Nations Population Fund. (2014). Urbanization and its Linkage to Socio-economic and Environmental Issues.

von Grebmer, K., Bernstein, J., Hossain, N., Brown, T., Prasai, N., Yohannes, Y., . . . Foley, C. (2017). 2017 Global Hunger Index: The inequalities of hunger. Washington, D.C.; Bonn; and Dublin: International Food Policy Research Institute, Welthungerhilfe, and Concern Worldwide.

von Grebmer, K., Saltzman, A., Birol, E., Wiesmann, D., Prasai, N., Yin, S., . . . A., S. (2014). 2014 Global hunger index: Getting to zero hunger. Bonn, Washington, D.C., and Dublin: Welthungerhilfe, International Food Policy Research Institute, and Concern Worldwide.

Wieringa, F. T., Dahl, M., Chamnan, C., Poirot, E., Kuong, K., Sophonneary, P., ... Laillou, A. (2016). The High Prevalence of Anemia in Cambodian Children and Women Cannot Be Satisfactorily Explained by Nutritional Deficiencies or Hemoglobin Disorders.

World Bank. (2013). Where Have All the Poor Gone? Cambodia Poverty Assessment.

World Bank. (2017a). Cambodia Economic Update: Staying Competitive through Improving Productivity.

World Bank. (2017b). Cambodia Systematic Country Diagnostic.

World Bank. (2017c). Data Bank. Retrieved from https://data.worldbank.org/country/cambodia

World Bank and Asian Development Bank. (2015). The Investment Climate Assessment 2014.

World Bank. (n.d.). Population, total. Retrieved from https://data.worldbank.org/indicator/SP.POP.TOTL?locations=KH

World Food Programme. (2016). Household Resilience in Cambodia II (unpublished).

World Food Programme. (2017a). Adolescent Nutrition: formative research Cambodia.

World Food Programme. (2017b). Challenges and Opportunities for Food Security and Nutrition, Mid-Term and Strategic Review Analysis.

World Food Programme. (2017c). Development Financing Analysis for Food Security and Nutrition, MTSR Analysis.

World Food Programme. (2017d). Fill the Nutrient Gap, Cambodia.

World Food Programme. (2017e). Gender Review of Food Security and Nutrition Policies in Cambodia.

World Food Programme. (2017f). Rural Vulnerability and Migration in Cambodia.

World Food Programme. (2017g). Urban Vulnerability in Phnom Penh.

World Health Organization and United Nations Children's Fund. (2015).

World Health Organization, United Nations Children's Fund, and International Baby Food Action Network. (2016). Marketing of breast-milk substitutes: National implementation of the international code.

ទីស្ដីការគណៈរដ្ឋមន្ត្រី
#41 មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រលេខ៖ 2470 ទូរសារ/ទូរស័ព្ទ (+855) 23 426 824
អ៊ីម៉ែល៖ info@card.gov.kh គេហទំព័រ៖ www.card.gov.kh